# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងអប់រំ យុវជន និងកីឡា

# សៀវភៅណែនាំពិសោធន៍វិទ្យាសាស្ត្រ (Lab Protocol) សម្រាប់ការរៀន និងបង្រៀន នៅមធ្យមសិក្សាទុតិយភូមិ

# មុខវិជ្ជា ជីវវិទ្យា

**គាំទ្រដោយគម្រោងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា**
**សម្រាប់ការអប់រំមធ្យមសិក្សាទុតិយភូមិ STEP UP**

កុម្ភៈ ២០២៥

# បុព្វកថា

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវវិធានការកំណែទម្រង់វិស័យអប់រំ ដោយផ្តោតលើការពង្រឹងគុណភាពអប់រំនៅគ្រប់កម្រិតសិក្សា និងការបង្កើនការចូលរៀនមុខវិជ្ជាវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ជាពិសេសការលើកកម្ពស់ការអប់រំស្ទែម ដែលជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍធនធានមនុស្សសម្រាប់សង្គម និងសេដ្ឋកិច្ចកម្ពុជា នាសតវត្សរ៍ទី២១។

ក្រសួងអប់រំ យុវជន និងកីឡា បាននឹងកំពុងផ្តល់ការគាំទ្រទាំងផ្នែករឹង និងផ្នែកទន់ដល់សាលារៀន ដូចជា ការធ្វើទំនើបកម្មថ្នាក់រៀន បន្ទប់ពិសោធន៍ ការបំពាក់សម្ភារៈ និងឧបករណ៍ពិសោធន៍ ការផ្តល់ឯកសារគាំទ្រដល់ការរៀន និងបង្រៀន ការបំប៉ននិងបង្វឹកគ្រូបង្រៀន និងការលើកកម្ពស់ការសិក្សាបន្ថែមក្រៅម៉ោង។ ទន្ទឹមគ្នានេះ **សៀវភៅណែនាំពិសោធន៍វិទ្យាសាស្ត្រ និងការផលិតវីដេអូពិសោធន៍វិទ្យាសាស្ត្រ**(Lab Protocol) **សម្រាប់ការរៀន និងបង្រៀននៅសាលាមធ្យមសិក្សាទុតិយភូមិ** ត្រូវបានរៀបចំឡើងដើម្បីបន្ស៊ីទៅនឹងតម្រូវការនៃការអនុវត្តជាក់ស្តែងលើការរៀន និងបង្រៀនពិសោធន៍ និងការអប់រំស្ទែម សម្រាប់ជួយលើកកម្ពស់គុណភាពនៃបង្រៀន និងរៀននៅមធ្យមសិក្សាទុតិយភូមិ ដោយមានការចូលរួមពីក្រុមគ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ ក្រុមការងារបច្ចេកទេសនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា គ្រូបង្រៀនសាលារៀនជំនាន់ថ្មីនៃវិទ្យាល័យព្រះស៊ីសុវត្ថិ និងគ្រូបង្រៀនវិទ្យាល័យធនធាន ក្រោមការគាំទ្រថវិកាពីគម្រោងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអប់រំកម្រិតមធ្យមសិក្សា(STEP-UP)។ សៀវភៅណែនាំនេះ នឹងជួយគាំទ្រដល់ការអនុវត្តការពិសោធវិទ្យាសាស្ត្រលើមុខវិជ្ជារូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា ដែលក្នុងមួយមុខវិជ្ជាមានចំនួន១៨ពិសោធន៍ សម្រាប់ថ្នាក់ទី១០ ទី១១ និងទី១២ អមទៅដោយវីដេអូពិសោធន៍វិទ្យាសាស្ត្រ។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរចំពោះក្រុមការងារបច្ចេកទេស និងគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ដែលបានខិតខំប្រឹងប្រែង ធ្វើឱ្យសម្រេចបានជាផ្លែផ្កានូវស្នាដៃដ៏មានសារៈសំខាន់នេះទុកជាប្រយោជន៍ដល់អ្នកសិក្សានៅកម្ពុជា។

ថ្ងៃ ចន្ទ ៥រោច ខែ មាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ កុម្ភៈ ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# អារម្ភកថា

សៀវភៅណែនាំពិសោធន៍វិទ្យាសាស្ត្រសម្រាប់គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិនេះ បានកើតឡើងក្រោមគំនិតផ្តួចផ្តើមរបស់ក្រសួងអប់រំ យុវជន និងកីឡា និងទទួលបាននូវការគាំទ្រថវិកាដោយធនាគារអភិវឌ្ឍន៍អាស៊ី(ADB)។ សៀវភៅនេះត្រូវបានសហការផលិតឡើងដោយក្រុមខ័ណ្ឌអ្នកបច្ចេកទេសមកពីវិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា នាយកដ្ឋានមធ្យមសិក្សា វិទ្យាល័យធនធាន និងសាលារៀនជំនាន់ថ្មីវិទ្យាល័យព្រះស៊ីសុវត្ថិ។ ការផលិតសៀវភៅណែនាំពិសោធន៍នេះឡើង ក្នុងគោលបំណងបំពេញបន្ថែមទៅលើចំណុចខ្វះខាតរបស់សៀវភៅណែនាំពិសោធន៍ដែលបានបោះពុម្ពក្នុងឆ្នាំសិក្សា២០២៣-២០២៤កន្លងទៅ ក៏ដូចជាបំពេញនូវសេចក្តីត្រូវការជាក់ស្តែងរបស់លោកគ្រូអ្នកគ្រូមុខវិជ្ជាជីវវិទ្យាដែលបាននឹងកំពុងបង្រៀននៅតាមវិទ្យាល័យធនធាន វិទ្យាល័យ បណ្តាញ និងវិទ្យាល័យសាធារណៈរបស់ក្រសួងអប់រំ យុវជន និងកីឡាទូទាំងប្រទេសកម្ពុជា។ សៀវភៅថ្មីនេះមានលក្ខណៈពិសេស និងសំខាន់ចំនួនបីគឺ៖ ១) សេចក្តីណែនាំខ្លីសម្រាប់គ្រូ ២) បញ្ជីត្រួតពិនិត្យ និង៣) សន្លឹកកិច្ចការពិសោធន៍។ ក្រៅពីលក្ខណៈពិសេសទាំងបីខាងលើ សៀវភៅនេះក៏បានបញ្ចូលផងដែរ នូវទម្រង់វិធីសាស្ត្របង្រៀនតាមទ្រឹស្តីអប់រំបែបស្ថាបនានិយម ដោយបើកចំហឱ្យលោកគ្រូអ្នកគ្រូនៅតាមវិទ្យាល័យអាចបញ្ចូលវិធីសាស្ត្របង្រៀនបែបសកម្មណាមួយ (ឧទាហរណ៍ វិធីសាស្ត្របង្រៀនបែបរិះរក វិធីសាស្ត្របង្រៀន5Es ឬវិធីសាស្ត្របង្រៀនបែបដោះស្រាយបញ្ហាជាដើម) រួមទាំងយុទ្ធវិធីបង្រៀនយ៉ាងសម្បូរបែប។ ហេតុដូច្នេះហើយ គ្រប់សន្លឹកកិច្ចការពិសោធន៍នៅក្នុងសៀវភៅនេះ ពុំបានកំណត់ថាគ្រូត្រូវតែប្រើប្រាស់វិធីសាស្ត្រណាមួយដាច់ខាតនោះទេ។ លក្ខណៈពិសេសមួយទៀតរបស់សៀវភៅណែនាំពិសោធន៍ថ្មីនេះ ក៏បានបញ្ចូលផងដែរនូវនវានុវត្តន៍ចំណេះដឹងនៅក្នុងមេរៀននីមួយៗ (Lesson Concept Extent) ដែលជួយដល់លោកគ្រូអ្នកគ្រូក្នុងការដឹកនាំសិស្សឱ្យពង្រីកចំណេះតាមរយៈការសិក្សាស្រាវជ្រាវបន្ថែម និងការដោះស្រាយបញ្ហា (បាតុភូត) នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ នវានុវត្តន៍ចំណេះដឹងនេះក៏បានបន្សុីគ្នាផងដែរ ទៅនឹងដំណើរការសិក្សានៃការអប់រំស្វែម ដែលក្រសួងអប់រំ យុវជន និងកីឡាបាននឹងកំពុងដាក់ឱ្យអនុវត្តឱ្យបានសកម្ម និងប្រសិទ្ធភាពនៅគ្រប់កម្រិតគ្រឹះស្ថានអប់រំសាធារណៈ។ បន្ថែមពីនេះទៀត នៅលើសន្លឹកនៃសេចក្តីណែនាំសម្រាប់គ្រូ គ្រប់មេរៀន ក៏បានភ្ជាប់ជាមួយកូដតំណភ្ជាប់ (QR Code) ផ្តល់ភាពងាយស្រួលដល់លោកគ្រូ អ្នកគ្រូចូលទៅកាន់វីដេអូពិសោធន៍នីមួយៗ។

បើទោះបីជាយ៉ាងណាក៏ដោយ ក្រុមអ្នកនិពន្ធយល់ឃើញថាសៀវភៅនេះប្រាកដជានៅមានចំណុចខ្វះខាតក្នុងកម្រិតណាមួយ។ ហេតុដូច្នេះក្រុមអ្នកនិពន្ធរងចាំទទួលនូវការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់ឯកឧត្តម លោកជំទាវ លោកលោកស្រី និងលោកគ្រូអ្នកគ្រូគ្រប់មជ្ឈដ្ឋាន។ យើងខ្ញុំទាំងអស់គ្នាដែលជាក្រុមអ្នកនិពន្ធសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះគំនិតកែលម្អរបស់ឯកឧត្តមលោកជំទាវ លោកលោកស្រី និងលោកគ្រូអ្នកគ្រូទាំងអស់លើខ្លឹមសារទាំងស្រុងរបស់សៀវភៅនេះ។

ថ្ងៃចន្ទ ១៥កើត ខែបុស្ស ឆ្នាំរោង ឆស័ក ពស.២៥៦៨
ភ្នំពេញថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៥
ក្រុមអ្នកនិពន្ធ

ចងក្រង និងបោះពុម្ពដោយ៖ វិទ្យាស្ថានជាតិអប់រំ ខែមករា ឆ្នាំ២០២៥
**គាំទ្រថវិកាដោយ៖ គម្រោងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអប់រំមធ្យមសិក្សា (STEP UP)**
© វិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០២៥

## គណៈកម្មការនិពន្ធ

| | | | |
|---|---|---|---|
| ១) | លោក | **ផែន សារិត** | គ្រូឧទ្ទេសជីវវិទ្យា វ.ជ.អ |
| ២) | លោកស្រី | **ឈូក ណាស្រស់** | គ្រូឧទ្ទេសជីវវិទ្យា វ.ជ.អ |
| ៣) | លោកស្រី | **ម៉ែន ភក្តី** | គ្រូឧទ្ទេសជីវវិទ្យា វ.ជ.អ |
| ៤) | លោកបណ្ឌិត | **ម៉ិន សារ៉េត** | គ្រូឧត្តមសិក្សា មហាវិទ្យាល័យវារីសាស្ត្រ វ.ប.ក. |
| ៥) | កញ្ញាបណ្ឌិត | **សាំង ដាវិន** | គ្រូឧត្តមសិក្សា មហាវិទ្យាល័យវារីសាស្ត្រ វ.ប.ក. |
| ៦) | លោក | **ឡឹង ចន្ធី** | សាស្ត្រាចារ្យដេប៉ា.ជីវវិទ្យា ស.ភ.ម.ភ |
| ៧) | លោក | **ផាន់ ចាន់ណារិទ្ធ** | មន្ត្រីនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ |
| ៨) | លោកស្រី | **ញ៉ុន ចរិយា** | មន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| ៩) | កញ្ញា | **គឹម សុន្តារី** | គ្រូវិទ្យាល័យព្រះស៊ីសុវត្ថិ-សាលារៀនជំនាន់ថ្មី |
| ១០) | កញ្ញា | **នាង សុគន្ធា** | គ្រូបង្រៀនជីវវិទ្យាវិទ្យាល័យទេពប្រណម្យ |
| ១១) | លោកស្រី | **លឹម ចន្ធូ** | គ្រូបង្រៀនជីវវិទ្យាវិទ្យាល័យកំពង់ស្ពឺ |
| ១២) | លោក | **សេន សម្បត្តិ** | គ្រូបង្រៀនជីវវិទ្យាវិទ្យាល័យកំពង់ស្ពឺ |
| ១៣) | កញ្ញា | **សុខ ដានី** | គ្រូបង្រៀនជីវវិទ្យាវិទ្យាល័យកំពង់ស្ពឺ |
| ១៤) | លោកស្រី | **ឈូវ សុខេង** | គ្រូបង្រៀនជីវវិទ្យាវិទ្យាល័យ.ចបទ.ព្រះរាជសម្ភារ |
| ១៥) | លោក | **អេវ សំណាង** | គ្រូបង្រៀនជីវវិទ្យាវិទ្យាល័យ.ចបទ.ព្រះរាជសម្ភារ |
| ១៦) | លោកស្រី | **ឡុង យុននាង** | គ្រូបង្រៀនជីវវិទ្យាវិទ្យាល័យជាស៊ីមតាកែវ |
| ១៧) | លោក | **ម៉ៃ ផុនា** | គ្រូបង្រៀនជីវវិទ្យាវិទ្យាល័យជាស៊ីមតាកែវ |
| ១៨) | លោក | **ហេង តារ៉ុម** | គ្រូបង្រៀនជីវវិទ្យាវិទ្យាល័យជាស៊ីមតាកែវ |
| ១៩) | លោក | **អ៊ុក សាម៉េត** | គ្រូបង្រៀនជីវវិទ្យាវិទ្យាល័យព្រះបាទសុរាម្រឹត |
| ២០) | លោកស្រី | **វណ្ណា វិរិយា** | គ្រូបង្រៀនជីវវិទ្យាវិទ្យាល័យព្រះបាទសុរាម្រឹត |
| ២១) | កញ្ញា | **ឆួក ចាន់នី** | គ្រូបង្រៀនជីវវិទ្យាវិទ្យាល័យព្រះបាទសុរាម្រឹត |
| ២២) | លោក | **សៅ ទ្រី** | គ្រូបង្រៀនជីវវិទ្យាវិទ្យាល័យព្រះបាទសុរាម្រឹត |
| ២៣) | លោក | **ពត ចាន់ដារា** | គ្រូបង្រៀនជីវវិទ្យាវិទ្យាល័យព្រះបាទសុរាម្រឹត |
| ២៤) | លោកស្រី | **អម ចាន់ធីតា** | គ្រូបង្រៀនជីវវិទ្យាវិទ្យាល័យព្រះបាទសុរាម្រឹត |
| ២៥) | លោក | **ថេង ម៉េងហ៊ាង** | គ្រូបង្រៀនជីវវិទ្យាវិទ្យាល័យព្រះអង្គឌួង |
| ២៦) | លោក | **ឈុំ ណារ៉ុង** | គ្រូបង្រៀនជីវវិទ្យាវិទ្យាល័យព្រះអង្គឌួង |
| ២៧) | លោកស្រី | **ប៉ោ មូរ៉ាមី** | គ្រូបង្រៀនជីវវិទ្យាវិទ្យាល័យព្រះអង្គឌួង |
| ២៨) | លោក | **សន សុជាលី** | គ្រូបង្រៀនជីវវិទ្យាវិទ្យាល័យព្រះអង្គឌួង |
| ២៩) | លោក | **សុន ស៊ីឈន** | គ្រូបង្រៀនជីវវិទ្យាវិទ្យាល័យស្វាយរៀង |
| ៣០) | លោកស្រី | **ណាន ចន្ធី** | គ្រូបង្រៀនជីវវិទ្យាវិទ្យាល័យស្វាយរៀង |
| ៣១) | លោក | **ម៉ែន ធី** | គ្រូបង្រៀនជីវវិទ្យាវិទ្យាល័យស្វាយរៀង |

## គណៈកម្មការគ្រប់គ្រង

១) ឯកឧត្តម **អ៊ុំ រម្យណី** រដ្ឋលេខាធិការក្រសួង អ.យ.ក.
២) ឯកឧត្តមបណ្ឌិត **ឌី ខាំបូលី** អនុប្រធានគ្រប់គ្រងគម្រោងSTEP UP
៣) ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំ
៤) លោក **ឌី ម៉ុណ្ណា** នាយករងវិទ្យាស្ថានជាតិអប់រំ
៥) លោកបណ្ឌិត **នួន វីរ៉ា** នាយករងវិទ្យាស្ថានជាតិអប់រំ
៦) លោកស្រី **ប៊ុន សុផានី** នាយិការងវិទ្យាស្ថានជាតិអប់រំ
៧) លោក **ថៃ ហេង** នាយករងវិទ្យាស្ថានជាតិអប់រំ

## គណៈកម្មការត្រួតពិនិត្យ និងកែលម្អ

១) លោកបណ្ឌិត **ប៊ុន គឹមចន់** នាយករងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
២) លោក **ម៉ៅ សារឿន** ព្រឹទ្ធបុរសមហាវិទ្យាល័យគរុកោសល្យ វ.ជ.អ
៣) លោក **សម្បូ គឹមសាន្ត** នាយករងវិទ្យាល័យព្រះស៊ីសុវត្ថិ-សាលារៀនជំនាន់ថ្មី
៤) លោកស្រីបណ្ឌិត **ឡឹយ សុគា** ព្រឹទ្ធបុរសរងមហាវិទ្យាល័យគរុកោសល្យ វ.ជ.អ
៥) លោក **រឿន ឬទ្ធី** អនុប្រធានការិ.នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ
៦) លោកបណ្ឌិត **ម៉ម ចាន់សៀន** នាយកសាលាក្រោយបរិញ្ញាបត្រ វ.ជ.អ
៧) លោកបណ្ឌិត **អាន វ៉ូប្រាថ** ព្រឹទ្ធបុរសរងមហាវិទ្យាល័យគរុកោសល្យ វ.ជ.អ
៨) លោក **ចេង ថុន** អនុប្រធានដេប៉ាតឺម៉ង់អប់រំ វ.ជ.អ
៩) លោកស្រី **តែ ស្រីសោភ័ណ** គ្រូឧទ្ទេសអក្សរសាស្ត្រខ្មែរ វ.ជ.អ

## គណៈកម្មការរចនា និងវាយអត្ថបទ

១) លោកស្រី **អ៊ុំ សោភ័ណ** អនុប្រធានអង្គភាពកិច្ចការទូទៅ វ.ជ.អ
២) លោក **ប៊ុនលី ម៉ារឌី** មន្ត្រីដេប៉ាតឺម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ
៣) លោក **ចាន់ រ៉ាដា** មន្ត្រីការិយាល័យគណនេយ្យ វ.ជ.អ
៤) លោក **ឃាង ម៉េងលី** មន្ត្រីការិយាល័យរដ្ឋបាល វ.ជ.អ
៥) លោក **ម៉ូត ណារិន** គ្រូឧទ្ទេសនៃវិទ្យាស្ថានជាតិអប់រំ
៦) កញ្ញា **កែវ កញ្ញា** មន្ត្រីស្ម័គ្រចិត្តដេប៉ាតឺម៉ង់អប់រំ វ.ជ.អ
៧) កញ្ញា **វិរៈ ខេងឡា** មន្ត្រីស្ម័គ្រចិត្តដេប៉ាតឺម៉ង់អប់រំ វ.ជ.អ
៨) កញ្ញា **ជា សូដាតា** មន្ត្រីស្ម័គ្រចិត្តដេប៉ាតឺម៉ង់អប់រំ វ.ជ.អ

# មាតិកា


**បុព្វកថា** ........................................ i

**អារម្ភកថា** ........................................ ii

**គណៈកម្មការនិពន្ធ** ........................................ iii

**សេចក្ដីផ្ដើម** ........................................ ១

**មេរៀនថ្នាក់ទី១០** ........................................ ២

ប្រធានបទទី១៖ ការធ្វើចំណែកថ្នាក់ស្លឹករុក្ខជាតិ ........................................ ២

ប្រធានបទទី២៖ សង្កេតទម្រង់ឆ្អឹងវែង (ឆ្អឹងភ្លៅគោ) ........................................ ៨

ប្រធានបទទី៣៖ ការផលិតដីកំប៉ុស្ដទឹក ........................................ ១៤

ប្រធានបទទី៤៖ របៀបបន្តពូជ និងបង្កាត់រុក្ខជាតិដោយឥតភេទ (ការសាកមែក និងការតដើម ) ........................................ ១៨

ប្រធានបទទី៥៖ សង្កេតជាលិកាសាច់ដុំ ........................................ ២៥

ប្រធានបទទី៦៖ ឥទ្ធិពលពន្លឺលើការប្រើប្រាស់ឧស្ម័នកាបូនិក(CO២)របស់រុក្ខជាតិគោក ......... ៣១

**មេរៀនថ្នាក់ទី១១** ........................................ ៣៧

ប្រធានបទទី១៖ សង្កេតសមាសធាតុគីមីក្នុងស្លឹករុក្ខជាតិ ........................................ ៣៧

ប្រធានបទទី២៖ សង្កេតរូបរាង និងធ្វើអត្តសញ្ញាណអាមីដុងក្នុងរុក្ខជាតិ ........................................ ៤៣

ប្រធានបទទី៣៖ សង្កេតបាតុភូតអូស្មូសក្នុងកោសិការុក្ខជាតិ(ស្លឹកប្រទាលល័ក្ត) ........................................ ៥០

ប្រធានបទទី៤៖ សង្កេតការលូតលាស់អំប្រីយ៉ុងបក្សី (ស៊ុតទា) ........................................ ៥៦

ប្រធានបទទី៥៖ សង្កេតលក្ខណៈរបស់ជ្រូសូភីល ........................................ ៦៣

ប្រធានបទទី៦៖ សង្កេតចំណែកមីតូសឫសខ្ទឹមស ........................................ ៧០

**មេរៀនថ្នាក់ទី១២** ........................................ ៧៧

ប្រធានបទទី១៖ សង្កេតទម្រង់ខួរក្បាលសត្វឆ្អឹងកង(បក្សី) ........................................ ៧៧

ប្រធានបទទី២៖ ទំនាក់ទំនងរវាងវិញ្ញាណរសជាតិ និងវិញ្ញាណក្លិន ........................................ ៨២

ប្រធានបទទី៣៖ សង្កេតឥទ្ធិពលអាំងតង់ស៊ីតេពន្លឺទៅលើរន្ធប្រស្រីភ្នែក ........................................ ៨៨

ប្រធានបទទី៤៖ សង្កេតរុក្ខជាតិម៉ូណូកូទីលេដូន និងរុក្ខជាតិឌីកូទីលេដូន ........................................ ៩៣

ប្រធានបទទី៥៖ ប្រៀបធៀបខួរក្បាលសត្វឆ្អឹងកង ........................................ ១០០

ប្រធានបទទី៦៖ ទំនាក់ទំនងរវាងសម្រូបទឹក និងរំភាយចំហាយទឹក ........................................ ១០៦

# សេចក្តីផ្តើម

ភារកិច្ចរបស់គ្រូបង្រៀនគឺការរៀបចំថ្នាក់រៀនដ៏ទាក់ទាញ និងមានប្រសិទ្ធភាពសម្រាប់បង្រៀនសិស្សនូវមេរៀន នីមួយៗ។ ការរៀបចំថ្នាក់រៀនត្រូវបានរាប់បញ្ចូលទាំងការកំណត់វត្ថុបំណង (ជ្រើសរើសមេរៀនមួយជាក់លាក់) ការរៀបចំសម្ភារៈបង្រៀន ការកំណត់វិធីសាស្ត្រនិងយុទ្ធវិធីបង្រៀន ការកំណត់បច្ចេកវិទ្យា (ICT) សម្រាប់ជួយដល់ការបង្រៀន ព្រមទាំងការផលិតឧបករណ៍វាយតម្លៃលើលទ្ធផលសិក្សារបស់សិស្ស គឺជាភារៈកិច្ចវិជ្ជាជីវៈ ប្រចាំថ្ងៃរបស់គ្រូបង្រៀន។ ក្រៅពីនេះ គ្រូបង្រៀនក៏ត្រូវមានទេពកោសល្យ និងសិល្បៈ (គរុកោសល្យ) នៃការបង្រៀនច្បាស់លាស់ និងប្រកបដោយភាពទាក់ទាញ។ គរុកោសល្យនៃការបង្រៀននៅសតវត្សទី២១ បានផ្លាស់ប្តូរដ៏ធំនូវឥរិយាបថនៃការបង្រៀនរបស់គ្រូ ពីរបៀបនៃការបង្រៀនបែបប្រពៃណីទៅជាការបង្រៀនបែបសកម្ម។ គរុកោសល្យនៃការបង្រៀនបែបប្រពៃណីត្រូវបានឱ្យនិយមន័យថាជាការបង្រៀនបែបតៗគ្នាតាមទម្លាប់បែបធម្មជាតិពីមួយជំនាន់ទៅមួយជំនាន់ទៀត ដោយមិនមានការអភិវឌ្ឍន៍សមត្ថភាពបច្ចេកទេសបង្រៀន ឬមានតិចតួច។ ឧទាហរណ៍គ្រូបង្រៀនតម្រូវឱ្យសិស្សទន្ទេញមេរៀន ថាតាម ឬសូត្រតាមសៀវភៅ ឬតាមគ្រូជាដើម។ ការបង្រៀនបែបនេះបានបណ្តុះទម្លាប់បែបអវិជ្ជនិងអសកម្ម ដោយសិស្សខ្វះបំណិននៃការដោះស្រាយបញ្ហាដោយខ្លួនឯង និងរង់ចាំទទួលតែពីគ្រូ។ វិធីសាស្ត្របង្រៀនបែបប្រពៃណីបានធ្វើឱ្យសិស្សក្លាយជាពលរដ្ឋអសកម្ម (មិនមែនជាពលរដ្ឋផលិត) ដែលធ្វើឱ្យសេដ្ឋកិច្ចពឹងផ្អែកភាគច្រើនលើការនាំចូលពីក្រៅប្រទេសនូវផលិតផលប្រើប្រាស់ប្រចាំថ្ងៃ។ គរុកោសល្យ និងវិធីសាស្ត្របង្រៀនសតវត្សទី២១ បានធ្វើឱ្យបដិវត្តកម្មនៃការអប់រំរបស់ពិភពលោកមានការផ្លាស់ប្តូរយ៉ាងលឿន។ បដិវត្តកម្មនេះក៏បានធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងលឿនលើឧស្សាហកម្មរបស់ពិភពលោក (4.0) ដែលយើងទាំងអស់គ្នាបានទទួលការជះឥទ្ធិពលដោយមិនដឹងខ្លួន ក្នុងនោះរួមមានបដិវត្តកម្មបច្ចេកវិទ្យា (ICT) បញ្ញាសិប្បនិម្មិត (AI) និងបច្ចេកវិទ្យាអវកាសជាដើម។ នៅក្នុងនិន្នាការនៃការប្រែប្រួលនេះ ការអប់រំបានដើរតួនាទីយ៉ាងសំខាន់ និងមិនអាចខ្វះបាន។

បញ្ហាប្រឈមដ៏ធំមួយរបស់គ្រូបង្រៀនគឺបំណិនទន់ (Soft Skill) ដែលអាចអនុវត្តបាននៅក្នុងវិជ្ជាជីវៈបង្រៀនប្រចាំថ្ងៃរបស់ពួកគាត់។ បញ្ហាទាំងនោះរួមមាន៖ គំនិតនវានុវត្តន៍ការប្រើប្រាស់សម្ភារៈឧបទ្ទេសដែលមានស្រាប់ ការកែច្នៃឧបករណ៍ងាយៗសម្រាប់ជួយគាំទ្រដល់ការបង្រៀន ការប្រើប្រាស់ថ្នាលឌីជីថល (Digital plate form) បច្ចេកវិទ្យាព័ត៌មានវិទ្យា បញ្ញាសិប្បនិម្មិត រួមទាំងការអនុវត្តវិធីសាស្ត្របង្រៀនសតវត្សទី២១ (វិធីសាស្ត្របង្រៀនតាមទ្រឹស្តីអប់រំបែបស្ថាបនានិយម)។ កិច្ចការទាំងនេះគឺជាបំណិនស្នូលរបស់គ្រូបង្រៀនដែលត្រូវអនុវត្តន៍ជាប្រចាំ ដើម្បីធ្វើឱ្យការបង្រៀនសម្រេចបាននូវវត្ថុបំណងមេរៀនពេញលេញ និងបរិយាកាសនៃការសិក្សារៀនសូត្ររបស់សិស្សមានភាពសកម្មនិងភាពរីករាយ។ បំណិនទន់ដែលចាំបាច់មួយទៀតរបស់គ្រូបង្រៀន ជាពិសេសមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រគឺ ការដឹកនាំសិស្សឱ្យអនុវត្តន៍ពិសោធទាំងនៅក្នុងថ្នាក់រៀន និងក្រៅថ្នាក់រៀន។ ការអនុវត្តពិសោធន៍ផ្ទាល់ជាប្រចាំរបស់សិស្សបានបណ្តុះនូវបំណិននៃការស្រាវជ្រាវដែលធ្វើឱ្យពួកគេមានគំនិតស្វ័យសិក្សាឆ្ពោះទៅរកការគិតបែបស៊ីជម្រៅ និងគំនិតនៃការបង្កើតថ្មី។

# មេរៀនថ្នាក់ទី១០

## ប្រធានបទទី១៖ ការធ្វើចំណែកថ្នាក់ស្លឹករុក្ខជាតិ

### ១.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូអ្នកគ្រូត្រូវអាន សេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- អានបញ្ជីត្រួតពិនិត្យ (☑ Check List) ខាងក្រោមឱ្យបានយល់ច្បាស់។

២- រៀបចំ ឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការពិសោធន៍ កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់។

៣- ចំពោះស្លឹករុក្ខជាតិ ឱ្យសិស្សរកឱ្យបានកាន់តែច្រើនប្រភេទស្លឹកកាន់តែល្អ។

៤- គ្រូសាកល្បងអនុវត្តធ្វើចំណែកស្លឹករុក្ខជាតិនៅមុនពេលថ្នាក់រៀនចាប់ផ្តើម។

៥- គ្រូអាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១) ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ ឬក្រៅថ្នាក់ធម្មតា និង (២) ជាការសិក្សាបែបគម្រោង។

៦- ក្នុងករណី (១) ថ្នាក់រៀនបែបសកម្ម គ្រូត្រូវផ្ញើវីដេអូ និងសន្លឹកកិច្ចការសិស្សឱ្យសិស្សនៅមុនម៉ោងបង្រៀន មួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)។

៧- ក្នុងករណី (២) ជាការសិក្សាបែបគម្រោង គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទី និងរយៈពេល ឱ្យបានច្បាស់លាស់។ ចំពោះវីដេអូពិសោធន៍ ត្រូវបង្ហាញនៅពេលបន្ទាប់ពីក្រុមនីមួយៗធ្វើបទបង្ហាញលទ្ធផល នៃការសិក្សាបែបគម្រោងរបស់ពួកគេ។

៨- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោម៖
- ☐ ឱ្យសិស្សឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
- ☐ ឱ្យសិស្សឆ្លើយសំណួរផ្ទាល់មាត់
- ☐ ឱ្យសិស្សធ្វើបទបង្ហាញជាក្រុម

៩- ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាមិនគ្រប់គ្រាន់នៅក្នុង ម៉ោងបង្រៀន។

*សូមចូលទៅកាន់វីដេអូពិសោធន៍តាមតំណភ្ជាប់នេះ*

**១.២- បញ្ជីត្រួតពិនិត្យ** ( ☑ Check List )

គ្រូ និងសិស្សត្រូវត្រៀមទៅតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ ក្នុងអំឡុងពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** ( ☑ Check List ) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក១៖ នានាភាពនៃភាវៈរស់<br>មេរៀនទី១ ចំណែកថ្នាក់ និងដើមឈើមែកជាងពូជអម្បូរ ទំព័រ៨-១៣ | |
| ☐ បានបង្រៀនរួចហើយ | ☐ បានរៀនទ្រឹស្តីមេរៀនរួចហើយ |
| **ប្រធានបទ៖ ការធ្វើចំណែកថ្នាក់ស្លឹករុក្ខជាតិ** | |
| ☐ សម្ភារៈបានរៀបចំរួចរាល់រួមមាន ស្លឹករុក្ខជាតិស្រស់មួយចំនួនមានទម្រង់ខុសៗគ្នា ផ្ទាំងក្រដាសស ( ខ្នាត $A_0$ ) ស្កុត ហ្វឺត និងកន្ត្រៃ។ | ☐ បានប្រមូលសម្ភារៈគ្រប់គ្រាន់ |
| ☐ បានត្រៀមសន្លឹកកិច្ចការសិស្សអំពីដំណើរការសង្កេត និងការធ្វើចំណែកថ្នាក់ស្លឹករុក្ខជាតិ ហើយបានចែកឱ្យសិស្សរួចរាល់ | ☐ បានអាន និងយល់ពីដំណើរការ ដែលគ្រូបានចែកឱ្យ |
| ☐ បានត្រៀមវីដេអូអំពីដំណើរការសង្កេត និងការធ្វើចំណែកថ្នាក់ស្លឹករុក្ខជាតិ | ☐ បានសង្កេត និងធ្វើចំណែកថ្នាក់ស្លឹករុក្ខជាតិរួចរាល់ និងមានឯកសារពាក់ព័ន្ធរួចហើយ |
| ☐ បានត្រៀមវិធី ឬសន្លឹកកិច្ចការវាយតម្លៃសិស្សរួចរាល់ | ☐ បានរៀបចំបង្កើតក្រុមនិងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់។ |
| ☐ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទីសមាជិកក្រុមម្នាក់ៗច្បាស់លាស់ ( ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង )។ | |
| **ក្នុងអំឡុងពិសោធន៍** ( ☑ Check List ) | |
| **គ្រូ** | **សិស្ស** |
| ☐ រំឭកដំណើរការសង្កេតស្លឹករុក្ខជាតិដែលមាននៅក្នុងសន្លឹកកិច្ចការសិស្សឡើងវិញ | ☐ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>☐ សង្កេត ពិភាក្សា និងកត់ត្រា ឬធ្វើបទបង្ហាញលទ្ធផល |
| ☐ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួចរាល់ ឬឱ្យសិស្សធ្វើបទបង្ហាញពីលទ្ធផលរបស់ក្រុម ដែលពួកគេបានធ្វើមុនពេលថ្នាក់រៀនចាប់ផ្តើម | ☐ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ។<br>☐ បោសសម្អាតបន្ទប់<br>☐ អាន និងស្វែងយល់បន្ថែម |
| ☐ សម្របសម្រួលតាមក្រុម<br>✓ បំផុសសិស្ស<br>✓ បង្កើនការប្រុងប្រយ័ត្ន<br>✓ សង្កេត និងតាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុម | |
| ☐ បញ្ចាំងវីដេអូ ( **ការធ្វើចំណែកថ្នាក់ស្លឹករុក្ខជាតិ** ) ឱ្យសិស្សសង្កេត និងផ្ទៀងផ្ទាត់ចម្លើយរបស់ពួកគេ | ☐ មើលវីដេអូ និងផ្ទៀងផ្ទាត់លទ្ធផល។ |

| | |
|---|---|
| ☐ ផ្ដល់គំរូរបាយការណ៍ពិសោធន៍ទៅសិស្ស (មានមួយចប់ទាំងលទ្ធផលនិងសន្និដ្ឋាន)។ | |
| **ក្រោយពិសោធន៍** (☑ Check List) | |
| **គ្រូ** | **សិស្ស** |
| ☐ ប្រមូលរបាយការណ៍ ឬសន្លឹកកិច្ចការនៃការសង្កេតស្លឹករុក្ខជាតិ<br>☐ **ការវាយតម្លៃ៖** គ្រូអាចឱ្យសិស្ស<br>☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>☐ ឆ្លើយសំណួរផ្ទាល់មាត់<br>☐ ធ្វើបទបង្ហាញជាក្រុម | ☐ សរសេររបាយការណ៍ ឬសន្លឹកកិច្ចការពិសោធន៍<br>☐ **កិច្ចការវាយតម្លៃ៖**<br>☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>☐ ឆ្លើយសំណួរផ្ទាល់មាត់<br>☐ ធ្វើបទបង្ហាញជាក្រុម |

## ១.៣- សន្លឹកកិច្ចការពិសោធន៍

### ប្រធានបទ៖ ការធ្វើចំណែកថ្នាក់ស្លឹករុក្ខជាតិ

### ១.៣.១- សេចក្តីផ្តើម




ស្លឹករុក្ខជាតិមាននាទីក្នុងការបណ្តុះឧស្ម័ន ផលិតនិងស្តុកអាហារបម្រុង ដើម្បីធានានូវការលូតលាស់របស់រុក្ខជាតិទាំងមូល។ ជាទូទៅស្លឹករុក្ខជាតិមានច្រើនសណ្ឋាន និងច្រើនទម្រង់ខុសៗគ្នាទៅតាមប្រភេទរុក្ខជាតិនីមួយៗ។ ស្លឹករុក្ខជាតិមានលក្ខណៈពិសេសមួយចំនួនដូចជា ទម្រង់ស្លឹក គែមស្លឹក ការតម្រៀបស្លឹក និងទ្រនុងស្លឹក។ តើយើងធ្វើចំណែកថ្នាក់ស្លឹករុក្ខជាតិដូចម្តេច?

### ១.៣.២- វត្ថុបំណង

- **វិជ្ជាសម្បទា** : បកស្រាយបានពីលក្ខណៈពិសេសទាំងបួននៃទម្រង់ខាងក្រៅរបស់ស្លឹករុក្ខជាតិតាមរយៈការសង្កេត និងពិភាក្សាក្រុមបានត្រឹមត្រូវ។
- **បំណិនសម្បទា** : ធ្វើចំណែកថ្នាក់ស្លឹករុក្ខជាតិទៅតាមក្រុមលក្ខណៈពិសេសនីមួយៗតាមរយៈការសង្កេតស្លឹករុក្ខជាតិ និងពិភាក្សាក្រុមបានច្បាស់លាស់។
- **ចរិយាសម្បទា** : បង្កើតទម្លាប់ក្នុងការសង្កេត និងធ្វើចំណែកថ្នាក់ស្លឹករុក្ខជាតិ។

### ១.៣.៣- វិធីសាស្ត្រ

#### ក- សម្ភារៈ

| | | | | |
|---|---|---|---|---|
|  |  |  |  |  |
| ១. ស្លឹករុក្ខជាតិស្រស់មួយចំនួន | ២. ផ្ទាំងក្រដាស $A_0$ | ៣. ស្កុត | ៤. ហ្វឺតសរសេរ | ៥. កន្ត្រៃ |

#### ខ- ដំណើរការ

១- យកស្លឹករុក្ខជាតិស្រស់មួយចំនួន (ស្លឹករុក្ខជាតិច្រើនប្រភេទកាន់តែល្អ) មកធ្វើចំណែកថ្នាក់។

២- លាតក្រដាស $A_0$ រួចគូសតារាង និងសរសេរដូចរូបនេះ។




៣- ធ្វើចំណែកថ្នាក់ស្លឹករុក្ខជាតិទាំងអស់មួយលក្ខណៈម្តងៗ (១)ទម្រង់ស្លឹក (២) គែមស្លឹក (៣) ការតម្រៀបរបស់ស្លឹក និង(៤)ទ្រនុងស្លឹកដូចក្នុងរូប។

៤- យកស្លឹករុក្ខជាតិទាំងអស់មកសង្កេត និងធ្វើចំណាត់ថ្នាក់ទៅតាមទម្រង់តួស្លឹក (ស្លឹកទោល និងស្លឹកសមាស)។

៥- បន្ទាប់ពីបានធ្វើចំណាត់ថ្នាក់ទៅលើទម្រង់តួស្លឹករុក្ខជាតិទាំងនោះរួចហើយ ត្រូវពិនិត្យទៅលើគែមស្លឹកវិញម្តង ដោយបែងចែកទៅតាមលក្ខណៈគែមដូចជា គែមពេញ គែមធ្មេញ និងគែមឆក។

៦- យើងសង្កេតសារជាថ្មីម្តងទៀតទៅលើស្លឹករុក្ខជាតិទាំងនោះ ដោយផ្តោតទៅលើការតម្រៀបស្លឹក (ស្លឹកឆ្លាស់ ស្លឹកឈម និងស្លឹកកញ្ចុំ)។

៧- សង្កេតពីលក្ខណៈទ្រនុងស្លឹក ដែលមានទ្រនុងរាងស្និត ទ្រនុងរាងស្រប និងទ្រនុងរាងកង្ហារ។

**គ- លទ្ធផល និងវិភាគ**

ចូរបំពេញឈ្មោះស្លឹករុក្ខជាតិនៅក្នុងតារាងលទ្ធផលខាងក្រោម៖

| **លក្ខណៈរបស់ស្លឹករុក្ខជាតិ** | | **ចំនួន** | **ឈ្មោះស្លឹករុក្ខជាតិ** |
|---|---|---|---|
| ទម្រង់តួស្លឹក | ទោល | | |
| | សមាស | | |
| គែមស្លឹក | ពេញ | | |
| | ធ្មេញ | | |
| | ឆក | | |
| តម្រៀបស្លឹក | ឆ្លាស់ | | |
| | ឈម | | |
| | កញ្ចុំ | | |
| ទ្រនុងស្លឹក | ស្និត | | |
| | ស្រប | | |
| | កង្ហារ | | |

**ឃ- វិភាគ**

១- តើស្លឹករុក្ខជាតិមានទម្រង់ដូចម្ដេចខ្លះ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

២- តើគែមស្លឹករុក្ខជាតិមានលក្ខណៈដូចម្ដេចខ្លះ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៣- តើការតម្រៀបរបស់ស្លឹករុក្ខជាតិមានលក្ខណៈដូចម្ដេចខ្លះ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៤- តើទ្រនុងស្លឹករុក្ខជាតិមានរាងដូចម្ដេចខ្លះ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

**ខ- សន្និដ្ឋាន**

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

**ឆ- សំណួរពង្រីកចំណេះដឹង**

១- តើការសិក្សាពីចំណែកថ្នាក់ស្លឹករុក្ខជាតិបានផ្តល់ចំណេះដឹងអ្វីខ្លះដល់ប្អូនៗ?

២- ចូរប្អូនៗធ្វើចំណែកថ្នាក់រុក្ខជាតិដោយផ្អែកលើលក្ខណៈ ឫស ដើម ផ្កា និងគ្រាប់។

## ប្រធានបទទី២៖ សង្កេតទម្រង់ឆ្អឹងវែង (ឆ្អឹងភ្លៅគោ)

### ២.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូគប្បីអានសេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- អានបញ្ជីត្រួតពិនិត្យ (☑ Check List) ខាងក្រោមឱ្យបានយល់ច្បាស់។

២- ត្រៀមឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការពិសោធន៍ កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់។

៣- សាកល្បងអនុវត្តវះកាត់ឆ្អឹងឱ្យបានស្ទាត់ នៅមុនពេលថ្នាក់រៀនចាប់ផ្តើម។

៤- ផ្ញើវីដេអូ និងសន្លឹកកិច្ចការឱ្យសិស្សនៅមុនម៉ោងបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)។

៥- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោម៖

- ☐ ឱ្យសិស្សឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
- ☐ ឱ្យសិស្សឆ្លើយសំណួរផ្ទាល់មាត់
- ☐ ឱ្យសិស្សធ្វើបទបង្ហាញជាក្រុម
- ☐ ឱ្យសិស្សឆ្លើយសំណួរតាមកម្មវិធីវាយតម្លៃឌីជីថល (ឧទាហរណ៍៖ Kahoot, Quizizz, Blooket, Padlet...)។

*សូមចូលទៅកាន់វីដេអូពិសោធន៍តាមតំណភ្ជាប់នេះ*

## ២.២- បញ្ជីត្រួតពិនិត្យ ( ☑ Check List )

គ្រូ និងសិស្សត្រូវត្រៀមទៅតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ ក្នុងអំឡុងពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** ( ☑ Check List ) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក៤៖ ជីវវិទ្យាមនុស្ស<br>មេរៀនទី១៖ ប្រព័ន្ធគ្រោងឆ្អឹងទំព័រ៨៤-៨៩<br>☐ បានបង្រៀនរួចហើយ<br>**ប្រធានបទ៖ សង្កេតទម្រង់ឆ្អឹងវែង (ឆ្អឹងភ្លៅគោ)**<br>☐ ត្រៀមសម្ភារៈរួចរាល់រួមមាន ឆ្អឹងភ្លៅគោ រណារអារដែក ស្រោមដៃ ថាសក្រមួន ជ្រញ់ឈើ កូនកន្សែង កូនកាំបិត ប៉ាំង កែវពង្រីក និងក្រដាសជូតមាត់។<br>☐ បានត្រៀមសន្លឹកកិច្ចការសិស្សអំពីដំណើរការសង្កេតទម្រង់ឆ្អឹងវែង (ឆ្អឹងភ្លៅគោ) និងបានចែកឱ្យសិស្សរួចរាល់<br>☐ បានចែកវីដេអូអំពីដំណើរការសង្កេតទម្រង់ឆ្អឹងវែង (ឆ្អឹងភ្លៅគោ) ឱ្យសិស្សរួចរាល់<br>☐ បានត្រៀមសន្លឹកកិច្ចការឬកម្មវិធីវាយតម្លៃឌីជីថលរួចរាល់<br>☐ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទីសមាជិកក្រុមម្នាក់ៗច្បាស់លាស់ (ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។ | ☐ បានអានទ្រឹស្តីមេរៀនរួច<br>☐ បានរកសម្ភារៈគ្រប់គ្រាន់<br>☐ បានអាន និងយល់ពីដំណើរការនៅក្នុងសន្លឹកកិច្ចការដែលគ្រូបានចែកឱ្យ<br>☐ បានមើលវីដេអូអំពីដំណើរការសង្កេតទម្រង់ឆ្អឹងវែង (ឆ្អឹងភ្លៅគោ) រួចហើយ<br>☐ បានរៀបចំបង្កើតក្រុមនិងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់ |
| **ក្នុងអំឡុងពិសោធន៍** ( ☑ Check List ) | |
| **គ្រូ** | **សិស្ស** |
| ☐ រំឭកដំណើរការសង្កេតទម្រង់ឆ្អឹងវែង ដែលមាននៅក្នុងសន្លឹកកិច្ចការសិស្សឡើងវិញ<br>☐ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួចរាល់<br>☐ សម្របសម្រួលតាមក្រុម<br>– បំផុសសិស្ស<br>– បង្កើនការប្រុងប្រយ័ត្ន<br>– សង្កេត និងតាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុម<br>☐ ឱ្យសិស្សតាមក្រុមនីមួយៗសរសេររបាយការណ៍មេរៀននៅក្នុងសន្លឹកកិច្ចការសិស្ស។ | ☐ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>☐ សង្កេត ពិភាក្សា និងកត់ត្រា<br>☐ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ។<br>☐ បោសសម្អាតបន្ទប់<br>☐ អាន និងស្វែងយល់បន្ថែម<br>☐ សរសេររបាយការណ៍មេរៀននៅក្នុងសន្លឹកកិច្ចការដែលគ្រូបានចែកឱ្យបានត្រឹមត្រូវ។ |
| **ក្រោយពិសោធន៍** ( ☑ Check List ) | |
| **គ្រូ** | **សិស្ស** |
| ☐ ប្រមូលសន្លឹកកិច្ចការសង្កេតទម្រង់ឆ្អឹងវែង | ☐ ប្រគល់សន្លឹកកិច្ចការឱ្យគ្រូ |

| | |
|---|---|
| □ **ការវាយតម្លៃ៖** គ្រូអាចឱ្យសិស្ស<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ធ្វើបទបង្ហាញ<br>□ ឆ្លើយសំណួរនៅក្នុងកម្មវិធីវាយតម្លៃឌីជីថល (ឧទាហរណ៍៖ Kahoot, Quizizz, Blooket, Padlet...)។ | □ **កិច្ចការវាយតម្លៃ៖**<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ធ្វើបទបង្ហាញជាក្រុម<br>□ ឆ្លើយសំណួរនៅក្នុងកម្មវិធីវាយតម្លៃឌីជីថល (ឧទាហរណ៍៖ Kahoot, Quizizz, Blooket, Padlet...)។ |

## ២.៣- សន្លឹកកិច្ចការពិសោធន៍

### ប្រធានបទ៖ សង្កេតទម្រង់ឆ្អឹងវែង (ឆ្អឹងភ្លៅគោ)

### ២.៣.១- សេចក្តីផ្តើម




ឆ្អឹងជាសរីរាង្គរឹង មាននាទីកំណត់រូបរាង ទ្រទ្រង់សារពាង្គកាយ ធ្វើឱ្យមានចលនា ការពារសរីរាង្គក្នុង ការផលិតកោសិកាឈាម ស្តុកទុកសារជាតុខនិជ និងសារជាតុផ្សេងៗទៀតពេលសារពាង្គកាយត្រូវការ។ នៅក្នុងសារពាង្គ-កាយថនិកសត្វមានឆ្អឹងសំប៉ែត ឆ្អឹងខ្លី និងឆ្អឹងវែងជាដើម។ ឆ្អឹងដើមដៃ ឆ្អឹងកំភួនដៃ ឆ្អឹងកំភួនជើង និងឆ្អឹងភ្លៅជាប្រភេទឆ្អឹងវែង។

តើទម្រង់ខាងក្រៅ និងទម្រង់ខាងក្នុងរបស់ឆ្អឹងវែងមានលក្ខណៈដូចម្តេច?

### ២.៣.២- វត្ថុបំណង

- **វិជ្ជាសម្បទា** : ពន្យល់ពីទម្រង់ខាងក្រៅ និងខាងក្នុងរបស់ឆ្អឹងវែងបានច្បាស់លាស់តាមរយៈការវះឆ្អឹងភ្លៅគោនិងការពិភាក្សាក្រុម។
- **បំណិនសម្បទា** : វិភាគពីលក្ខណៈផ្សេងៗនៃផ្នែកនីមួយៗរបស់ឆ្អឹងវែងបានត្រឹមត្រូវតាមរយៈការសង្កេត។
- **ចរិយាសម្បទា** : ប្រុងប្រយ័ត្នពីការប៉ះទង្គិចឆ្អឹងជាមួយវត្ថុរឹង និងថែទាំឆ្អឹងឱ្យរឹងមាំតាមរយៈរបបអាហារត្រឹមត្រូវ។

### ២.៣.៣- វិធីសាស្ត្រ

#### ក- សម្ភារៈ

| | | | | |
|---|---|---|---|---|
|  ១. ឆ្អឹងភ្លៅគោ |  ២. រណាអារដែក |  ៣. ស្រោមដៃពេទ្យ |  ៤. ថាសក្រមួន |  ៥. ជ្រញ់ឈើ |
|  ៦. កូនកន្សែង |  ៧. ប៉ាំង |  ៨. កូនកាំបិត |  ៩. កែវពង្រីក |  ១០. ក្រដាសជូតមាត់ |

#### ខ- ដំណើរការ

១- បង្ហាញ និងសង្កេតទម្រង់ខាងក្រៅរបស់ឆ្អឹងភ្លៅគោ។

២- ចៀរសាច់ជាប់ឆ្អឹង និងសរសៃចេញ រួចជូតឱ្យស្អាត។

៣- បង្ហាញ និងសង្កេតទម្រង់ខាងក្រៅរបស់ឆ្អឹងវែងទាំងមូលម្តងទៀត។

៤- អារឆ្អឹងតាមបណ្ដោយចេញពីក្បាលឆ្អឹង រហូតដល់កណ្ដាលតួឆ្អឹង រួចអារទទឹង ហើយយកឆ្អឹងដែលបាន អារដាច់នោះចេញ។

៥- ប្រសិនបើឆ្អឹងវែងដែលត្រូវសង្កេតប្រឡាក់កម្ទេចកម្ទីឆ្អឹង យើងត្រូវយកឆ្អឹងវែងនោះទៅលាងទឹកឱ្យស្អាត (ត្រូវប្រយ័ត្នកុំឱ្យបែកខួរឆ្អឹង)។

៦- សង្កេតលក្ខណៈផ្សេងៗនៃផ្នែកនីមួយៗក្នុងឆ្អឹងវែងដោយភ្នែកទទេ (ដើម្បីសង្កេតលក្ខណៈលម្អិតខាងក្នុងរបស់ឆ្អឹងឱ្យកាន់តែច្បាស់ យើងត្រូវប្រើកែវពង្រីកជាជំនួយ)។

៧- ឆ្កឹះយកខួរឆ្អឹងនៅក្នុងតួឆ្អឹងវែងមកពិនិត្យលម្អិត (ដោយភ្នែកទទេ និងកែវពង្រីកជាជំនួយ)។

**គ- លទ្ធផល និងវិភាគ**

– **លទ្ធផល**

ចូរគូររូបពីទម្រង់ឆ្អឹងភ្លៅគោ និងដាក់ឈ្មោះផ្នែកផ្សេងៗឱ្យបានត្រឹមត្រូវ។

| | |
|---|---|
| **រូបឆ្អឹងភ្លៅគោផ្នែកខាងក្រៅ** | **រូបឆ្អឹងភ្លៅផ្នែកខាងក្នុង** |

– **វិភាគ**

១- តើទម្រង់ឆ្អឹងវែងមានលក្ខណៈដូចម្ដេច?

.........................................................................................................................................

.........................................................................................................................................

.........................................................................................................................................

.........................................................................................................................................

.........................................................................................................................................

២- ចូររៀបរាប់ឱ្យបានលម្អិតពីផ្នែកនីមួយៗរបស់ឆ្អឹងវែង។

.........................................................................................................................................

.........................................................................................................................................

.........................................................................................................................................

.........................................................................................................................................

.........................................................................................................................................

៣- ក្រោយពីបានសង្កេតទៅលើទម្រង់ឆ្អឹងវែង តើយើងត្រូវធ្វើដូចម្ដេច ដើម្បីថែរក្សាឆ្អឹងឱ្យមានសុខភាពល្អ?

.........................................................................................................................................

.........................................................................................................................................

.....................................................................................................................................................................................

.....................................................................................................................................................................................

.....................................................................................................................................................................................

.....................................................................................................................................................................................

**ឃ- សន្និដ្ឋាន**

.....................................................................................................................................................................................

.....................................................................................................................................................................................

.....................................................................................................................................................................................

.....................................................................................................................................................................................

.....................................................................................................................................................................................

.....................................................................................................................................................................................

**ខ- សំណួរពង្រីកចំណេះដឹង**

១- ចូរប្អូនសង្កេតពីទម្រង់របស់ឆ្អឹងផ្សេងៗទៀតក្រៅពីឆ្អឹងវែង។

២- តើអាហារប្រភេទណាខ្លះ ដែលជួយដល់ការលូតលាស់របស់ឆ្អឹង និងជួយឱ្យឆ្អឹងរឹងមាំល្អ?

៣- តើយើងត្រូវធ្វើដូចម្តេចខ្លះ ដើម្បីចៀសវាងពីជំងឺពុកឆ្អឹង?

## ប្រធានបទទី៣៖ ការផលិតជីកំប៉ុស្តទឹក

### ៣.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្មនិងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូត្រូវអាន សេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- អានបញ្ជីត្រួតពិនិត្យ (☑ Check List) ខាងក្រោមឱ្យបានយល់ច្បាស់។

២- រៀបឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធ សន្លឹកកិច្ចការពិសោធន៍កិច្ចតែង ការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់។

៣- សាកល្បងអនុវត្តធ្វើជីកំប៉ុស្តទឹកនៅមុនពេលថ្នាក់រៀនចាប់ផ្តើម។

៤- ឱ្យសិស្សមើលវីដេអូអំពីការផលិតជីកំប៉ុស្តទឹកនេះ និងឱ្យពួកគេស្រាវជ្រាវពីរបៀបផ្សេងៗទៀតនៃការផលិត ជីកំប៉ុស្តទឹក ដើម្បីពួកគាត់ធ្វើការផលិតជីនេះតាមក្រុមនីមួយៗ។

៥- គ្រូអាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១) ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ឬក្រៅថ្នាក់ធម្មតា និង (២) ជាការសិក្សាបែបគម្រោង។

៦- ក្នុងករណី (១) ថ្នាក់រៀនបែបសកម្មធម្មតា គ្រូត្រូវផ្ញើវីដេអូ និងសន្លឹកកិច្ចការសិស្សឱ្យសិស្សនៅមុនម៉ោង បង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)។

៧- ក្នុងករណី (២) ជាការសិក្សាបែបគម្រោង គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទី និងរយៈពេល ឱ្យបានច្បាស់លាស់។ ចំពោះវីដេអូពិសោធ ត្រូវបង្ហាញនៅពេលបន្ទាប់ពីក្រុមនីមួយៗធ្វើបទបង្ហាញលទ្ធផល នៃការសិក្សាបែបគម្រោងរបស់ពួកគេ។

៨- ឱ្យសិស្សអនុវត្តធ្វើជីកំប៉ុស្តទឹកនេះឱ្យបានយ៉ាងហោចណាស់មួយខែមុនថ្ងៃត្រូវឡើងធ្វើបទបង្ហាញនៅក្នុងថ្នាក់។

៩- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោម៖

- ☐ ឱ្យសិស្សឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
- ☐ ឱ្យសិស្សឆ្លើយសំណួរផ្ទាល់មាត់
- ☐ ឱ្យសិស្សធ្វើបទបង្ហាញជាក្រុម។

១០- ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាមិនគ្រប់គ្រាន់នៅក្នុង ម៉ោងបង្រៀន។

*សូមចូលទៅកាន់វីដេអូពិសោធន៍តាមតំណភ្ជាប់នេះ*

### ៣.២- បញ្ជីត្រួតពិនិត្យ ( ☑ Check List )

គ្រូនិងសិស្សត្រូវត្រៀមទៅតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ ក្នុងអំឡុងពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** ( ☑ Check List ) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក៥៖ ដីវិទ្យាក្នុងវិស័យកសិកម្ម មេរៀនទី១ ដី ទំព័រ៩៨-១០៥<br>☑ បានបង្រៀនរួចហើយ<br>**ប្រធានបទ៖ ការផលិតជីកំប៉ុស្តទឹក**<br>☐ ចែកសិស្សជាក្រុមតូចៗក្នុងមួយក្រុមអាចមានសមាជិកពី៤ទៅ៦នាក់<br>☐ បានចែកសន្លឹកកិច្ចការពិសោធន៍និងវីដេអូអំពីការផលិតជីកំប៉ុស្តទឹកឱ្យសិស្សរួចហើយ<br>☐ ឱ្យសិស្សតាមក្រុមស្រាវជ្រាវមើលការផលិតជីកំប៉ុស្តទឹកពីប្រភពផ្សេងៗ<br>☐ ឱ្យសិស្សតាមក្រុមប្រមូលសម្ភារៈសម្រាប់ផលិតជីកំប៉ុស្តទឹកនិងថតវីដេអូ<br>☐ ឱ្យសិស្សបំពេញសន្លឹកកិច្ចការ<br>☐ ឱ្យសិស្សតាមក្រុមនីមួយៗសរសេររបាយការណ៍នៃការផលិតជីកំប៉ុស្តទឹក។ | ☐ បានអានទ្រឹស្តីមេរៀន<br>☐ បានចូលតាមក្រុមតូចៗ<br>☐ បានមើលនិងស្វែងយល់ពីវីដេអូអំពីការជីកំប៉ុស្តទឹក<br>☐ បានស្រាវជ្រាវបន្ថែម<br>☐ ប្រមូលសម្ភារៈដែលត្រូវការសម្រាប់ការផលិតជីកំប៉ុស្តទឹកនិងថតរាល់សកម្មភាពនានាសម្រាប់ធ្វើបទបង្ហាញ<br>☐ បំពេញសន្លឹកកិច្ចការ<br>☐ សរសេររបាយការណ៍នៃការផលិតជីកំប៉ុស្តទឹកតាមក្រុម។ |

| **ក្នុងអំឡុងពិសោធន៍** ( ☑ Check List ) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ រំឭកដំណើរការផលិតជីកំប៉ុស្តទឹកឡើងវិញ<br>☐ ឱ្យសិស្សតាមក្រុមនីមួយៗឡើងធ្វើបទបង្ហាញ<br>☐ គ្រូសម្របសម្រួលនិងអាចធ្វើការប្រៀនធៀបលទ្ធផលតាមក្រុមនីមួយៗ។ | ☐ ឡើងឆ្លើយ<br>☐ ឡើងធ្វើបទបង្ហាញ<br>☐ កត់ត្រា ផ្ទៀងផ្ទាត់ |

| **ក្រោយពិសោធន៍** ( ☑ Check List ) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ប្រមូលរបាយការណ៍ការផលិតជីកំប៉ុស្តទឹក និងដាក់ពិន្ទុ<br>☐ ប្រមូលសន្លឹកកិច្ចការ | ☐ តាមក្រុមនីមួយៗប្រគល់របាយការណ៍ឱ្យគ្រូ<br>☐ ប្រគល់សន្លឹកកិច្ចការឱ្យគ្រូ |

## ៣.៣- សន្លឹកកិច្ចការពិសោធន៍

### ប្រធានបទៈ ការផលិតជីកំប៉ុស្តទឹក

### ៣.៣.១- សេចក្តីផ្តើម

ជីមានសារៈសំខាន់ណាស់សម្រាប់ផ្តល់សារៈធាតុចិញ្ចឹមដល់ការលូតលាស់របស់រុក្ខជាតិ។ ជីមាន២ប្រភេទ ជីគីមី និងជីធម្មជាតិ។ ជីកំប៉ុស្តជាប្រភេទមួយនៃជីធម្មជាតិ ដែលផ្តល់សារធាតុចិញ្ចឹមបានល្អជួយដល់ការលូតលាស់ដំណាំកសិកម្មតាមបែបធម្មជាតិដែលមិនធ្វើឱ្យខូចគុណភាពដី។

ជីកំប៉ុស្តត្រូវបានផលិតឡើងដោយមានការលាយបញ្ចូលគ្នាលាមកសត្វ និងកាកសំណល់របស់រុក្ខជាតិដែលត្រូវបានបំបែកដោយមីក្រូសារពាង្គកាយ។ ជីកំប៉ុស្តមានពីរប្រភេទគឺជីកំប៉ុស្តទឹក និងជីកំប៉ុស្តគោក។ តើជីកំប៉ុស្តទឹកត្រូវបានផលិតឡើងដូចម្តេច?

### ៣.៣.២- វត្ថុបំណង

- **វិជ្ជាសម្បទា :** រៀបរាប់ពីវិធីធ្វើជីកំប៉ុស្តទឹកបានត្រឹមត្រូវតាមរយៈការអនុវត្តជាក់ស្តែង។
- **បំណិនសម្បទា :** ផលិត និងប្រើប្រាស់ជីកំប៉ុស្តទឹកបលើដំណាំបានត្រឹមត្រូវតាមរយៈការអនុវត្តជាក់ស្តែង។
- **ចរិយាសម្បទា :** មានទម្លាប់ប្រើប្រាស់ជីកំប៉ុស្តទឹកលើដំណាំបានត្រឹមត្រូវ ដើម្បីផ្តល់នូវសុខសុវត្ថិភាពចំណីអាហារ និងសុខភាពល្អក្នុងការរស់នៅប្រចាំថ្ងៃក្នុងសហគមន៍។

### ៣.៣.៣- វិធីសាស្ត្រ

**ក- សម្ភារៈ**

| | | |
|---|---|---|
|  |  |  |
| ១. ស្លឹករុក្ខជាតិស្រស់២គីឡូក្រាម | ២. លាមកគោ មាន់ ទា (១គីឡូក្រាម) | ៣. ធុងជ័រចំណុះ១៦០លីត្រ |
|  |  |  |
| ៤. ការ៉ុងចំណុះ៥០គីឡូក្រាម | ៥. ដុំថ្ម | ៦. ឈើវែង (១.៥ម៉ែត្រ) |

**ខ- ដំណើរការ**

១- ច្រកស្លឹកឈើ និងលាមកសត្វចូលក្នុងការ៉ុងដោយវាស់បរិមាណឱ្យបានច្បាស់លាស់។

២- ដាក់បាវដែលបានច្រកស្លឹកឈើ និងលាមកសត្វទៅក្នុងធុងជ័រ រួចដាក់ដុំថ្មសង្កត់ពីលើ។

៣- ចាក់ទឹកចំណុះ២០ដងនៃបាវស្លឹកឈើនិងលាមកសត្វចូលក្នុងធុង(ឧទាហរណ៍ ប្រសិនបើយើងច្រកស្លឹកឈើ និងលាមកសត្វមួយប៉ោតចូលក្នុងការ៉ុង យើងត្រូវប្រើទឹក២០ប៉ោតចាក់ចូលទៅក្នុងធុង)។

៤- គ្របធុងជីឱ្យបានល្អ។

៥- យកឈើវែងកូរល្បាយក្នុងធុងរៀងរាល់ថ្ងៃ (មួយថ្ងៃកូរពីរដង) ដោយបង្វិលទៅបង្វិលមកឱ្យបាន១០ដង។

៦- រក្សាទុកជីកំប៉ុស្តទឹករយៈពេលបីសប្តាហ៍ (យ៉ាងតិច) ឬរហូតជីលែងមានក្លិនស្អុយទើបអាចប្រើប្រាស់វាបាន។

**គ- លទ្ធផល និងវិភាគ**

**– លទ្ធផល**

ចូរកត់ត្រាពីបម្រែបម្រួលលក្ខណៈរបស់ជីកំប៉ុស្តទឹកក្នុងតារាងខាងក្រោម៖

| រយៈពេល | លក្ខណៈជីកំប៉ុស្តទឹក |
|---|---|
| ១សប្តាហ៍ | |
| ២សប្តាហ៍ | |
| ៣សប្តាហ៍ | |

**– វិភាគ**

១- ហេតុអ្វីបានជាយើងត្រូវផ្អាប់ស្លឹករុក្ខជាតិ និងលាមកសត្វដោយត្រាំក្នុងទឹករយៈយ៉ាងតិចពេល៣សប្តាហ៍?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

២- ហេតុអ្វីបានជាយើងត្រូវកូរទឹកជីមួយថ្ងៃ២ដង?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៣- ហេតុអ្វីយើងត្រូវគ្របជីកំប៉ុស្តទឹកឱ្យបានជិតល្អ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

**ឃ- សន្និដ្ឋាន**

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

**ង- សំណួរពង្រីកចំណេះដឹង**

១- តើយើងប្រើប្រាស់ជីកំប៉ុស្តទឹកដូចម្តេច?

២- ចូរផលិតជីកំប៉ុស្តប្រភេទផ្សេងៗទៀត ក្រៅពីការពីជីកំប៉ុស្តទឹក។

## ប្រធានបទទី៤៖ របៀបបន្តពូជ និងបង្កាត់រុក្ខជាតិដោយឥតភេទ (ការសាកមែក និងការតដើម )

### ៤.១- សេចក្ដីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការនៃដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូត្រូវអានសេចក្ដីណែនាំខ្លីដូចខាងក្រោម៖

១- អានបញ្ជី (☑ Check List) ខាងក្រោមឱ្យបានយល់ច្បាស់។

២- រៀប ឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការពិសោធន៍ កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់។

៣- សាកល្បងអនុវត្តពីរបៀបបន្តពូជ និងបង្កាត់រុក្ខជាតិដោយឥតភេទ នៅមុនពេលថ្នាក់រៀនចាប់ផ្ដើម។

៤- អាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១) ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ឬក្រៅថ្នាក់ធម្មតា និង(២) ជាការសិក្សាបែបគម្រោង។

៥- ក្នុងករណី (១) ថ្នាក់រៀនបែបសកម្មធម្មតា គ្រូត្រូវផ្ញើវីដេអូ និងសន្លឹកកិច្ចការពិសោធន៍ឱ្យសិស្សនៅមុនម៉ោងបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)។

៦- ក្នុងករណី (២) ជាការសិក្សាបែបគម្រោង គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទី និងរយៈពេលឱ្យបានច្បាស់លាស់។ ចំពោះវីដេអូពិសោធន៍ ត្រូវបង្ហាញនៅពេលបន្ទាប់ពីក្រុមនីមួយៗធ្វើបទបង្ហាញលទ្ធផលនៃការសិក្សាបែបគម្រោងរបស់ពួកគេ។

៧- ឱ្យសិស្សអនុវត្តធ្វើរបៀបបន្តពូជ និងបង្កាត់រុក្ខជាតិដោយឥតភេទនេះ ឱ្យបានយ៉ាងហោចណាស់១ខែមុនថ្ងៃត្រូវឡើងធ្វើបទបង្ហាញនៅក្នុងថ្នាក់។

៨- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោម៖

☐ ឱ្យសិស្សឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ

☐ ឱ្យសិស្សឆ្លើយសំណួរផ្ទាល់មាត់

☐ ឱ្យសិស្សធ្វើបទបង្ហាញជាក្រុម។

*សូមចូលទៅកាន់វីដេអូពិសោធន៍តាមតំណភ្ជាប់នេះ*

### ៤.២- បញ្ជីត្រួតពិនិត្យ ( ☑ Check List )

គ្រូ និងសិស្សត្រូវត្រៀមទៅតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ ក្នុងអំឡុងពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** ( ☑ Check List ) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក៥៖ ជីវវិទ្យាក្នុងវិស័យកសិកម្ម មេរៀនទី២៖ ការបង្កាត់ ទំព័រ១០៦-១១១<br>☐ បានបង្រៀនរួចហើយ<br>**ប្រធានបទ៖** របៀបបន្តពូជ និងបង្កាត់រុក្ខជាតិដោយឥតភេទ ( ការសាកមែក និងការតដើម )<br>☐ សម្ភារៈបានរៀបចំរួចរាល់រួមមាន៖ ស្រកីដូង ខ្សែចង ដីល្បាប់ ស្រោមដៃ កន្ត្រៃកាត់មែកឈើ កូនកាំបិតមែកស្វាយ កូនទុរេន ថង់ប្លាស្ទិច<br>☐ បានផលិតឯកសារអំពីរបៀបបន្តពូជ និងបង្កាត់រុក្ខជាតិដោយឥតភេទ ( ការសាកមែក និងការតដើម ) សម្រាប់សិស្ស និងបានចែកឱ្យសិស្សរួចជាស្រេច<br>☐ បានផលិតវីដេអូអំពីរបៀបបន្តពូជ និងបង្កាត់រុក្ខជាតិដោយឥតភេទ ( ការសាកមែក និងការតដើម )<br>☐ សន្លឹកកិច្ចការវាយតម្លៃត្រូវបានបែងចែកឱ្យសិស្សរួចរាល់<br>☐ គ្រូបានបែងចែកក្រុម និងបានកំណត់តួនាទីសមាជិកម្នាក់ៗបានច្បាស់លាស់ ( សមាជិកអាចពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង ) តែក្នុងនោះសមាជិក៣នាក់ត្រៀមរួចរាល់សម្រាប់ការងារប្រតិបត្តិ។ | ☐ បានអាន និងរៀនទ្រឹស្តីមេរៀន<br>☐ បានអាន និងយល់ពីដំណើរការ ដែលគ្រូបានចែកឱ្យ<br>☐ បានរកសម្ភារៈគ្រប់គ្រាន់<br>☐ ទទួលបានសន្លឹកកិច្ចការវាយតម្លៃរួចហើយ<br>☐ បានរៀបចំក្រុមនិងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់។ |
| **ក្នុងអំឡុងពិសោធន៍** ( ☑ Check List ) | |
| **គ្រូ** | **សិស្ស** |
| ☐ ប្រមូលសន្លឹកកិច្ចការ និងរបាយការណ៍លទ្ធផលអំពីរបៀបបន្តពូជ និងបង្កាត់រុក្ខជាតិដោយឥតភេទ ( ការសាកមែក និងការតដើម )<br>☐ **ការវាយតម្លៃ៖ គ្រូអាចឱ្យសិស្ស**<br>☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>☐ ធ្វើបទបង្ហាញលទ្ធផលនៃការសិក្សា | ☐ ប្រគល់សន្លឹកកិច្ចការពិសោធន៍ឱ្យគ្រូ<br>☐ **កិច្ចការវាយតម្លៃ៖**<br>☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>☐ ធ្វើបទបង្ហាញជាក្រុម |
| **ក្រោយពិសោធន៍** ( ☑ Check List ) | |
| **គ្រូ** | **សិស្ស** |
| ☐ ប្រមូលរបាយការណ៍លទ្ធផលអំពីរបៀបបន្តពូជ និងបង្កាត់រុក្ខជាតិដោយឥតភេទ( ការសាកមែក និង ការតដើម ) និងដាក់ពិន្ទុ | ☐ ប្រគល់របាយការណ៍លទ្ធនៃការសិក្សាបែបគម្រោង។ |

| | |
|---|---|
| □ វាយតម្លៃមួយដោយផ្អែកលើការធ្វើបទបង្ហាញរបស់ក្រុមសិស្សនីមួយៗ។ | |

## ៤.៣- សន្លឹកកិច្ចការពិសោធន៍

### ប្រធានបទ៖ របៀបបន្តពូជ និងបង្កាត់រុក្ខជាតិដោយឥតភេទ(ការសាកមែក និងការតដើម)

### ៤.៣.១- សេចក្តីផ្តើម

នៅក្នុងវិស័យកសិកម្ម ការបង្កាត់រុក្ខជាតិដោយឥតភេទ ត្រូវបានអនុវត្តយ៉ាងទូលំទូលាយ ដើម្បីផលិតកសិផលប្រកបដោយគុណភាព សុវត្ថិភាព និងបរិមាណសម្រាប់ការផ្គត់ផ្គង់នៅលើទីផ្សារ។ ក្រៅពីដំណុះដំណាលដោយគ្រាប់រុក្ខជាតិក៏មានការបន្តពូជដោយឥតភេទផងដែរ តាមរបៀបផ្សេងៗរួមមានការសាកមែក(ផ្សាំ) ការតភ្នែក(ពន្លកក្លៀង) និងការភ្ជាប់ដើមដែលហៅថាការបន្តពូជដោយលូតលាស់សិប្បនិម្មិត។ ការសាកមែកបានជួយឱ្យការដាំដុះរុក្ខជាតិហូបផ្លែទទួលបានផលក្នុងរយៈពេលខ្លីជាងកាដាំដុះដោយគ្រាប់។ អ្នកបច្ចេកទេសកសិកម្មបានជ្រើសរើសពូជរុក្ខជាតិហូបផ្លែដែលមានភាពធន់ទៅនឹងអាកាសធាតុ ឈ្មះជំងឺ សម្រាប់ធ្វើជាដើមទម្រ ហើយយកមែករុក្ខជាតិហូបផ្លែពូជផ្សេង ដែលផ្លែច្រើនរសជាតិឆ្ងាញ់ឆាប់ទទួលបានផល ធ្វើជាផ្នែកចុង។

តើយើងធ្វើដូចម្តេច ដើម្បីសាកមែក និងតដើមរុក្ខជាតិឱ្យទទួលបានលទ្ធផលល្អ?

### ៤.៣.២- វត្ថុបំណង

- **វិជ្ជាសម្បទា :** រៀបរាប់ពីរបៀបតដើមនិងសាកមែកបានត្រឹមត្រូវតាមរយៈការសង្កេត។
- **បំណិនសម្បទា :** វិភាគពីកត្តាផ្សេងៗដែលអាចឱ្យរុក្ខជាតិដុះឫសត្រង់កន្លែងសាកតាមរយៈការតាមដាននិងថែទាំ។
- **ចរិយាសម្បទា :** មានទំលាប់ក្នុងការបង្កាត់រុក្ខជាតិដោយឥតភេទដោយការអនុវត្តក្នុងវិស័យកសិកម្មនៅក្នុងសហគមន៍។

### ៤.៣.៣- វិធីសាស្រ្ត

#### ក- សម្ភារៈ

| | | | | |
|---|---|---|---|---|
|  ១. ស្រកីដូង |  ២. កូនស្វាយ |  ៣. កូនក្រូចឆ្មា |  ៤. មែកស្វាយពូជផ្សេង |  ៥.កន្ត្រៃកាត់មែកឈើ |
|  ៦. កាំបិតចៀរ |  ៧. ស្រោមដៃ |  ៨. ខ្សែហ្វ៊ីប |  ៩. ដីកំប៉ុស្ត ឬដីល្បាយ |  ១០. ថង់ផ្លាស្ទិក |
|  ១១. កាំបិតកាត់សំបក |  ១២. កូនប៉ែល |  ១៣. ប្លាស្ទិករុំ | | |

**ខ- ដំណើរការ**

- គ្រូបង្ហាញសម្ភារៈមួយចំនួនសម្រាប់ការសាកមែកនិងការតដើមនៅទីតាំងដែលត្រូវសាកមែកនិងតដើម ឬក្នុងសួនកសិកម្មសាលារៀន។
- បន្ទាប់មកអនុវត្តការសាកមែកនិងតដើម។

**វិធីសាកមែកៈ**

១- ជ្រើសរើសមែកក្រូចណាដែលមានសុខភាពល្អ គ្មានជំងឺ។

២- យកកន្ត្រៃកាត់មែកផ្សេងៗដែលមិនត្រូវការចោល បន្ទាប់មកយកកូនកាំបិតដែលមុតល្អចៀរសំបកជុំវិញមែកក្រូចប្រវែងប្រហែល៣ទៅ៤សង់ទីម៉ែត្រ។

៣- យកកូនកាំបិតកោសអំបិលឈើឱ្យអស់ និងស្អាតល្អ។

៤- យកដីដែលមានជីជាតិល្អ (ដីកំប៉ុស្ត) ដាក់ក្នុងស្រកីដូងរួចយកទៅផ្តោបជុំវិញមែកស្វាយត្រង់កន្លែងដែលបានចៀរសំបក រួចយកខ្សែហ្វ៊ីបចងផ្នែកសងខាង និងផ្នែកកណ្តាលស្រកីដូងឱ្យបានតឹងល្មម។

៥- ស្រោចទឹកជារៀងរាល់ថ្ងៃ (២ដងក្នុងមួយថ្ងៃក្នុងករណីមេឃក្តៅខ្លាំង) រហូតមែកស្វាយនោះមានដុះឫសពណ៌ត្នោតចេញផុតមកក្រៅស្រកីដូង ទើបអាចកាត់យកទៅដាំនៅមជ្ឈដ្ឋានថ្មីបាន។

**វិធីតដើមៈ**

១- ជ្រើសរើសកូនស្វាយ (កូនដែលបានមកពីការបណ្តុះគ្រាប់) មានសុខភាពល្អមកកាត់ផ្នែកខាងចុងចេញដោយទុកតែផ្នែកគល់ (ប្រវែងប្រហែល១០ទៅ១៥សង់ទីម៉ែត្រ) សម្រាប់ធ្វើជាដើមទម្រ។

២- ចិតគល់កូនស្វាយរាងជាអក្សរវេ (V) ធ្វើជាដើមទម្រ។

៣- ជ្រើសរើសមែកស្វាយពូជផ្សេងមានសុខភាពល្អ និងបានចេញផ្កាផ្លែរួចហើយសម្រាប់តភ្ជាប់ជាមួយដើមទម្រ។

៤- កាត់យកមែកស្វាយមួយកំណាត់ (ប្រហែល៣ទៅ៤សង់ទីម៉ែត្រ) ដែលមានពន្លកមែក (ភ្នែកពន្លក) រួចចិតផ្នែកគល់មែកឱ្យស្រួចរាងជាអក្សរវេ (V) ធ្វើជាជន្លួញ។

៥- បន្ទាប់មកយកកំណាត់មែកស្វាយ(ជន្លួញ)ទៅស៊កចូលក្នុងគល់ដើមទម្រ។

៦- យកប្លាស្ទិចរុំលើមុខតំណរហូតផុតចុងមែកស្វាយឱ្យបានណែននិងជិតល្អ។

៧- យកថង់ប្លាស្ទិចស្រោបកន្លែងតដើមឱ្យបានជិតល្អ។

៨- រក្សាកូនស្វាយដែលបានតដើមរួចនៅក្នុងមជ្ឈដ្ឋានសមស្រប (កន្លែងដែលមានសំណើម និងពន្លឺថ្ងៃគ្រប់គ្រាន់)។

៩- ស្រោចទឹក និងថែទាំជាប្រចាំរហូតកូនស្វាយនោះដុះពន្លកថ្មី។

**គ- លទ្ធផល និងវិភាគ**

- **លទ្ធផល**

**ការសាកមែក**

១- តើឫសថ្មីដុះចេញពីកន្លែងណានៃមែកដែលបានសាកនោះ?

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

២- ហេតុអ្វីបានជាយើងត្រូវកាត់សំបកមែកក្រូចចេញ?

..............................................................................................................................................

..............................................................................................................................................

|---|---|---|---|---|
|  |  |  |  |  |
| ១១. ស្រោមដៃពេទ្យ | ១២. ហ្វឺតសរសេរ | ១៣. បន្ទះឡាម | ១៤. ឡាមែល | ១៥. កូនស្លាបព្រាជ័រ |

**ខ- ដំណើរការ**

**ដំណាក់កាលទី១៖**

រៀបចំសូលុយស្យុងអំបិលកំហាប់១៥% ដោយដាក់អំបិល១៥ក្រាមជាមួយទឹក៥០ ឬ៦០មីលីលីត្រ រួចកូរអំបិលឱ្យរលាយសព្វ បន្ទាប់មកបន្ថែមទឹកឱ្យគ្រប់១០០មីលីលីត្រ រួចកូរឱ្យសព្វម្តងទៀតជាការស្រេច។

**ដំណាក់កាលទី២៖**

- យកស្លឹកប្រទាលល័ក្តទៅលាងទឹក រួចជូតឱ្យស្អាត
- បកយកស្រទាប់កោសិកាអេពីឌែមរបស់ស្លឹកប្រទាលល័ក្តដែលមានពណ៌ក្រហមជាំឱ្យបានស្តើងបំផុត រួចដាក់លើបន្ទះឡាមដែលមានតំណក់ទឹក ហើយយកឡាម៉ែលគ្របពីលើសំណាកដោយលៃយ៉ាងណាកុំឱ្យមានពពុះខ្យល់ (គ្របឡាមែលតាមទម្រេតមុំ៤៥ដឺក្រេ)
- ពិនិត្យទម្រង់កោសិកាដោយប្រើអុបហ្ស៊ិកទីបលេខតូចបំផុត លេខធំបន្ទាប់ និងលេខធំបំផុត។

**ដំណាក់កាលទី៣៖**

- ដកទឹកចេញពីសំណាកលើបន្ទះឡាមដោយប្រើក្រដាសជូតមាត់ បន្ទាប់មកបន្តក់ស្យុងអំបិលមួយតំណក់លើសំណាកនៅលើបន្ទះឡាមនោះ
- រង់ចាំ៤ទៅ៥នាទី
- សង្កេតពីការប្រែប្រួលទំហំវ៉ាគុយអូល។

***កំណត់ចំណាំ៖***

(១) រាល់ពេលប្តូរពីមជ្ឈដ្ឋានទឹកទៅមជ្ឈដ្ឋានសូលុយស្យុងអំបិលត្រូវប្រាកដថាសំណាកកោសិកា មិនត្រូវបានផ្លាស់ប្តូរ (សង្កេតមើលពីបម្រែបម្រួលទម្រង់វ៉ាគុយអូលនៅលើកោសិកាតែមួយ)។

(២) សូមកុំផ្លាស់ប្តូរលេខអុបហ្ស៊ិកទីបរាល់ពេលផ្លាស់ប្តូរមជ្ឈដ្ឋាន (ពីមជ្ឈដ្ឋានធម្មតា ទៅមជ្ឈដ្ឋានទឹក និងមជ្ឈដ្ឋានសូលុយស្យុងអំបិល)។

**គ- លទ្ធផល និងវិភាគ**

- **លទ្ធផល**

ចូរគូររូបពីការសង្កេតបាតុភូតក្នុងដំណាក់កាលទាំងបីខាងលើ។

| | | |
|---|---|---|
| | | |
| ទម្រង់វ៉ាគុយអូលក្នុងមជ្ឈដ្ឋានធម្មតា | ទម្រង់វ៉ាគុយអូលក្នុងមជ្ឈដ្ឋានទឹក | ទម្រង់វ៉ាគុយអូលក្នុងមជ្ឈដ្ឋានសូលុយស្យុងអំបិល ១៥% |

– **វិភាគ**

១- ហេតុអ្វីបានវាំគុយអូលកោសិការីកធំ នៅក្នុងមជ្ឈដ្ឋានតំណក់ទឹក?

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

២- ហេតុអ្វីបានជាវាំគុយអូលកោសិការួមតូច នៅក្នុងមជ្ឈដ្ឋានសូលុយស្យុងអំបិល?

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

៣- ដូចម្តេចដែលហៅថាអូស្មូស?

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

**ឃ- សន្និដ្ឋាន**

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

**ខ- សំណួរពង្រីកចំណេះដឹង**

១- ហេតុអ្វីបានជាស៊ុតប្រែជាស្អុយនៅពេលយើងត្រាំក្នុងទឹករយៈពេលយូរ?

២- ហេតុអ្វីបានជាគ្រាប់រុក្ខជាតិមួយចំនួន ត្រូវត្រាំទឹកសិន មុនធ្វើការបណ្ដុះ?

៣- ហេតុអ្វីបានជារុក្ខជាតិគោកងាប់ (រលួយ) នៅពេលលិចទឹករយៈពេលយូរ?

៤- តើបាតុភូតអូស្មូសមានសារៈប្រយោជន៍អ្វីខ្លះ នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់យើង?

៥- តើបាតុភូតអូស្មូសមានសារៈប្រយោជន៍អ្វីខ្លះ នៅក្នុងវិស័យវេជ្ជសាស្ត្រ?

## ប្រធានបទទី៤៖ សង្កេតការលូតលាស់អំប្រ៊ីយ៉ុងបក្សី (ស៊ុតទា)

### ៤.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូត្រូវអាន សេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- អានបញ្ជីត្រួតពិនិត្យ (☑ Check List) ខាងក្រោមឱ្យបានយល់ច្បាស់។

២- ត្រៀមឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការពិសោធន៍ កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់។

៣- សាកល្បងអនុវត្តដំណើរការពិសោធឱ្យបានស្ទាត់ នៅមុនពេលថ្នាក់រៀនចាប់ផ្តើម។

៤- ចែកសន្លឹកកិច្ចការពិសោធន៍ និងវីដេអូណែនាំពិសោធន៍នេះទៅឱ្យសិស្សនៅមុនពេលបង្រៀនមួយថ្ងៃ យ៉ាងតិចដោយអនុវត្តបែបថ្នាក់រៀនត្រឡប់ (Flipped classroom)។

៥- ការបង្រៀនបែបថ្នាក់រៀនសកម្មសម្រាប់មេរៀននេះជាជម្រើសដ៏ល្អបំផុត។

៦- ត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់តួនាទីសមាជិក និងរយៈពេលឱ្យបានច្បាស់លាស់។

៧- ត្រូវណែនាំសិស្សឱ្យជ្រើសយកស៊ុតបង្កកំណើត (ស៊ុតទាឬស៊ុតមាន់) ដែលមានអាយុខុសគ្នា ក្រៅពីអាយុស៊ុតក្នុងមេរៀននេះក៏បានដែរ។

៨- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃខាងក្រោម៖

- ☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
- ☐ ឆ្លើយសំណួរផ្ទាល់មាត់
- ☐ ធ្វើបទបង្ហាញជាក្រុម
- ☐ កម្មវិធីវាយតម្លៃឌីជីថល (ឧទាហរណ៍៖Kahoot, Quizizz, Blooket, Padiet...)។

៩- ផ្ទៀងផ្ទាត់បញ្ជីត្រួតពិនិត្យ (☑) លើចំណុចទាំងឡាយណាដែលជាសកម្មភាពសមស្របតាមប្រធានបទ។

១០- ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាមិនគ្រប់គ្រាន់ នៅក្នុងម៉ោងបង្រៀន។

*សូមចូលទៅកាន់វីដេអូពិសោធន៍តាមតំណភ្ជាប់នេះ:*

## ៤.២- បញ្ជីត្រួតពិនិត្យ (☑ Check List)

គ្រូ និងសិស្សត្រូវត្រៀមទៅតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ ក្នុងអំឡុងពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** (☑ Check List) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក២៖ ការបន្តពូជ និងការលូតលាស់<br>មេរៀនទី២៖ ការលូតលាស់របស់អំប្រ៊ីយ៉ុង ទំព័រ ៥៨-៦៦<br>☐ បានបង្រៀនរួចហើយ<br>**ប្រធានបទ៖ សង្កេតការលូតលាស់អំប្រ៊ីយ៉ុងបក្សី (ស៊ុតទា)**<br>☐ បានត្រៀមសម្ភារៈរួចរាល់រួមមាន៖ ស៊ុតបង្កកំណើត (ស៊ុតទា) មានអាយុ ៤ ៩ ១៦ និង១៩ថ្ងៃ ប្រអប់ប៉េទ្រី កែវពង្រីក ពិល ស្កុតក្រដាស ឈុតវះកាត់ ក្រដាសជូតមាត់ ម៉ាស ស្រោមដៃពេទ្យ និងថាស<br>☐ បានត្រៀមសន្លឹកកិច្ចការពិសោធន៍ ដំណើរការសង្កេតការលូតលាស់អំប្រ៊ីយ៉ុងបក្សី (ស៊ុតទា)<br>☐ បានត្រៀមសន្លឹកកិច្ចការវាយតម្លៃ និងចែកឱ្យសិស្សរួចរាល់<br>☐ បានចែកវីដេអូ ដំណើរការសង្កេតការលូតលាស់អំប្រ៊ីយ៉ុងបក្សី (ស៊ុតទា) ឱ្យសិស្សរួចរាល់<br>☐ បានត្រៀមសន្លឹកកិច្ចការវាយតម្លៃ ឬកម្មវិធីវាយតម្លៃរួចរាល់<br>☐ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទីសមាជិកក្រុមម្នាក់ៗបានច្បាស់លាស់ (ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។ | ☐ បានរៀនទ្រឹស្តីមេរៀនរួចហើយ<br>☐ បានរក និងប្រមូលសម្ភារៈគ្រប់គ្រាន់<br>☐ បានអាន និងយល់ពីដំណើរការនៅក្នុងសន្លឹកកិច្ចការដែលគ្រូបានចែកឱ្យ<br>☐ បានមើលវីដេអូ ដំណើរការសង្កេតការលូតលាស់អំប្រ៊ីយ៉ុងបក្សី (ស៊ុតទា) រួចរាល់<br>☐ បានសង្កេតដំណើរការពិសោធន៍ទៅតាមជំហាននីមួយៗ និងមានឯកសារពាក់ព័ន្ធរួចហើយ<br>☐ បានត្រៀមចូលរួមក្នុងការវាយតម្លៃរបស់គ្រូ<br>☐ បានបង្កើតក្រុម និងបែងចែកតួនាទីសមាជិកក្រុមច្បាស់លាស់។ |

| **ក្នុងអំឡុងពិសោធន៍** (☑ Check List) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ព្យួក ឬមើលវីដេអូអំពីដំណើរការពិសោធន៍<br>☐ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួច<br>☐ សម្របសម្រួលតាមក្រុម<br>– បំផុស ឬផ្តល់គន្លឹះដល់ក្រុមសិស្ស<br>– បង្កើនការប្រុងប្រយ័ត្នដល់សិស្ស<br>– សង្កេត តាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុមនីមួយៗ<br>☐ ឱ្យសិស្សសរសេររបាយការណ៍មេរៀននៅក្នុងសន្លឹកកិច្ចការពិសោធន៍ជាបុគ្គល ឬក្រុម។ | ☐ រំឭកដំណើរការពិសោធន៍ឡើងវិញ<br>☐ ប្រធានក្រុមដឹកនាំដំណើរការពិសោធន៍តាមក្រុមនីមួយៗ<br>☐ សង្កេត ពិភាក្សា និង កត់ត្រា<br>☐ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ<br>☐ បោសសម្អាតបន្ទប់<br>☐ អាន និងស្វែងយល់បន្ថែម<br>☐ សរសេររបាយការណ៍។ |

| **ក្រោយពិសោធន៍** (☑ Check List) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ប្រមូលសន្លឹកកិច្ចការពិសោធន៍<br>– **វាយតម្លៃ៖** គ្រូអាចឱ្យសិស្ស<br>☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>☐ ធ្វើបទបង្ហាញ<br>☐ ឆ្លើយសំណួរនៅក្នុងកម្មវិធីវាយតម្លៃឌីជីថល (ឧទាហរណ៍៖ Kahoot, Quizizz, Blooket, Padlet...)។ | ☐ ប្រគល់សន្លឹកកិច្ចការពិសោធន៍ឱ្យគ្រូ<br>– **កិច្ចការវាយតម្លៃ៖** សិស្សត្រូវ<br>☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>☐ ធ្វើបទបង្ហាញ<br>☐ ឆ្លើយសំណួរនៅក្នុងកម្មវិធីវាយតម្លៃឌីជីថល (ឧទាហរណ៍៖ Kahoot, Quizizz, Blooket, Padlet...)។ |

## ៤.៣- សន្លឹកកិច្ចការពិសោធន៍

### ប្រធានបទ៖ សង្កេតការលូតលាស់អំប្រីយ៉ុងបក្សី (ស៊ុតទា)

### ៤.៣.១- សេចក្តីផ្តើម

ការបង្កកំណើតរបស់បក្សីកើតឡើងនៅក្នុងខ្លួនសត្វញី (មេ) បន្ទាប់មកស៊ុតបង្កកំណើតលូតលាស់ជាបន្តបន្ទាប់ស្រោបដោយជាលិការឹងហៅថា សំបកស៊ុត។ ស៊ុតបង្កកំណើតបក្សីពងចេញមកក្រៅខ្លួនសត្វមេ និងលូតលាស់ក្រោមសីតុណ្ហភាពមួយសមស្រប (ប្រហែល37C⁰)[3] និងត្រូវការរយៈពេលខុសគ្នាទៅតាមប្រភេទបក្សី ដើម្បីញាស់ក្លាយកូនបក្សីពេញលេញ។ ចំពោះមាន់ និងការលូតលាស់របស់អំប្រីយ៉ុងត្រូវការរយៈពេលប្រហែល២១ ឬ២២ថ្ងៃ ដើម្បីញាស់ក្លាយជាកូនមាន់ឬកូនទា។ ការលូតលាស់របស់អំប្រីយ៉ុងមានដំណាក់កាលផ្សេងៗ។

### ៤.៣.២- វត្ថុបំណង

- **វិជ្ជាសម្បទា :** ពន្យល់ពីបម្រែបម្រួលការលូតលាស់របស់អំប្រីយ៉ុងបក្សីតាមរយៈការសង្កេត និងពិភាក្សាក្រុមបានត្រឹមត្រូវ។
- **បំណិនសម្បទា :** វិភាគពីលក្ខណៈស៊ុតបង្កកំណើត និងការលូតលាស់របស់អំប្រីយ៉ុងបក្សីក្នុងអាយុកាលផ្សេងៗគ្នា (ស៊ុតទាអាយុ៤ ៩ ១៦ និង១៩ថ្ងៃ) បានត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម។
- **ចរិយាសម្បទា :** ចូលចិត្តតាមដានការលូតលាស់អំប្រីយ៉ុងរបស់ស៊ុត និងអំប្រីយ៉ុងសត្វដទៃទៀត។

### ៤.៣.៣- វិធីសាស្ត្រ

**ក- សម្ភារៈ**

| | | | | |
|---|---|---|---|---|
|  ១. ស៊ុតបង្កកំណើតអាយុខុសៗគ្នា |  ២. ប្រអប់ប៉េទ្រី |  ៣. កែវពង្រីក |  ៤. ពិល |  ៥. ស្កុតក្រដាស |
|  ៦. ឈុតវះកាត់ |  ៧. ក្រដាសជូតមាត់ |  ៨. ម៉ាស |  ៩. ស្រោមដៃពេទ្យ |  ១០. ថាស |

**ខ- ដំណើរការ**

១- ដំបូងយើងសង្កេតមើលស៊ុត ដើម្បីរកឱ្យឃើញផ្នែកស្រួច និងផ្នែកទាល។

២- បញ្ចាំងភ្លើងពិលបញ្ឆិតចំហៀងបន្តិចនៅផ្នែកទាល និងស្រួចនៃស៊ុត ដើម្បីពិនិត្យរកថង់ខ្យល់។

៣- បន្ទាប់មកយើងយកស៊ុតបង្កកំណើតដែលមានអាយុ៤ ៩ ១៦ និង១៩ថ្ងៃ មកចោះបំបែកសំបកនៅផ្នែកខាង

[3] *Nora A Baak et al; 2019. Temperature of embryo culture for assisted reproduction.*

ទាលថ្នមៗ និងដោយប្រុងប្រយ័ត្នចៀសវាងកុំឱ្យដាច់ភ្នាសចង់ខ្យល់ ឬស្រោមភ្នាសអំប្រីយ៉ុង។



៤- បកសំបកស៊ុតដោយប្រើតង្កៀបវះកាត់មុខតូច និងកាត់តាមទិសទ្រេត (ដូចរូប) ដើម្បីកុំឱ្យប៉ះអំប្រីយ៉ុង។

៥- ហែកសំបកស៊ុតតាមផ្នែក ដែលបានវះកាត់សំបករួចដាក់អំប្រីយ៉ុងចូលក្នុងប្រអប់ប៉េទ្រី។

៦- សង្កេតអំប្រីយ៉ុងស៊ុតបង្កកំណើតនីមួយៗ។

៧- ប្រើកែវពង្រីកជំនួយសម្រាប់សង្កេតអំប្រីយ៉ុង ឱ្យកាន់តែច្បាស់ល្អ។

## គ- លទ្ធផល និងវិភាគ

### – លទ្ធផល

ចូរគូរទម្រង់អំប្រីយ៉ុងតាមអាយុស៊ុតនីមួយៗដែលបានមើលឃើញ។

| | | | |
|---|---|---|---|
| អាយុ៤ថ្ងៃ | អាយុ៩ថ្ងៃ | អាយុ១៦ថ្ងៃ | អាយុ១៩ថ្ងៃ |



*តារាងកត់ត្រាលទ្ធផល*

| លក្ខណៈស៊ុតបង្កកំណើតតាមការសង្កេត | អាយុរបស់ស៊ុតបង្កកំណើត (ថ្ងៃ) | | | |
|---|---|---|---|---|
| | ៤ | ៩ | ១៦ | ១៩ |
| ទំហំថង់អំប្រីយ៉ុង | | | | |
| សកម្មភាពកម្រើករបស់អំប្រីយ៉ុង | | | | |
| លក្ខណៈផ្សេងៗទៀតបើសង្កេតឃើញ | | | | |

ក្រោយយើងយកអំប្រីយ៉ុងចេញពីសំបកស៊ុតដាក់ចូលប្រអប់ប៉េទ្រីរួច តើប្អូនសង្កេតឃើញដូចម្តេច?

| លក្ខណៈស៊ុតបង្កកំណើតតាមការសង្កេត | អាយុរបស់ស៊ុតបង្កកំណើត (ថ្ងៃ) |
|---|---|

| | ៤ | ៩ | ១៦ | ១៩ |
| --- | --- | --- | --- | --- |
| អាល់ប៊ុយមែនរបស់ស៊ុត (សស៊ុត) | | | | |
| ស៊ុតលឿង (Yolk) | | | | |
| លក្ខណៈ/ទម្រង់អំប្រីយ៉ុង | | | | |
| ទំហំលូតលាស់របស់អំប្រីយ៉ុង | | | | |
| សរីរាង្គផ្សេងៗលូតលាស់ពេញលក្ខណៈ | | | | |
| លក្ខណៈផ្សេងៗទៀតបើសង្កេតឃើញ | | | | |

- **វិភាគ**

១- តើផ្នែកទាល និងផ្នែកស្រួចរបស់ស៊ុតមានលក្ខណៈខុសគ្នាដូចម្តេច?

........................................................................................................................................

........................................................................................................................................

........................................................................................................................................

២- តើប្អូនសង្កេតឃើញដូចម្តេច ក្រោយបកសំបកស៊ុតផ្នែកទាលរួច?

........................................................................................................................................

........................................................................................................................................

........................................................................................................................................

........................................................................................................................................

........................................................................................................................................

៣- ហេតុអ្វីបានជានៅផ្នែកទាលរបស់ស៊ុតមានថង់អំប្រីយ៉ុងផត?

........................................................................................................................................

........................................................................................................................................

........................................................................................................................................

........................................................................................................................................

........................................................................................................................................

៤- តើអំប្រីយ៉ុងអាយុមួយណា ដែលយើងអាចចាប់ផ្តើមសង្កេតឃើញទម្រង់សារពាង្គកាយច្បាស់ល្អ?

........................................................................................................................................

........................................................................................................................................

........................................................................................................................................

........................................................................................................................................

........................................................................................................................................

៥- តើសរីរាង្គមួយណាមានការលូតលាស់មុនគេ?

........................................................................................................................................

........................................................................................................................................

........................................................................................................................................

........................................................................................................................................

........................................................................................................................................

........................................................................................................................................

៦- តើស៊ុតលឿងមានសារៈសំខាន់ដូចម្ដេច សម្រាប់ការលូតលាស់របស់អំប្រីយ៉ុង?

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

.........................................................................................................................................................

## ឃ- សន្និដ្ឋាន

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

## ង- សំណួរពង្រីកចំណេះដឹង

១- តើការលូតលាស់អំប្រីយ៉ុងរបស់ថ្នាក់សត្វផ្សេងៗទៀតក្រៅពីថ្នាក់បក្សីមានលក្ខណៈដូចម្ដេច?

២- តើការលូតលាស់អំប្រីយ៉ុងរបស់រុក្ខជាតិមានលក្ខណៈដូចម្ដេច?

# ប្រធានបទទី៥៖ សង្ខេតលក្ខណៈរបស់ជ្រូសូគីល

## ៥.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូត្រូវអាន សេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- អានបញ្ជីត្រួតពិនិត្យ (☑ Check List) ខាងក្រោមឱ្យបានយល់ច្បាស់។

២- ត្រៀមឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការពិសោធន៍ កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់។

៣- សាកល្បងអនុវត្តដំណើរការពិសោធឱ្យបានស្ទាត់ នៅមុនពេលថ្នាក់រៀនចាប់ផ្តើម។

៤- ចែកសន្លឹកកិច្ចការពិសោធន៍ និងវីដេអូណែនាំពិសោធន៍នេះទៅឱ្យសិស្សនៅមុនពេលបង្រៀនមួយថ្ងៃយ៉ាងតិច ដោយអនុវត្តបែបថ្នាក់រៀនត្រឡប់ (Flipped classroom)។

៥- ការបង្រៀនបែបថ្នាក់រៀនសកម្មសម្រាប់មេរៀននេះជាជម្រើសដ៏ល្អបំផុត។

៦- បែងចែកសិស្សជាក្រុម ហើយកំណត់តួនាទីសមាជិក និងរយៈពេលឱ្យបានច្បាស់លាស់។

៧- ណែនាំឱ្យសិស្សរកប្រភេទផ្លែឈើទុំដោរខុសៗគ្នា និងមានក្លិនខ្លាំងដែលងាយទាក់ទាញជ្រូសូគីល។

៨- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវង្វាយតម្លៃខាងក្រោម៖

☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ

☐ ឆ្លើយសំណួរផ្ទាល់មាត់

☐ ធ្វើបទបង្ហាញជាក្រុម

☐ កម្មវិធីវង្វាយតម្លៃឌីជីថល (ឧទាហរណ៍៖Kahoot, Quizizz, Blooket, Padiet...)។

៩- ផ្ទៀងផ្ទាត់បញ្ជីត្រួតពិនិត្យ (☑) លើចំណុចទាំងឡាយណាដែលជាសកម្មភាពសមស្របតាមប្រធានបទ។

១០-ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាមិនគ្រប់គ្រាន់នៅក្នុងម៉ោងបង្រៀន។

*សូមចូលទៅកាន់វីដេអូពិសោធន៍តាមតំណភ្ជាប់នេះ៖*

## ៥.២- បញ្ជីត្រួតពិនិត្យ ( ☑ Check List )

គ្រូ និងសិស្សត្រូវត្រៀមទៅតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ ក្នុងអំឡុងពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** ( ☑ Check List ) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក៣៖ តំណពូជ<br>មេរៀនទី២៖ ក្រូម៉ូសូម ទំព័រ៩២-១០៩<br>☐ បានបង្រៀនរួចហើយ<br>**ប្រធានបទ៖ សង្កេតលក្ខណៈរបស់ជ្រូសូភីល**<br>☐ បានត្រៀមសម្ភារៈរួចរាល់រួមមាន៖ មីក្រូទស្សន៍កែវពង្រីក ( Stereo Microscope ) ចេកទុំ ឬត្នោតទុំ ដបទឹកសុទ្ធ ( ចំណុះ 1.5L ) កន្ត្រៃ កាំបិតកាត់ ស្កុតថ្លា សំឡីត្បារត្រចៀក ស្រោមដៃពេទ្យ ថ្នាំបាញ់មូស ថាស ម៉ាស ឈុតវះកាត់ ក្រដាសជូតមាត់ និងក្រដាសរ៉ាម( A4 )<br>☐ បានត្រៀមសន្លឹកកិច្ចការពិសោធន៍ ដំណើរការសង្កេតលក្ខណៈរបស់ជ្រូសូភីល<br>☐ បានត្រៀមសន្លឹកកិច្ចការវាយតម្លៃ និងចែកឱ្យសិស្សរួចរាល់<br>☐ បានចែកវីដេអូ ដំណើរការសង្កេតលក្ខណៈរបស់ជ្រូសូភីល ឱ្យសិស្សរួចរាល់<br>☐ បានត្រៀមសន្លឹកកិច្ចការវាយតម្លៃ ឬកម្មវិធីវាយតម្លៃឌីជីថលរួចរាល់<br>☐ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទីសមាជិកក្រុមម្នាក់ៗបានច្បាស់លាស់ ( ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង )។ | ☐ បានរៀនទ្រឹស្តីមេរៀនរួចហើយ<br>☐ បានរក និងប្រមូលសម្ភារៈគ្រប់គ្រាន់<br>☐ បានអាន និងយល់ពីដំណើរការនៅក្នុងសន្លឹកកិច្ចការដែលគ្រូបានចែកឱ្យ<br>☐ បានមើលវីដេអូ ដំណើរការសង្កេតលក្ខណៈរបស់ជ្រូសូភីលរួចរាល់<br>☐ បានសង្កេតដំណើរការពិសោធន៍ទៅតាមជំហាននីមួយៗ និងមានឯកសារពាក់ព័ន្ធរួចហើយ<br>☐ បានត្រៀមចូលរួមក្នុងការវាយតម្លៃរបស់គ្រូ<br>☐ បានបង្កើតក្រុម និងបែងចែកតួនាទីសមាជិកក្រុមច្បាស់លាស់។ |
| **ក្នុងអំឡុងពិសោធន៍** ( ☑ Check List ) | |
| **គ្រូ** | **សិស្ស** |
| ☐ រំឭក ឬមើលវីដេអូអំពីដំណើរពិសោធន៍<br>☐ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួច<br>☐ សម្របសម្រួលតាមក្រុម<br>– បំផុស ឬផ្តល់គន្លឹះដល់ក្រុមសិស្ស<br>– បង្កើនការប្រុងប្រយ័ត្នដល់សិស្ស<br>– សង្កេត តាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុមនីមួយៗ<br>☐ ឱ្យសិស្សផ្តល់សរសេររបាយការណ៍មេរៀននៅក្នុងសន្លឹកកិច្ចការពិសោធន៍ជាបុគ្គល ឬក្រុម។ | ☐ រំឭកដំណើរការពិសោធន៍ឡើងវិញ<br>☐ ប្រធានក្រុមដឹកនាំដំណើរការពិសោធន៍តាមក្រុមនីមួយៗ<br>☐ សង្កេត ពិភាក្សា និងកត់ត្រា<br>☐ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ<br>☐ បោសសម្អាតបន្ទប់<br>☐ អាន និងស្វែងយល់បន្ថែម<br>☐ សរសេររបាយការណ៍។ |

<table>
<tr><th colspan="2">ក្រោយពិសោធន៍ ( ☑ Check List )</th></tr>
<tr><th>គ្រូ</th><th>សិស្ស</th></tr>
<tr><td>☐ ប្រមូលសន្លឹកកិច្ចការពិសោធន៍<br>– វាយតម្លៃ៖ គ្រូអាចឱ្យសិស្ស<br>☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>☐ ធ្វើបទបង្ហាញជាក្រុម<br>☐ ឆ្លើយសំណួរនៅក្នុងកម្មវិធីវាយតម្លៃឌីជីថល ( ឧទាហរណ៍៖ Kahoot, Quizizz, Blooket, Padlet... )។</td><td>☐ ប្រគល់សន្លឹកកិច្ចការពិសោធន៍ឱ្យគ្រូ<br>– កិច្ចការវាយតម្លៃ៖ សិស្សត្រូវ<br>☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>☐ ធ្វើបទបង្ហាញជាក្រុម<br>☐ ឆ្លើយសំណួរនៅក្នុងកម្មវិធីវាយតម្លៃឌីជីថល ( ឧទាហរណ៍៖ Kahoot, Quizizz, Blooket, Padlet... )។</td></tr>
</table>

## ៥.៣- សន្លឹកកិច្ចការពិសោធន៍

## ប្រធានបទ៖ សង្កេតលក្ខណៈរបស់រុយផ្លែឈើ

### ៥.៣.១- សេចក្ដីផ្ដើម

**រុយផ្លែឈើ** (*Drosophila melanogaster*) ឬ Fruit fly ជាសត្វល្អិតតូចៗ ដែលជារឿយៗប្រទះឃើញនៅក្នុងផ្ទះ ភោជនីយដ្ឋាន និងគ្រប់កន្លែងដែលមានអាហារ ផ្លែឈើ បន្លែ ឬកាកសំណល់ទុកចោលស្អុយរលួយ។ រុយផ្លែឈើញីអាចពងបាន៥០ទៅ៧៥ពងក្នុងមួយថ្ងៃ។ ពងរុយផ្លែឈើលូតលាស់ក្លាយជាដង្កូវ រួចបន្តវិវត្តហូតដល់ដំណាក់កាលពេញវ័យក្នុងរយៈពេលប្រហែលមួយសប្ដាហ៍។ រុយផ្លែឈើមានអាយុកាលខ្លីណាស់១២ទៅ១៥ថ្ងៃប៉ុណ្ណោះ។ រុយផ្លែឈើមានចំនួនក្រូម៉ូសូម2n=8។ រុយផ្លែឈើញីមានក្រូម៉ូសូមភេទ XX និងឈ្មោលXY។ សត្វញី និងសត្វឈ្មោលមានលក្ខណៈមួយចំនួនខុសគ្នា ដែលងាយស្រួលក្នុងការធ្វើការសង្កេត។ លក្ខណៈសម្គាល់ទាំងនោះរួមមាន៖ ពណ៌ភ្នែក (ខ្មៅ ក្រហម ស) ពណ៌ដងខ្លួន (ខ្មៅ ប្រផេះ ត្នោត) ស្លាប (រួញ វែង) និងលក្ខណៈសម្គាល់ភេទជាដើម។

### ៥.៣.២- វត្ថុបំណង

- **វិជ្ជាសម្បទា :** រៀបរាប់ពីលក្ខណៈខាងក្រៅ (ផេណូទីប) របស់រុយផ្លែឈើរួមមាន ភេទ ពណ៌ដងខ្លួន ពណ៌ភ្នែក និងលក្ខណៈស្លាប បានត្រឹមត្រូវតាមរយៈការសង្កេត និងពិភាក្សាក្រុម។
- **បំណិនសម្បទា :** វិភាគលក្ខណៈខាងក្រៅរបស់រុយផ្លែឈើពូជផ្សេងៗគ្នាបានត្រឹមត្រូវតាមរយៈការសង្កេត។
- **ចរិយាសម្បទា :** មានទម្លាប់ក្នុងការសង្កេតលក្ខណៈខាងក្រៅរបស់ពូជរុយផ្លែឈើផ្សេងៗនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។

### ៥.៣.៣- វិធីសាស្ត្រ

**ក- សម្ភារៈ**

| | | | | |
|---|---|---|---|---|
| <br>១. មីក្រូទស្សន៍ស្តេរេអូ | <br>២. ចេកទុំ(រលួយ) | <br>៣. ដបទឹកសុទ្ធ(1.5L) | <br>៤. កន្ត្រៃ | <br>៥. កាំបិតកាត់ |
| <br>៦. ស្កុតថ្លា | <br>៧. សំឡីត្បារត្រចៀក | <br>៨. ស្រោមដៃពេទ្យ | <br>៩. ថ្នាំបាញ់មូស | <br>១០. ថាស |
| <br>១១. ម៉ាស | <br>១២. ឈុតវះកាត់ | <br>១៣. ក្រដាសជូតមាត់ | <br>១៤. ក្រដាសស(A4) | |

### ខ- ដំណើរការ

១- ដំបូងយើងត្រូវធ្វើឧបករណ៍ចាប់ (អន្ទាក់) ជ្រូសូភីលជាមុនសិន។

២- យើងកាត់ផ្នែកខាងលើ១ភាគ៣នៃដបទឹកសុទ្ធ (ចំណុះ១.៥លីត្រ) ។

៣- យកផ្លែឈើដែលទុំជោរ (ចេកទុំ ខ្នុរទុំ ត្នោតទុំ...) ដាក់ចូលចូលក្នុងដបអន្ទាក់។

៤- យកផ្នែកមាត់ដបស៊កចូលក្នុងផ្នែកគូតដប បន្ទាប់មករុំស្កុតត្រង់មុខប្រសព្វរវាងផ្នែកមាត់ និងគូតដបឱ្យបានជិតល្អ (មើលរូប)។

៥- យកដបអន្ទាក់ទុកនៅកន្លែងណាដែលយើងសង្កេតឃើញថាមានជ្រូសូភីល (ម្លប់ និងមានសំណើម) រួចទៅរក្សាទុករយៈពេលចន្លោះ២៤ម៉ោងទៅ៤៨ម៉ោង ដើម្បីឱ្យជ្រូសូភីលចូលក្នុងដប។

៦- ប្រើថ្នាំបាញ់មូលសណ្តំជ្រូសូភីល ដើម្បីងាយចាប់ជ្រូសូភីលមកពិនិត្យតាមមីក្រូទស្សន៍ ឬកែវពង្រីក។



### គ- លទ្ធផល និងវិភាគ

– **លទ្ធផល**

| ប្រភេទនុយ (ឈ្មោះផ្លែឈើទុំ) ........................................................................................ | | | | | |
|---|---|---|---|---|---|
| លរ. | ឈ្មោះពូជជ្រូសូភីល | ភេទ | ពណ៌ភ្នែក | ពណ៌ដងខ្លួន | លក្ខណៈស្លាប |
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |
| ៩ | | | | | |

ចូរគូររូបជ្រូសូភីលដែលបានសង្កេតឃើញដោយមីក្រូទស្សន៍កែវពង្រីក រួចដាក់ឈ្មោះសរីរាង្គផ្សេងៗឱ្យបានត្រឹមត្រូវ។

– លក្ខណៈភេទ

| | |
|---|---|
| *លក្ខណៈភេទឈ្មោល* | *លក្ខណៈភេទញី* |

– លក្ខណៈស្លាប

| | |
|---|---|
| *លក្ខណៈស្លាបរួញ* | *លក្ខណៈស្លាបវែង* |

– **វិភាគ**

១- តើជ្រូសូភីលញី និងជ្រូសូភីលឈ្មោលមានលក្ខណៈខុសគ្នាដូចម្តេចខ្លះ ?

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

២- ចូររៀបរាប់ពណ៌ដងខ្លួន ពណ៌ភ្នែក និងលក្ខណៈស្លាបរបស់ជ្រូសូភីលដែលបានសង្កេតឃើញ។

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

៣- ហេតុអ្វីបានជាយើងចាំបាច់ត្រូវដាក់ផ្លែឈើទុំជោរសម្រាប់ជានុយ ?

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

**ឃ- សន្និដ្ឋាន**

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

**ង- សំណួរពង្រីកចំណេះដឹង**

១- តើជ្រូសូភីលបន្តពូជដូចម្តេច ?

# ប្រធានបទទី៦៖ សង្កេតចំណែកមីតូសឫសខ្ទឹមស

## ៦.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូគប្បីអានសេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- អានបញ្ជីត្រួតពិនិត្យ (☑ Check List) ខាងក្រោមឱ្យបានយល់ច្បាស់។

២- ត្រៀមឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការពិសោធន៍ កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់។

៣- សាកល្បងអនុវត្តដំណើរការពិសោធន៍ឱ្យបានស្ទាត់មុនពេលថ្នាក់រៀនចាប់ផ្តើម។

៤- ផ្ញើវីដេអូ និងសន្លឹកកិច្ចការឱ្យសិស្សមុនពេលបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)។

៥- ប្រាប់សិស្សឱ្យបណ្តុះឫសខ្ទឹមស បីទៅបួនថ្ងៃ មុនពេលពិសោធន៍។

៦- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយកវិធីវាយតម្លៃមួយក្នុងចំណោមវិធីខាងក្រោម៖

- ☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
- ☐ ឆ្លើយសំណួរផ្ទាល់មាត់
- ☐ ធ្វើបទបង្ហាញជាក្រុម
- ☐ វាយតម្លៃបែបឌីជីថល (ឧទាហរណ៍៖ Kahoot, Quizizz, Blooket, Padlet...)។

*សូមចូលទៅកាន់វីដេអូពិសោធន៍តាមតំណភ្ជាប់នេះ*

## ៦.២- បញ្ជីត្រួតពិនិត្យ (☑ Check List)

គ្រូ និងសិស្សត្រូវត្រៀមទៅតាមដំណាក់កាលទាំងបី៖ មុនពិសោធន៍ ក្នុងអំឡុងពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** (☑ Check List) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ជំពូក១៖ កោសិកា<br>មេរៀនទី៣៖ ដំណុះដំណាលកោសិកា និងរូបផ្តុំសារពាង្គកាយរស់ ទំព័រទី២៤-៣៤<br>☐ បានបង្រៀនរួចហើយ<br>**ប្រធានបទ៖ សង្កេតចំណែកមីតូសរបស់ឫសខ្ទឹមស**<br>☐ ត្រៀមសម្ភារៈរួចរាល់រួមមាន ឫសខ្ទឹមស សូលុយស្យុង HCL 3% សូលុយស្យុង Safranin 0.1% មីក្រូទស្សន៍ ប្រអប់ប៉េទ្រី ចង្កៀងអាល់កុល ដែកកេះ បន្ទះឡាម ឡាម៉ែល ថាស កូនកាំបិត បំពង់សាក កែវបេសែ ពីប៉ែតជ័រ ស្រោមដៃពេទ្យ ក្រដាសA4 ក្រដាសជូតមាត់ កន្ត្រៃ ឡាម ដង្កៀប ដបទឹកសុទ្ធ កូនកន្សែង និងម្ជុលមុខលំពែង<br>☐ បានត្រៀមសន្លឹកកិច្ចការសិស្សអំពីដំណើរការសង្កេតចំណែកមីតូសឫសខ្ទឹមស<br>☐ សន្លឹកកិច្ចការវាយតម្លៃត្រូវបានចែកឱ្យសិស្ស។<br>☐ បានផ្ញើវីដេអូអំពីដំណើរការសង្កេត ចំណែកមីតូសឫសខ្ទឹមសឱ្យសិស្ស<br>☐ បានត្រៀមសន្លឹកកិច្ចការ ឬកម្មវិធីវាយតម្លៃឌីជីថល<br>☐ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទីសមាជិកក្រុមម្នាក់ៗច្បាស់លាស់ (ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។ | ☐ បានអានទ្រឹស្តីមេរៀន<br>☐ បានរកសម្ភារៈគ្រប់គ្រាន់<br>☐ បានអាន និងយល់ពីដំណើរការនៅក្នុងសន្លឹកកិច្ចការដែលគ្រូបានចែកឱ្យ<br>☐ បានមើលវីដេអូអំពីដំណើរការសង្កេតចំណែកមីតូសឫសខ្ទឹមស<br>☐ បានរៀបចំបង្កើតក្រុមនិងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់។ |
| **ក្នុងអំឡុងពិសោធន៍** (☑ Check List) | |
| **គ្រូ** | **សិស្ស** |
| ☐ រំឭកដំណើរការពិសោធន៍ សង្កេតចំណែកមីតូសឫសខ្ទឹមសនៅក្នុងសន្លឹកកិច្ចការសិស្ស<br>☐ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុម<br>☐ សម្របសម្រួលតាមក្រុម<br>– បំផុស និងផ្តល់គន្លឹះទៅសិស្សតាមក្រុម<br>– បង្កើនការប្រុងប្រយ័ត្ន<br>– សង្កេត និងតាមដានដំណើរការ និងការពិភាក្សា របស់សិស្សតាមក្រុម<br>☐ ឱ្យសិស្សបំពេញសន្លឹកកិច្ចការរៀងខ្លួន<br>☐ ឱ្យសិស្សតាមក្រុមនីមួយៗសរសេររបាយការណ៍ | ☐ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>☐ សង្កេត ពិភាក្សា និងកត់ត្រា<br>☐ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ<br>☐ បោសសម្អាតបន្ទប់<br>☐ អាន និងស្វែងយល់បន្ថែម<br>☐ បំពេញសន្លឹកកិច្ចការ<br>☐ សរសេររបាយការណ៍ពិសោធន៍តាមក្រុម។ |

| | |
|---|---|
| ពិសោធន៍(កំណត់រយៈពេលប្រមូលដាក់លាក់)។ | |
| **ក្រោយពិសោធន៍** (☑ Check List) | |
| **គ្រូ** | **សិស្ស** |
| ☐ ប្រមូលសន្លឹកកិច្ចការសង្កេតចំណែកមីតូសឫសខ្ទឹមស<br>☐ ប្រមូលរបាយការណ៍<br>✧ **រើសការវាយតម្លៃខាងក្រោមនេះ ៖**<br>☐ លើចម្លើយក្នុងសន្លឹកកិច្ចការសិស្សដែលផ្តល់<br>☐ លើធ្វើបទបង្ហាញ<br>☐ លើចម្លើយនៅក្នុងកម្មវិធីវាយតម្លៃឌីជីថល ( Kahoot, Quizizz, Blooket, Padlet…)។ | ☐ ប្រគល់សន្លឹកកិច្ចការជូនគ្រូ<br>☐ ប្រគល់របាយការណ៍ជូនគ្រូ<br>✧ **បំពេញកិច្ចការ**<br>☐ ឆ្លើយសំណួរ<br>☐ ធ្វើបទបង្ហាញ<br>☐ បំពេញតាមកម្មវិធីវាយតម្លៃឌីជីថល (Kahoot, Quizizz, Blooket, Padlet…)។ |

# ៦.៣- សន្លឹកកិច្ចការពិសោធន៍

## ប្រធានបទ៖ សង្កេតចំណែកមីតូសឫសខ្ទឹមស

### ៦.៣.១- សេចក្ដីផ្ដើម



ការលូតលាស់ធំធាត់របស់ភាវៈរស់ជាលទ្ធផលនៃការកើនឡើងនូវចំនួនកោសិកាឥតឈប់ឈររបស់សារពាង្គកាយតាមលំនាំមួយហៅថាមីតូស។ ចំណែកមីតូសរបស់រុក្ខជាតិកើតឡើងយ៉ាងលឿននៅពន្លកដើម និងចុងឫស។ នៅផ្នែកពន្លកដើមជាលិកាលូតលាស់លឿនដើម្បីធានានូវការលូតកម្ពស់ដើម ចំណែកចុងឫសជួយឱ្យរុក្ខជាតិលូតលាស់ចាក់ចូលក្នុងដីទប់លំនឹងដើម និងស្រូបសារធាតុខនិជ និងទឹកពីក្នុងដី។ ប្រធានបទនេះយើងសង្កេតដំណើរការចំណែកមីតូសឫសខ្ទឹមស។ តើចំណែកមីតូសឫសខ្ទឹមសប្រព្រឹត្តទៅដូចម្ដេច?

### ៦.៣.២- វត្ថុបំណង

– **វិជ្ជាសម្បទា** : ពន្យល់ពីវគ្គផ្សេងៗរបស់ចំណែកមីតូសឫសខ្ទឹមសបានត្រឹមត្រូវតាមរយៈការសង្កេត។

– **បំណិនសម្បទា** : វិភាគពីលក្ខណៈក្រូម៉ូសូមរបស់កោសិកាក្នុងវគ្គនីមួយៗនៃចំណែកមីតូសឫសខ្ទឹមសបានត្រឹមត្រូវតាមរយៈការសង្កេត។

– **ចរិយាសម្បទា**: ទម្លាប់ផ្ដល់សារធាតុចិញ្ចឹមឱ្យបានគ្រប់គ្រាន់ដល់រុក្ខជាតិ ដើម្បីលូតលាស់ និងធំធាត់បានល្អ។

### ៦.៣.៣- វិធីសាស្ត្រ

**ក- សម្ភារៈ**

| | | | | |
|---|---|---|---|---|
|  |  |  |  |  |
| ១. ឫសខ្ទឹមស | ២.បន្ទះឡាម និងឡាម៉ែល | ៣. ស្រោមដៃពេទ្យ | ៤. កន្ត្រៃ តង្កៀប និងម្ជុលមុខលំពែង | ៥. សូលុយស្យុង HCL 3% |
|  |  |  |  |   |
| ៦. សូលុយស្យុង Safranin 0.1% | ៧. មីក្រូទស្សន៍អុបទិក | ៨. ប្រអប់ប៉េទ្រី | ៩. ចង្កៀងអាល់កុល | ១០. ឡាម |
|  |  |  |  | |
| ១១. កូនកាំបិត | ១២. បំពង់សាក | ១៣. ដប់ទឹកសុទ្ធ | ១៤. ក្រដាសជូតមាត់ និងកូកន្សែង | |

### ខ- ដំណើរការ

**វិធីបណ្តុះឫសខ្ទឹមស**

១- កាត់ដបជ័រចំណុះ៥០០មីលីលីត្រប្រហែល១ភាគ៣ពីមាត់ដប រួចយកផ្នែកមាត់ដាក់ចុះក្រោម បន្ទាប់មកចាក់ទឹកប្រហែល២៥០មីលីលីត្រចូលក្នុងដប។

២- យកក្រដាសជូតមាត់ញុកចូលក្នុងដបឱ្យបានសមល្មម។

៣- យកខ្ទឹមស ៣-៤កំពឹស ដាក់ក្នុងដបជ័រ( ក្បាលឫសចុះក្រោម )។

៤- រក្សាទុកដបបណ្តុះរយៈពេលពី៣-៥ថ្ងៃ។

**វិធីសង្កេតចំណែកមីតូសឫសខ្ទឹមស**

១- យកពីប៉ែតជ័របូមសូលុយស្យុង HCl 3% ចំណុះ5ml ដាក់ក្នុងបំពង់សាក។

២- កាត់ឫសខ្ទឹមសបីទៅបួនសសៃ(ប្រវែងប្រហែល0.៥សង់ទីម៉ែត្រ)ដាក់ក្នុងបំពង់សាកនោះ រួចត្រលែងតិចៗ ២ទៅ៣នាទី។

៣- យកបំពង់សាកខាងលើទៅកម្តៅលើភ្លើងចង្កៀងអាល់កុលឱ្យបានសីតុណ្ហភាពប្រហែល៦០$^{0}$C រយៈពេលពីរនាទី។

៤- ទុកសូលុយស្យុងក្នុងបំពង់សាកឱ្យត្រជាក់ រួចយកឫសខ្ទឹមសទៅត្រាំក្នុងសូលុយស្យុង Safranin 0.1% ក្នុងប្រអប់ប៉េទ្រីរយៈពេល៨ទៅ១០នាទី។

៥- ចាក់ទឹកចូលក្នុងប្រអប់ប៉េទ្រី ដើម្បីលាងសូលុយស្យុង Safranin ចេញពីឫសខ្ទឹមសឱ្យបានស្អាត។

៦- យកសំណាកឫសខ្ទឹមសដាក់លើបន្ទះឡាម បន្ទាប់មកកាត់យកចុងឫសប្រវែង២-៣មីលីម៉ែត្រ។

៧- គ្របឡាម៉ែលពីលើសំណាក រួចប្រើមេដៃសង្កត់ទៅលើឡាម៉ែលថ្នមៗ ដោយរុញឡាម៉ែលចុះឡើងៗ ធ្វើយ៉ាងណាឱ្យសំណាកបែកស្តើងបំផុត។

៨- យកសំណាកឫសទៅពិនិត្យដោយមីក្រូទស្សន៍អុបទិច( ប្រើកែវពង្រីក 4x 10x និង40x)។

### គ- លទ្ធផល និងវិភាគ

– **លទ្ធផល**

គូររូបកោសិកា និងដាក់ឈ្មោះវគ្គនីមួយៗរបស់មីតូសដែលបានសង្កេតឃើញដោយមីក្រូទស្សន៍ឱ្យត្រឹមត្រូវ។

៦- ហេតុអ្វីបានជាយើងត្រូវកម្តៅឫសខ្ទឹមស?

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

### ឃ- សន្និដ្ឋាន

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

### ង- សំណួរពង្រីកចំណេះដឹង

១- ចូរសង្កេតមីតូសឫសរុក្ខជាតិផ្សេងៗទៀត។

# មេរៀនថ្នាក់ទី១២

## ប្រធានបទទី១៖ សង្កេតទម្រង់ខួរក្បាលសត្វឆ្អឹងកង(បក្សី)

### ១.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំការធ្វើពិសោធប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូត្រូវអានសេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- អានបញ្ជីត្រួត (☑ Check List) ខាងក្រោមឱ្យបានយល់ច្បាស់។

២- រៀបចំ ឬប្រមូលសម្ភារៈ និងឧបករណ៍ដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការពិសោធន៍ កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់។

៣- គ្រូណែនាំឱ្យសិស្សឱ្យមានការបម្រុងប្រយ័ត្នខ្ពស់ទាំងមុនពេល កំឡុងពេល និងក្រោយពិសោធន៍ជាពិសេសរបស់មានមុខមុតស្រួច។

៤- គ្រូសាកល្បងអនុវត្តធ្វើការសង្កេតទម្រង់ខួរក្បាលសត្វឆ្អឹងកង(បក្សី)នៅមុនពេលថ្នាក់រៀនចាប់ផ្តើម។

៥- គ្រូឱ្យសន្លឹកកិច្ចការពិសោធន៍ និងវីដេអូពិសោធន៍ទៅសិស្ស មួយថ្ងៃយ៉ាងតិចមុនអនុវត្តន៍ពិសោធន៍(អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)។

៦- គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទី និងរយៈពេលឱ្យបានច្បាស់លាស់។

៧- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោម៖

- ☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
- ☐ ឆ្លើយសំណួរផ្ទាល់មាត់
- ☐ ធ្វើបទបង្ហាញជាក្រុម។

៨- ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាមិនគ្រប់គ្រាន់ក្នុងម៉ោងបង្រៀន។

*សូមចូលទៅកាន់វីដេអូពិសោធន៍តាមតំណភ្ជាប់នេះ*

## ១.២- បញ្ជីត្រួតពិនិត្យ ( ☑ Check List )

គ្រូ និងសិស្សត្រូវត្រៀមទៅតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ ក្នុងអំឡុងពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** ( ☑ Check List ) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ជំពូក៣៖ តម្រូវផ្សេងៗរបស់សារពាង្គកាយរបស់<br>មេរៀនទី១៖ តម្រូវប្រសាទ ទំព័រទី៥៦ ដល់៦១<br>**ប្រធានបទ៖ សង្កេតទម្រង់ខួរក្បាលសត្វឆ្អឹងកង(បក្សី)**<br>☐ បានបង្រៀនរួចហើយ<br>☐ សម្ភារៈបានរៀនចំរួចរាល់រួមមាន៖ ក្បាលមាន់ កូនកាំបិតមុខស្រួច កាំបិតធំ តង្កៀប ថាសវះកាត់ ទឹក កូនកន្សែងជូតដៃ ក្រដាសជូតមាត់ ស្រោមដៃ ម៉ាស ជ្រញ់ កន្ត្រៃមុខស្រួច-មុខទាល កន្ត្រៃមុខស្រួច ប៉ាំង<br>☐ បានត្រៀមសន្លឹកកិច្ចការសិស្សអំពីដំណើរការសង្កេតទម្រង់ខួរក្បាលសត្វឆ្អឹងកង(បក្សី)និងបានចែកឱ្យសិស្សរួចរាល់<br>☐ បានត្រៀមវិធី ឬសន្លឹកកិច្ចការវាយតម្លៃឱ្យសិស្សឱ្យបានរួចរាល់<br>☐ បានត្រៀមវីដេអូអំពីដំណើរការសង្កេតទម្រង់ខួរក្បាលសត្វឆ្អឹងកង(បក្សី) និងបានចែកឱ្យសិស្សរួចរាល់<br>☐ គ្រូបានបែងចែកក្រុមសិស្ស និងបានកំណត់តួនាទីសមាជិកម្នាក់ៗច្បាស់លាស់(សមាជិកអាចពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។ | ☐ បានអានទ្រឹស្តីមេរៀនរួចរាល់<br>☐ បានរកសម្ភារៈពិសោធន៍គ្រប់គ្រាន់<br>☐ បានអាន និងយល់ពីដំណើរការសង្កេតអំពីទម្រង់ខួរក្បាលសត្វឆ្អឹងកងទៅតាមជំហាននីមួយៗដែលគ្រូបានចែកឱ្យ<br>☐ បានមើលវីដេអូស្តីពីការសង្កេតទម្រង់ខួរក្បាលសត្វឆ្អឹងកងរួចហើយ<br>☐ បានរៀបចំបង្កើតក្រុម និងកំណត់តួនាទីសមាជិកក្រុមច្បាស់លាស់។ |
| **ក្នុងអំឡុងពិសោធន៍** ( ☑ Check List ) | |
| **គ្រូ** | **សិស្ស** |
| ☐ រំឭកដំណើរការសង្កេតខួរក្បាលបក្សីដែលមានក្នុងសន្លឹកកិច្ចការឡើងវិញ<br>☐ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួចរាល់<br>☐ សម្របសម្រួលតាមក្រុម<br>– បំផុសសិស្ស(តើត្រូវចៀរស្បែកក្បាលមាន់យ៉ាងដូចម្តេច?<br>– បង្កើនការប្រុងប្រយ័ត្នចំពោះឧបករណ៍មុត<br>– សង្កេត និងតាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុម<br>– បញ្ចាំងវីដេអូអំពីការសង្កេតខួរក្បាលបក្សីឱ្យសិស្សសង្កេតឡើងវិញ។ | ☐ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>☐ សង្កេត ពិភាក្សា និងកត់ត្រា ឬធ្វើបទបង្ហាញលទ្ធផល<br>☐ សម្អាតសម្ភារៈនិងរៀបចំទុកដាក់ឱ្យបានរៀបរយ<br>☐ បោសសម្អាតបន្ទប់ពិសោធន៍<br>☐ អាន និងស្វែងយល់បន្ថែម<br>☐ មើលវីដេអូឡើងវិញ។ |

| **ក្រោយពិសោធន៍** ( ☑ Check List ) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ប្រមូលរបាយការណ៍ ឬសន្លឹកកិច្ចការអំពីការសង្កេតទម្រង់ខួរក្បាលសត្វឆ្អឹងកង (បក្សី)<br>☐ **ការវាយតម្លៃ៖** គ្រូអាចឱ្យសិស្ស<br>☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>☐ ឆ្លើយសំណួរផ្ទាល់មាត់<br>☐ ឬធ្វើបទបង្ហាញតាមក្រុម។ | ☐ សរសេររបាយការណ៍ និងសន្លឹកកិច្ចការមេរៀន<br><br>☐ **កិច្ចការវាយតម្លៃ៖**<br>☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>☐ ឆ្លើយសំណួរផ្ទាល់មាត់<br>☐ ធ្វើបទបង្ហាញជាក្រុម។ |

## ១.៣- សន្លឹកកិច្ចការពិសោធន៍

### ប្រធានបទ៖ សង្កេតទម្រង់ខួរក្បាលសត្វឆ្អឹងកង(បក្សី)

### ១.៣.១- សេចក្តីផ្តើម

ខួរក្បាលជាផ្នែកមួយនៃមជ្ឈមណ្ឌលប្រសាទ ដែលមាននាទីទទួល និងឆ្លើយតបព័ត៌មាន។ ទម្រង់ខួរក្បាលរបស់សត្វឆ្អឹងកងមានការវិវត្តន៍ និងប្រែប្រួលខុសៗគ្នាពីថ្នាក់សត្វមួយទៅថ្នាក់សត្វមួយទៀត។ ឧទាហរណ៍ទម្រង់ខួរក្បាលរបស់សត្វឆ្អឹងកងថ្នាក់ទាបមួយចំនួនមិនទាន់មានរូបរាងច្បាស់លាស់ និងស្មុគស្មាញដូចទម្រង់ខួរក្បាលសត្វឆ្អឹងកងថ្នាក់ខ្ពស់នៅឡើយទេ។ ចំពោះសត្វឆ្អឹងកងទាំងប្រាំថ្នាក់ក៏មានទម្រង់ខុសៗគ្នាដែរ។ ផ្អែកលើទម្រង់ខុសៗគ្នានេះ យើងអាចសិក្សាសង្កេតបានបានយ៉ាងទូលំទូលាយតាមរយៈការវះកាត់ទម្រង់ខួរក្បាល។

តើទម្រង់របស់ខួរក្បាលបក្សី (មាន់) មានលក្ខណៈដូចម្តេចខ្លះ?

### ១.៣.២- វត្ថុបំណង

- **វិជ្ជាសម្បទា** : រៀបរាប់ពីផ្នែកផ្សេងៗខួរក្បាលមាន់បានត្រឹមត្រូវតាមរយៈការសង្កេត និងការពិភាក្សា។
- **បំណិនសម្បទា** : អនុវត្តការវះកាត់ខួរក្បាលមាន់បានត្រឹមត្រូវតាមរយៈសកម្មភាពវះកាត់ក្បាលមាន់។
- **ចរិយាសម្បទា** : ការពារខួរក្បាលរបស់យើងពីការប៉ះទង្គិចផ្សេងៗ និងបរិភោគអាហារដែលមានជីវជាតិគ្រប់គ្រាន់ដើម្បីជំនួយដល់ខួរក្បាលមានសុខភាពល្អ។

### ១.៣.៣- វិធីសាស្ត្រ

**ក- សម្ភារៈ**

| | | | | |
|---|---|---|---|---|
|  ១. ថាសវះកាត់ |  ២. ក្បាលមាន់ |  ៣. កាំបិតធំ |  ៤. កាំបិតវះកាត់ |  ៥. កន្ត្រៃមុខស្រួច |
|  ៦. ប៉ាំង |  ៧. កន្ត្រៃមុខទាល-ស្រួច |  ៨. ថាសក្រមួន |  ៩. ស្រោមដៃ |  ១០. ក្រដាសជូតមាត់ |

**ខ- ដំណើរការ**

១- មុនដំណើរការ ត្រូវពាក់អាវ ស្រោមដៃ និងវែនតាពិសោធន៍ឱ្យបានត្រឹមត្រូវ។
២- ដំបូងកាត់កមាន់ឱ្យខ្លីល្មម (ទុកប្រហែល០.៥សង់ទីម៉ែត្រពីតួក្បាល)។
៣- ប្រើកន្ត្រៃមុខស្រួចកាត់ស្បែកក្បាលមាន់ចេញឱ្យបានស្អាតល្អ។
៤- ប្រើកន្ត្រៃមុខស្រួច កាំបិតវះកាត់ និងប៉ាំង កាត់សាច់ដុំកចេញឱ្យអស់។
៥- ប្រើកន្ត្រៃមុខស្រួចកាត់ពីផ្នែកលើនៃឆ្អឹងលលាដ៏ក្បាល។
៦- ប្រើប៉ាំង និងកន្ត្រៃមុខស្រួច មុខទាលទាញឆ្អឹងលលាដ៍ក្បាលចេញ (សូមប្រយ័ត្នកុំឱ្យដាច់ស្រោមខួរ និងបែកខួរ)។

៧- ប្រើកន្ត្រៃមុខស្រួច មុខទាលកាត់សម្អាតសរីរាង្គផ្សេងៗជុំវិញខួរឱ្យបានស្អាតល្អ ដោយទុកតែខួរក្បាល (សូមប្រយ័ត្នបែកខួរ)។

៨- សង្កេតទម្រង់ និងផ្នែកផ្សេងៗខួរក្បាលមាន់។

**គ- លទ្ធផល និងវិភាគ**

– **លទ្ធផល**

ចូរគូររូប និងដាក់ឈ្មោះលើផ្នែកនីមួយៗទម្រង់ខួរក្បាលមាន់។

| | |
|---|---|
| *១. ទម្រង់ខួរក្បាលមាន់មើលពីខាងលើ* | *២. ទម្រង់ខួរក្បាលមាន់មើលពីខាងក្រោម* |

– **វិភាគ**

១- តើទម្រង់ខួរក្បាលមាន់មានប៉ុន្មានផ្នែក? អ្វីខ្លះ?

............................................................................................................................................

............................................................................................................................................

............................................................................................................................................

............................................................................................................................................

............................................................................................................................................

២- ចូរប្រាប់ឈ្មោះ និងនាទីផ្នែកផ្សេងៗខួរក្បាលមាន់ដែលប្អូនបានសង្កេតឃើញតាមរយៈការវះកាត់?

............................................................................................................................................

............................................................................................................................................

............................................................................................................................................

............................................................................................................................................

............................................................................................................................................

**ឃ- សន្និដ្ឋាន**

............................................................................................................................................

............................................................................................................................................

............................................................................................................................................

............................................................................................................................................

**ង- សំណួរពង្រីកចំណេះដឹង**

១- ចូរប្រៀបធៀបខួរក្បាលថ្នាក់បក្សី និងខួរក្បាលថ្នាក់ថនិកសត្វ។

២- តើត្រូវការពារខួរក្បាលរបស់អ្នកដូចម្តេចខ្លះ?

៣- តើការពាក់មួកសុវត្ថិភាពក្នុងពេលជិះម៉ូតូឬកង់ ជួយអ្នកដូចម្តេចខ្លះ?

## ប្រធានបទទី២៖ ទំនាក់ទំនងរវាងវិញ្ញាណរសជាតិ និងវិញ្ញាណក្លិន

### ២.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូត្រូវអាន សេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- អានតារាង (☑ Check List) ខាងក្រោមឱ្យបានយល់ច្បាស់។

២- រៀបឬប្រមូលចំសម្ភារៈ និងឧបករណ៍ដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការពិសោធន៍កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់។

៣- គ្រូសាកល្បងអនុវត្តធ្វើចំណែកស្លឹកក្រុជាតិនៅមុនពេលថ្នាក់រៀនចាប់ផ្តើម។

៤- គ្រូត្រូវផ្ញើវីដេអូ និងសន្លឹកកិច្ចការឱ្យសិស្សនៅមុនម៉ោងបង្រៀនយ៉ាងតិចមួយថ្ងៃ (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)។

៥- គ្រូអាចឱ្យសិស្សជ្រើសរើសទឹកផ្លែឈើប្រភេទខុសពីមេរៀននេះឱ្យតែមានរសជាតិប្រហាក់ប្រហែលគ្នា ឬ លើសពីបីប្រភេទក៏បាន។

៦- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោម៖

- ☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
- ☐ ឆ្លើយសំណួរផ្ទាល់មាត់
- ☐ ធ្វើបទបង្ហាញជាក្រុម
- ☐ កម្មវិធីវាយតម្លៃឌីជីថល (ឧទាហរណ៍៖ Kahoot, Quizizz, Blooket, Padlet...)។

*សូមចូលទៅកាន់វីដេអូពិសោធន៍តាមតំណភ្ជាប់នេះ*

## ២.២- បញ្ជីត្រួតពិនិត្យ (☑ Check List)

គ្រូ និងសិស្សត្រូវត្រៀមទៅតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ ក្នុងអំឡុងពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** (☑ Check List) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ជំពូក៣៖ តម្រូវផ្សេងៗរបស់សារពាង្គកាយ<br>មេរៀនទី២ សរីរាង្គវិញ្ញាណ ទំព័រ៧៦-៩៣<br>☐ បានបង្រៀនរួចហើយ<br>**ប្រធានបទ៖ ទំនាក់ទំនងរវាងវិញ្ញាណរសជាតិ និងវិញ្ញាណក្លិន**<br>☐ សម្ភារៈបានរៀបចំរួចរាល់រួមមាន ទឹកផ្លែឈើ បំពង់បឺត កូនកន្សែង ក្រមាសម្រាប់បិទភ្នែក ចាស ទឹកសុទ្ធ ក្រដាសអនាម័យ និងធុងសម្រាម<br>☐ បានត្រៀមវីដេអូអំពីដំណើរការសង្កេតទំនាក់ទំនងរវាងវិញ្ញាណរសជាតិ និងវិញ្ញាណក្លិន ហើយបានផ្តល់ឱ្យសិស្សរួចរាល់<br>☐ សន្លឹកកិច្ចការវាយតម្លៃត្រូវបានបែងចែកឱ្យសិស្សរួចរាល់<br>☐ គ្រូបានបែងចែកក្រុម និងបានកំណត់តួនាទីសមាជិកម្នាក់ៗបានច្បាស់លាស់(សមាជិកអាចពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។ | ☐ បានបង្រៀនទ្រឹស្តីមេរៀនរួចហើយ<br>☐ បានរកសម្ភារៈគ្រប់គ្រាន់<br>☐ បានមើលវីដេអូដំណើរការសង្កេតទំនាក់ទំនងរវាងវិញ្ញាណរសជាតិ និងវិញ្ញាណក្លិន រួចហើយ<br>☐ បានរៀបចំបង្កើតក្រុម និងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់ |
| **ក្នុងអំឡុងពិសោធន៍** (☑ Check List) | |
| **គ្រូ** | **សិស្ស** |
| ☐ រំឭកដំណើរការសង្កេត ទំនាក់ទំនងរវាងវិញ្ញាណរសជាតិ និងវិញ្ញាណក្លិនឡើងវិញ<br>☐ សម្របសម្រួលតាមក្រុម<br>– បំផុសសិស្ស<br>– បង្កើនការប្រុងប្រយ័ត្ន<br>– សង្កេត និងតាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុមផ្តល់គំរូរបាយ- ការណ៍ពិសោធន៍ទៅសិស្ស(មានមួយចប់ទាំងលទ្ធផល និងសន្និដ្ឋាន)។<br>☐ ឱ្យសិស្សសរសេររបាយការណ៍មេរៀននៅក្នុងសន្លឹកកិច្ចការពិសោធន៍ជាបុគ្គល ឬក្រុម។ | ☐ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>☐ សង្កេត ពិភាក្សា និង កត់ត្រា<br>☐ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ<br>☐ បោសសម្អាតបន្ទប់<br>☐ អាន និងស្វែងយល់<br>☐ សរសេររបាយការណ៍។ |
| **ក្រោយពិសោធន៍** (☑ Check List) | |
| **គ្រូ** | **សិស្ស** |
| ☐ ប្រមូលរបាយការណ៍ ឬសន្លឹកកិច្ចការអំពីការសង្កេតទំនាក់ទំនងរវាងវិញ្ញាណរសជាតិនិងវិញ្ញាណក្លិន និងដាក់ពិន្ទុ<br>– **ការវាយតម្លៃ៖** គ្រូអាចឱ្យសិស្ស | ☐ ប្រគល់របាយការណ៍ ឬសន្លឹកកិច្ចការពិសោធន៍ជូនគ្រូ<br>– **កិច្ចការវាយតម្លៃ៖** |

| | |
|---|---|
| ☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>☐ ឆ្លើយសំណួរផ្ទាល់មាត់<br>☐ ធ្វើបទបង្ហាញតាមក្រុម<br>☐ ឆ្លើយសំណួរដោយប្រើកម្មវិធីវង្វាយតម្លៃឌីជីថល (ឧទាហរណ៍៖ Kahoot, Quizizz, Blooket, Padlet...)។ | ☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចវាយតម្លៃ<br>☐ ឆ្លើយសំណួរផ្ទាល់មាត់<br>☐ ធ្វើបទបង្ហាញជាក្រុម<br>☐ ឆ្លើយសំណួរដោយប្រើកម្មវិធីវង្វាយតម្លៃឌីជីថល (ឧទាហរណ៍៖ Kahoot, Quizizz, Blooket, Padlet...)។ |

## ២.៣- សន្លឹកកិច្ចការពិសោធន៍

### ប្រធានបទ៖ ទំនាក់ទំនងរវាងវិញ្ញាណរសជាតិ និងវិញ្ញាណក្លិន

### ២.៣.១- សេចក្តីផ្តើម

អណ្តាតជាសរីរាង្គសំខាន់ក្នុងការនិយាយក្នុងការរំលាយអាហារ (បែបមេកានិក) និងផ្តល់រសជាតិ។ យើងអាចដឹងរសជាតិបានល្អដោយសារវិញ្ញាណរសជាតិ និងវិញ្ញាណក្លិន។ វិញ្ញាណទាំងពីរនេះទទួលដឹងបានអាស្រ័យទៅនឹងសារធាតុគីមីក្នុងអាហារ ផ្ទួលវិញ្ញាណរសជាតិលើអណ្តាត និងខ្យល់ដង្ហើមតាមច្រមុះ។ ច្រមុះជាសរីរាង្គយានវិញ្ញាណមាននាទីសំខាន់ក្នុងដំណកដង្ហើមនិងទទួលក្លិន។ កោសិកាផ្ទួលយានវិញ្ញាណដែលស្ថិតនៅក្នុងប្រហោងច្រមុះជាអ្នកចាប់ក្លិន។ នៅក្នុងប្រហោងច្រមុះ កោសិកាផ្ទួលមានផ្ទៃប្រហែល 10cm$^2$ បង្កើតបានជាតំបន់យានវិញ្ញាណ។

តើវិញ្ញាណរសជាតិ និងវិញ្ញាណក្លិនមានទំនាក់ទំនងគ្នាដូចម្តេចក្នុងអំឡុងពេលបរិភោគអាហារ?

### ២.៣.២- វត្ថុបំណង

- **វិជ្ជាសម្បទា :** ពន្យល់ពីទំនាក់ទំនងរវាងវិញ្ញាណរសជាតិ និងវិញ្ញាណក្លិន តាមរយៈការសង្កេត និងពិភាក្សាក្រុមបានច្បាស់លាស់។
- **បំណិនសម្បទា :** វិភាគឥទ្ធិពលនៃវិញ្ញាណក្លិន លើវិញ្ញាណរសជាតិបានត្រឹមត្រូវតាមរយៈការធ្វើតេស្តរសជាតិ និងក្លិន។
- **ចរិយាសម្បទា :** មានទម្លាប់អនាម័យល្អ ដើម្បីឱ្យសរីរាង្គវិញ្ញាណមានសុខភាពល្អនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។

### ២.៣.៣- វិធីសាស្ត្រ

**ក- សម្ភារ:**

| | | |
|---|---|---|
| <br>១. ទឹកទំពាំងបាយជូរ | <br><br>២. ទឹកប៉ោម | <br>៣. ទឹកក្រូច |
| <br>៤. ទឹកសុទ្ធ | <br>៥. តារាងកត់ត្រា លទ្ធផល | <br>៦. បំពង់បឺត ក្រដាសជូតមាត់ និងកូនកន្សែង |

**ខ- ដំណើរការ**

បែងចែកសិស្សជា៥ទៅ៦ក្រុមតាមស្ថានភាពជាក់ស្តែង ដោយក្នុង១ក្រុមៗត្រូវមានអ្នកចូលរួមធ្វើពិសោធចំនួនបីនាក់៖

១- អ្នកតេស្ត[4]

២- អ្នកធ្វើតេស្ត[5]

៣- អ្នកកត់ត្រាទិន្នន័យ

រៀបចំទឹកផ្លែឈើទាំងបីប្រភេទរួមមានទឹកក្រូច ទឹកប៉ោម និងទឹកទំពាំងបាយជូរ និងសម្ភារៈពិសោធន៍គ្រប់គ្រាន់។

**សកម្មភាពទី១៖ បិទភ្នែក និងបិទច្រមុះ**

- **អ្នកតេស្ត** : យកក្រមាចងបិទភ្នែកឱ្យបានជិតល្អ (កុំចងតឹងពេក) រួចយកដៃបិទច្រមុះ
- **អ្នកធ្វើតេស្ត** : យកបំពង់បឺត បឺត/បូម យកទឹកផ្លែឈើ (ប្រភេទមួយណាមុនក៏បាន) បន្តក់មួយតំណក់ចូលក្នុងមាត់អ្នកតេស្តរួចប្រាប់ឈ្មោះទឹកផ្លែឈើ (**អ្នកតេស្ត** ហាមលាដៃចេញពីច្រមុះបើមិនទាន់ប្រាប់ពីឈ្មោះទឹកផ្លែឈើដែលកំពុងធ្វើតេស្តទេ)។
- **អ្នកកត់ត្រាទិន្នន័យ** : ត្រូវសង្កេតអ្នកធ្វើតេស្តឱ្យបានច្បាស់លាស់ថា តើគាត់បានជ្រើសរើសយករសជាតិទឹកផ្លែឈើមួយណា រួចកត់ត្រាចម្លើយអ្នកតេស្ត។ នៅពេលដែលគាត់ប្រាប់ពីរសជាតិនិងឈ្មោះទឹកផ្លែឈើរួចរាល់ សូមកត់ត្រាចម្លើយអ្នកតេស្តចូលក្នុងតារាង។
- **អ្នកតេស្ត** : រៀងរាល់តេស្តទឹកផ្លែឈើណាមួយរួចរាល់ ត្រូវខ្ពុរមាត់ចេញម្តង និងពិសាទឹកបន្តិចដើម្បីលាងរសជាតិចេញ។
- បន្ទាប់មក អ្នកតេស្ត អ្នកធ្វើតេស្ត និងអ្នកកត់ត្រាទិន្នន័យ ធ្វើដូចលំនាំខាងលើ សម្រាប់តេស្តរសជាតិទឹកផ្លែឈើបន្តបន្ទាប់ទៀត។

**សកម្មភាពទី២៖ បិទភ្នែក និងបើកច្រមុះ** (អ្នកតេស្ត ដដែល/ហាមប្តូរអ្នកតេស្ត)

- ធ្វើដូចសកម្មភាពទី១ ប៉ុន្តែអ្នកតេស្តមិនត្រូវបានបិតច្រមុះទេ ក្នុងកំឡុងពេលសកម្មភាពតេស្តទឹកផ្លែឈើនីមួយៗ។

**គ- លទ្ធផល និងវិភាគ**

– **លទ្ធផល**

តារាងលទ្ធផល៖ ចូរបង្ហាញពីលទ្ធផលរបស់ប្អូនៗ

| សកម្មភាព | ប្រភេទទឹកផ្លែឈើ | | |
|---|---|---|---|
| | ទឹកក្រូច | ទឹកប៉ោម | ទឹកទំពាំងបាយជូរ |
| ១. បិទភ្នែក និងបិទច្រមុះ | | | |
| ២. បិទភ្នែក និងបើកច្រមុះ | | | |

– **វិភាគ**

១- ចូរប្រៀបធៀបលទ្ធផលទាំងពីរសកម្មភាព (សកម្មភាពបិតភ្នែកបិតច្រមុះ និងសកម្មភាពបិតភ្នែកបើកច្រមុះ)។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

[4] ***អ្នកតេស្ត*** *សំដៅលើអ្នកដែលត្រូវបានជ្រើសរើសសម្រាប់ភ្លក់រសជាតិទឹកផ្លែឈើក្នុងអំឡុងពិសោធន៍។*

[5] ***អ្នកធ្វើតេស្ត*** *សំដៅលើអ្នកដែលយកទឹកផ្លែឈើដាក់ចូលក្នុងមាត់អ្នកតេស្ត។*

២- តើវិញ្ញាណរសជាតិ និងវិញ្ញាណក្លិនមានទំនាក់ទំនងគ្នាដូចម្ដេច?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៣- តើយើងត្រូវថែរក្សាសរីរាង្គវិញ្ញាណដូចម្ដេច?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៤- ហេតុអ្វីយើងចាំបាច់ត្រូវថែរក្សាសរីរាង្គវិញ្ញាណឱ្យបានល្អ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

**ឃ- សន្និដ្ឋាន**

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

**ង- សំណួរពង្រីកចំណេះដឹង**

១- តើវិញ្ញាណគំហើញមានទំនាក់ទំនងជាមួយវិញ្ញាណរសជាតិ និងវិញ្ញាណក្លិនដូចម្ដេច?

២- តើសារជាតុគីមីក្នុងអាហារត្រូវបានបកប្រែ ដើម្បីផ្ដល់ជារសជាតិផ្សេងៗដូចម្ដេច?

# ប្រធានបទទី៣៖ សង្កេតឥទ្ធិពលអាំងតង់ស៊ីតេពន្លឺទៅលើរន្ធប្រស្រីភ្នែក

## ៣.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូត្រូវអានសេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- អានបញ្ជីត្រួតពិនិត្យ (☑Check List) ខាងក្រោមឱ្យបានយល់ច្បាស់។

២- រៀប ឬប្រមូលសម្ភារៈ និងឧបករណ៍មួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការពិសោធន៍ កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់។

៣- សាកល្បងអនុវត្តដំណើរការពិសោធឱ្យបានស្ទាត់ នៅមុនពេលថ្នាក់រៀនចាប់ផ្តើម។

៤- ចែកសន្លឹកកិច្ចការពិសោធន៍ និងផ្ញើវីដេអូណែនាំពិសោធន៍នេះទៅឱ្យសិស្សនៅមុនពេលបង្រៀនមួយថ្ងៃយ៉ាងតិច ដោយអនុវត្តបែបថ្នាក់រៀនត្រឡប់ (Flipped classroom)។

៥- ត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់តួនាទីសមាជិក និងរយៈពេលឱ្យបានច្បាស់លាស់។

៦- ត្រូវណែនាំសិស្សឱ្យយកចិត្តទុកដាក់លើការប្រើប្រាស់ពិល ចៀសវាការបញ្ចាំងពិលដាក់ចំប្រស្រីភ្នែក។

៧- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃខាងក្រោម៖

- ☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
- ☐ ឆ្លើយសំណួរផ្ទាល់មាត់
- ☐ ធ្វើបទបង្ហាញជាក្រុម
- ☐ កម្មវិធីវាយតម្លៃឌីជីថល (ឧទាហរណ៍៖ Kahoot, Quizizz, Blooket, Padlet...)។

៨- ផ្ទៀងផ្ទាត់បញ្ជីត្រួតពិនិត្យ (☑) លើចំណុចទាំងឡាយណាដែលជាសកម្មភាពសមស្របតាមប្រធានបទ។

*សូមចូលទៅកាន់វីដេអូពិសោធន៍តាមតំណភ្ជាប់នេះ*

### ៣.២- បញ្ជីត្រួតពិនិត្យ (☑ Check List)

គ្រូនិងសិស្សត្រូវត្រៀមទៅតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ ក្នុងអំឡុងពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** (☑ Check List) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ជំពូក៣៖ តម្រូវផ្សេងៗរបស់សារពាង្គកាយ<br>មេរៀនទី២៖ សរីរាង្គវិញ្ញាណ ទំព័រទី៧៦-៨៣<br>☐ បានបង្រៀនរួចហើយ<br>**ប្រធានបទ៖ សង្កេតឥទ្ធិពលអាំងតង់ស៊ីតេពន្លឺទៅលើរន្ធប្រស្រីភ្នែក**<br>☐ បានត្រៀមសម្ភារៈរួចរាល់រួមមាន៖ ពិលពេទ្យ ឬ ពិលដែលមានពន្លឺពណ៌ពងមាន់ ចំនួន១សម្រាប់សិស្ស១ក្រុម កៅអី២សម្រាប់សិស្ស១ក្រុម សមាជិកប្រតិបត្តិមានចំនួន ៣នាក់ក្នុង១ក្រុម<br>☐ បានរៀបចំឯកសារស្ដីពីដំណើរការសង្កេតឥទ្ធិពលអាំងតង់ស៊ីតេពន្លឺទៅលើរន្ធប្រស្រីភ្នែក សម្រាប់សិស្ស និងបានចែកឱ្យសិស្សរួចរាល់<br>☐ បានត្រៀមវីដេអូដំណើរការសង្កេតឥទ្ធិពលអាំងតង់ស៊ីតេពន្លឺទៅលើរន្ធប្រស្រីភ្នែក និងបានផ្ដល់ឱ្យសិស្សរួចរាល់<br>☐ បានត្រៀមសន្លឹកកិច្ចការ ឬឧបករណ៍វាយតម្លៃលើប្រធានបទនេះរួចរាល់<br>☐ បានបែងចែកសិស្សជាក្រុម(ក្រុមនីមួយៗមានសមាជិកអាច ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្ដែង) ដែលមានតួនាទីសម្រាប់សមាជិកម្នាក់ៗ ហើយសមាជិក៣នាក់ត្រៀមរួចរាល់សម្រាប់ការងារប្រតិបត្តិ។ | ☐ បានរៀនទ្រឹស្ដីមេរៀនរួចហើយ<br>☐ ស្វែងយល់ពីឥទ្ធិពលអាំងតង់ស៊ីតេពន្លឺទៅលើរន្ធប្រស្រីភ្នែក ដែលគ្រូបានចែកឱ្យ។<br>☐ បានរកសម្ភារៈគ្រប់គ្រាន់<br>☐ បានមើលវីដេអូដំណើរការសង្កេតឥទ្ធិពលអាំងតង់ស៊ីតេពន្លឺទៅលើរន្ធប្រស្រីភ្នែក<br>☐ បានរៀបចំបង្កើតក្រុមនិងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់។ |
| **ក្នុងអំឡុងពិសោធន៍** (☑ Check List) | |
| **គ្រូ** | **សិស្ស** |
| ☐ រំឭកដំណើរការសង្កេតឥទ្ធិពលអាំងតង់ស៊ីតេពន្លឺទៅលើរន្ធប្រស្រីភ្នែកឡើងវិញ<br>☐ សម្របសម្រួលតាមក្រុម៖<br>– បំផុសសិស្ស<br>– បង្កើនការប្រុងប្រយ័ត្នលើការសង្កេតរន្ធប្រស្រីភ្នែករបស់សិស្សដែលត្រូវបានសង្កេត<br>– សង្កេតមើលការរីក រួមនៃរន្ធប្រស្រីភ្នែកលើករណីទាំងបី (ងងឹត ធម្មតា និងមានពន្លឺខ្លាំង) | ☐ រំឭកដំណើរការពិសោធន៍ឡើងវិញ<br>☐ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ(មានសមាជិក៣នាក់ប្រតិបត្តិនេះ)<br>☐ សង្កេត ពិភាក្សា និង កត់ត្រាលើការរីក ឬរួមនៃរន្ធប្រស្រីភ្នែកលើករណីទាំងបីនៃពន្លឺ (ងងឹត ធម្មតា និងមានពន្លឺខ្លាំង)<br>☐ សម្អាតសម្ភារៈ និងរៀបចំកៅអីទុកដាក់ឱ្យបានរៀបរយ<br>☐ បោសសម្អាតបន្ទប់ |

| | |
|---|---|
| ☐ ឱ្យសិស្សសរសេររបាយការណ៍នៅក្នុងសន្លឹកកិច្ចការពិសោធន៍ជាបុគ្គល ឬក្រុម។ | ☐ សរសេររបាយការណ៍។ |
| **ក្រោយពិសោធន៍** ( ☑ Check List ) | |
| **គ្រូ** | **សិស្ស** |
| ☐ ប្រមូលសន្លឹកកិច្ចការពិសោធន៍តាមក្រុមនីមួយៗ និងដាក់ពិន្ទុ<br>- **វាយតម្លៃ៖ គ្រូអាចឱ្យសិស្ស**<br>☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>☐ ឆ្លើយសំណួរផ្ទាល់មាត់<br>☐ ធ្វើបទបង្ហាញ<br>☐ ឆ្លើយសំណួរក្នុងកម្មវិធីវាយតម្លៃឌីជីថល ( ឧទាហរណ៍៖ Kahoot, Quizizz, Blooket, Padlet... )។ | ☐ ប្រគល់សន្លឹកកិច្ចការពិសោធន៍ឱ្យគ្រូ<br>- **កិច្ចការវាយតម្លៃ៖**<br>☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>☐ ឆ្លើយសំណួរផ្ទាល់មាត់<br>☐ ធ្វើបទបង្ហាញ<br>☐ ឆ្លើយសំណួរក្នុងកម្មវិធីវង្វាយតម្លៃឌីជីថល ( ឧទាហរណ៍៖ Kahoot, Quizizz, Blooket, Padlet... )។ |

## ៣.៣- សន្លឹកកិច្ចការពិសោធន៍

## ប្រធានបទ៖ សង្កេតឥទ្ធិពលអាំងតង់ស៊ីតេពន្លឺទៅលើរន្ធប្រស្រីភ្នែក

### ៣.៣.១- សេចក្ដីផ្ដើម

ភ្នែកជាសរីរាង្គគំហើញមួយដ៏សំខាន់របស់មនុស្សដែលផ្ដល់ព័ត៌មានបានច្រើនជាង ៧០%[6] ពីពិភពខាងក្រៅ។ ភ្នែកមាននាទីសំខាន់ក្នុងការប្រមូលផ្ដុំពន្លឺពីមជ្ឈដ្ឋានជុំវិញហើយបំប្លែងជាព័ត៌មានរួចបញ្ជូនទៅកាន់ខួរក្បាល ដើម្បីវិភាគព័ត៌មាននោះ។ គ្រាប់ភ្នែកមនុស្សមានភ្នាស៣ស្រទាប់គឺ៖ ស្ក្លេរ៉ូទិច កូរ៉ូអ៊ីត និងរេទីន។ ប្រស្រីភ្នែកកើតពីសាច់ដុំរលីងដែលជាជាតិពណ៌របស់ភ្នែក។ ជាតិពណ៌នេះស្ថិតក្នុងសាច់ដុំរលីងនៃប្រស្រីភ្នែកដែលផ្ដល់ពណ៌ ធ្វើឱ្យប្រស្រីភ្នែកមានពណ៌ខ្មៅតខៀវ ប្រផេះ និងបៃតង។ ប្រស្រីភ្នែកជាផ្នែកពណ៌នៃគ្រាប់ភ្នែកមាននាទីតម្រូវសម្របតម្រូវបរិមាណពន្លឺចូលទៅក្នុងភ្នែកដោយស្វ័យប្រវត្តិ។ តើអាំងតង់ស៊ីតេពន្លឺមានឥទ្ធិពលទៅលើរន្ធប្រស្រីភ្នែកដូចម្ដេច?

### ៣.៣.២- វត្ថុបំណង

- **វិជ្ជាសម្បទា :** ពន្យល់ពីបម្រែបម្រួលរន្ធប្រស្រីភ្នែកក្រោមឥទ្ធិពលពន្លឺបានច្បាស់លាស់ តាមរយៈការសង្កេត និងពិភាក្សាក្រុម។
- **បំណិនសម្បទា :** វិភាគពីឥទ្ធិពលអាំងតង់ស៊ីពន្លឺទៅលើបម្រែបម្រួលរន្ធប្រស្រីភ្នែកបានត្រឹមត្រូវតាមរយៈការសង្កេត។
- **ចរិយាសម្បទា :** ប្រុងប្រយ័ត្នជាប់ជានិច្ចក្នុងការការពារភ្នែកពីពន្លឺខ្លាំងពេកឬខ្សោយពេក និងពីការប៉ះទង្គិចផ្សេងៗ។

### ៣.៣.៣- វិធីសាស្ត្រ

**ក- សម្ភារៈ** ពិលមានពន្លឺពណ៌ពងមាន់ចំនួន១ និងកៅអីចំនួន២ក្នុងមួយក្រុម។

**ខ- ដំណើរការ**

១- ក្រុមសិស្សនីមួយៗមានសមាជិក៣នាក់សម្រាប់ធ្វើការងារប្រតិបត្តិ៖

- អ្នកទី១ ជាអ្នកដែលត្រូវបានគេសង្កេតរន្ធប្រស្រីភ្នែក
- អ្នកទី២ ជាអ្នកសង្កេតរន្ធប្រស្រីភ្នែករបស់អ្នកទី១ និង
- អ្នកទី៣ ជាអ្នកបញ្ចាំងពន្លឺពិលលើអ្នកទី១។

២- ក្នុងដំណើរការសង្កេតនេះត្រូវឱ្យអ្នកទី២ ពិនិត្យលើ៣លក្ខខណ្ឌជាក់លាក់គឺ៖

- លក្ខខណ្ឌងងឹត
- ពន្លឺធម្មតា
- និងពន្លឺខ្លាំង(ប្រើពន្លឺពិល)។

៣- លក្ខខណ្ឌងងឹតទៅពន្លឺធម្មតា៖

- អ្នកដែលត្រូវបានគេសង្កេត ត្រូវយកដៃទាំងពីរខ្ទប់/គ្រប(មិនឱ្យប៉ះគ្របកភ្នែក)ពីលើប្រឡង់ភ្នែកទាំង២ឱ្យជិតល្អ ដោយរក្សាភ្នែកបើកធម្មតារយៈពេល១នាទី (ហាមបិទភ្នែក និងសង្កត់លើគ្រាប់ភ្នែក) ចំណែកអ្នកសង្កេតវិញ ត្រូវរង់ចាំតាមដានសង្កេតរន្ធប្រស្រីភ្នែកជាប់ជានិច្ច។
- រយៈពេល១នាទីក្រោយមក អ្នកដែលត្រូវបានគេសង្កេត(អ្នកទី១)ដកដៃចេញពីភ្នែកដោយយឺតៗ ដើម្បីឱ្យអ្នកសង្កេត(អ្នកទី២) តាមដានពិនិត្យរន្ធប្រស្រីភ្នែកបានភ្លាមៗ។ អ្នកសង្កេតត្រូវបន្តសង្កេតរន្ធប្រស្រីភ្នែករហូតដល់ពេលមានប្រែប្រួលទំហំរន្ធប្រសីភ្នែកមកសភាពដើមវិញ។

៤- លក្ខខណ្ឌពន្លឺធម្មតាទៅពន្លឺខ្លាំង៖

[6] *THE EYE: SUPER ORGAN AND A KEY SOURCE OF INFORMATION - VPS (viewpointsystem.com).*

- អ្នកសង្កេតត្រូវបន្តសង្កេតពីបម្រែបម្រួលទំហំរន្ធប្រស្រីភ្នែកពីសភាពពន្លឺធម្មតាទៅពន្លឺខ្លាំងយ៉ាងប្រុងប្រយ័ត្ន
- អ្នកបញ្ចាំងពន្លឺពិល(អ្នកទី៣)ត្រូវបញ្ចាំងពន្លឺភ្លើងពិលបញ្ឆិតលើស្មាអ្នកទី១ រួចរំកិលពន្លឺបន្តិចម្តងៗខិតទៅចុងនៃប្រឡង់ភ្នែកដោយមិនឱ្យចំពីលើកែវភ្នែកឡើយ។
- អ្នកសង្កេត(អ្នកទី២)ត្រូវតាមដានពិនិត្យរន្ធប្រស្រីភ្នែកឱ្យបានច្បាស់លាស់ រួចកត់ត្រាពីបម្រែបម្រួលទំហំរន្ធប្រសីភ្នែកក្នុងលក្ខខណ្ឌទាំង៣ខាងលើនៅក្នុងតារាងកត់ត្រាឱ្យបានត្រឹមត្រូវ។

**គ- លទ្ធផល និងវិភាគ**

- **លទ្ធផល**

| លក្ខខណ្ឌពន្លឺ | បម្រែបម្រួលរន្ធប្រស្រីភ្នែក |
|---|---|
| ងងឹត | |
| ពន្លឺធម្មតា | |
| ពន្លឺខ្លាំង | |

- **វិភាគ**

១- តើបម្រែបម្រួលអាំងតង់ស៊ីតេពន្លឺមានឥទ្ធិពលដូចម្តេចទៅលើរន្ធប្រស្រីភ្នែក?

..............................................................................................................

..............................................................................................................

២- ហេតុអ្វីបានជារន្ធប្រស្រីភ្នែកមានការប្រែប្រួលនៅក្នុងលក្ខខណ្ឌនីមួយៗ?

..............................................................................................................

..............................................................................................................

..............................................................................................................

៣- ហេតុអ្វីពន្លឺខ្លាំងធ្វើឱ្យភ្នែកស្រវាំង?

..............................................................................................................

..............................................................................................................

..............................................................................................................

៤- តើយើងត្រូវធ្វើដូចម្តេច ដើម្បីថែរក្សាសុខភាពភ្នែកឱ្យបានល្អ?

..............................................................................................................

..............................................................................................................

..............................................................................................................

**ឃ- សន្និដ្ឋាន**

..............................................................................................................

..............................................................................................................

..............................................................................................................

**ខ- សំណួរពង្រីកចំណេះដឹង**

១- ចូរសង្កេតពីចំណុចខ្វាក់របស់រន្ធប្រស្រីភ្នែក។

២- តើរូបភាពត្រូវបានឆ្លងកាត់ និងបកប្រែដោយកែវភ្នែកដូចម្តេច?

៣- តើធ្វើដូចម្តេច ដើម្បីអាចដឹងថាភ្នែករបស់ថ្នាក់បក្សីអាចមើលឃើញបានឆ្ងាយជាងភ្នែករបស់ថ្នាក់សត្វឆ្អឹងកងផ្សេងៗទៀត?

# ប្រធានបទទី៤៖ សង្កេតរុក្ខជាតិម៉ូណូកូទីលេដុង និងរុក្ខជាតិឌីកូទីលេដុង

## ៤.១- សេចក្ដីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូត្រូវអានសេចក្ដីណែនាំខ្លីដូចខាងក្រោម៖

១- អានបញ្ជីត្រួតពិនិត្យ (☑ Check List) ខាងក្រោមឱ្យបានយល់ច្បាស់។

២- រៀបឬប្រមូលសម្ភារៈ និងឧបករណ៍មួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការពិសោធន៍ កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់។

៣- សាកល្បងអនុវត្តដំណើរការពិសោធឱ្យបានស្ទាត់ នៅមុនពេលថ្នាក់រៀនចាប់ផ្ដើម។

៤- ចែកសន្លឹកកិច្ចការពិសោធន៍ និងផ្ញើវីដេអូណែនាំពិសោធន៍នេះទៅឱ្យសិស្សនៅមុនពេលបង្រៀនមួយថ្ងៃយ៉ាងតិចដោយអនុវត្តបែបថ្នាក់រៀនត្រឡប់ (Flipped classroom)។

៥- ការបង្រៀនបែបថ្នាក់រៀនសកម្មសម្រាប់មេរៀននេះជាជម្រើសដ៏ល្អបំផុត។

៦- ត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់តួនាទីសមាជិក និងរយៈពេលឱ្យបានច្បាស់លាស់។

៧- ត្រូវណែនាំសិស្សឱ្យយកនូវសម្ភារៈដែលត្រូវការឱ្យបានគ្រប់គ្រាន់។

៨- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃខាងក្រោម៖

- ☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
- ☐ ឆ្លើយសំណួរផ្ទាល់មាត់
- ☐ ធ្វើបទបង្ហាញជាក្រុម
- ☐ កម្មវិធីវាយតម្លៃឌីជីថល (ឧទាហរណ៍៖ Kahoot, Quizizz, Blooket, Padlet...)។

៩- ផ្ទៀងផ្ទាត់បញ្ជីត្រួតពិនិត្យ (☑) លើចំណុចទាំងឡាយណាដែលជាសកម្មភាពសមស្របតាមប្រធានបទ។

១០- អាចជ្រើសរើសរុក្ខជាតិនិងផ្នែកផ្សេងៗរបស់វាទៅតាមប្រភេទរុក្ខជាតិដែលអ្នកអាចរកបាននៅតាមមូលដ្ឋានផ្ទាល់របស់អ្នក។

*សូមចូលទៅកាន់វីដេអូពិសោធន៍តាមតំណភ្ជាប់នេះ*

## ៤.២- បញ្ជីត្រួតពិនិត្យ (☑ Check List)

គ្រូ និងសិស្សត្រូវត្រៀមទៅតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ ក្នុងអំឡុងពិសោធន៍ និងក្រោយពិសោធន៍។

| | |
|---|---|
| **មុនពិសោធន៍** (☑ Check List) | |
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក១៖ ស៊ីមណ្ឌស្លែម និងអង់ស្យូស្លែម<br>មេរៀនទី២៖ អង់ស្យូស្លែម ទំព័រទី១៥-១៦<br>☐ បានបង្រៀនរួចហើយ<br>**ប្រធានបទ៖ សង្កេតរុក្ខជាតិម៉ូណូកូទីលេដូន និងរុក្ខជាតិឌីកូទីលេដូន**<br>☐ សម្ភារៈបានរៀបចំរួចរាល់រួមមាន គ្រាប់រុក្ខជាតិមួយចំនួន ស្លឹករុក្ខជាតិស្រស់មួយចំនួន ផ្ការុក្ខជាតិមួយចំនួន ឫស និងដើមមួយចំនួន។<br>☐ បានចែកសន្លឹកកិច្ចការអំពីការសង្កេតរុក្ខជាតិម៉ូណូកូទីលេដូន និងឌីកូទីលេដូនឱ្យសិស្សរួចរាល់<br>☐ បានផ្តល់វីដេអូដំណើរការសង្កេតរុក្ខជាតិម៉ូណូកូទីលេដូន និងឌីកូទីលេដូនឱ្យសិស្សរួចរាល់<br>☐ បានបែងចែកក្រុម និងបានកំណត់តួនាទី សមាជិកម្នាក់ៗបានច្បាស់លាស់ (សមាជិកអាច ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។ | ☐ បានរៀនទ្រឹស្តីមេរៀនរួចហើយ<br>☐ បានរក និងប្រមូលសម្ភារៈគ្រប់គ្រាន់<br>☐ ទទួលបានសន្លឹកកិច្ចការនិងបានស្វែងយល់<br>☐ បានមើលវីដេអូការសង្កេតរុក្ខជាតិម៉ូណូកូទីលេដូន និង ឌីកូទីលេដូន និងឯកសារពាក់ព័ន្ធរួចហើយ<br>☐ បានរៀបចំបង្កើតក្រុមនិងកំណត់តួនាទីសមាជិកក្រុមបានច្បាស់លាស់។ |
| **ក្នុងអំឡុងពិសោធន៍** (☑ Check List) | |
| **គ្រូ** | **សិស្ស** |
| ☐ រំឭកដំណើរការសង្កេតរុក្ខជាតិម៉ូណូកូទីលេដូន និងឌីកូទីលេដូនឡើងវិញ<br>☐ សម្របសម្រួលតាមក្រុម៖<br>– បំផុសសិស្ស<br>– សង្កេតពីលក្ខណៈនៃសរីរាង្គនីមួយៗរបស់រុក្ខជាតិម៉ូណូកូទីលេដូន និងឌីកូទីលេដូន និងការពិភាក្សារបស់សិស្សតាមក្រុម<br>☐ ឱ្យសិស្សបំពេញសន្លឹកកិច្ចការ។ | ☐ រំឭកដំណើរការពិសោធន៍ឡើងវិញ<br>☐ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>☐ សង្កេត ប្រៀបធៀប ពិភាក្សា និងកត់ត្រាពីលក្ខណៈនៃសរីរាង្គនីមួយៗរបស់រុក្ខជាតិម៉ូណូកូទីលេដូន និងឌីកូទីលេដូន<br>☐ សង្កេត ប្រៀបធៀប និងបំពេញសន្លឹកកិច្ចការ<br>☐ សម្អាតសម្ភារៈ និង រៀបចំកៅអីទុកដាក់ឱ្យ បានរៀបរយ<br>☐ បោសសម្អាតបន្ទប់។ |
| **ក្រោយពិសោធន៍** (☑ Check List) | |
| **គ្រូ** | **សិស្ស** |
| ☐ ប្រមូលសន្លឹកកិច្ចការពិសោធន៍តាមក្រុមនីមួយៗ និងដាក់ពិន្ទុ<br>- **វាយតម្លៃ៖** គ្រូអាចឱ្យសិស្ស<br>☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>☐ ឆ្លើយសំណួរផ្ទាល់មាត់ | ☐ ប្រគល់សន្លឹកកិច្ចការពិសោធន៍ឱ្យគ្រូ<br>- **កិច្ចការវាយតម្លៃ៖**<br>☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>☐ ឆ្លើយសំណួរផ្ទាល់មាត់ |

| | |
|---|---|
| □ ធ្វើបទបង្ហាញ<br>□ ឆ្លើយសំណួរក្នុងកម្មវិធីវាយតម្លៃឌីជីថល (ឧទាហរណ៍៖ Kahoot, Quizizz, Blooket, Padlet...)។ | □ ធ្វើបទបង្ហាញ<br>□ ឆ្លើយសំណួរក្នុងកម្មវិធីវង្វាយតម្លៃឌីជីថល (ឧទាហរណ៍៖ Kahoot, Quizizz, Blooket, Padlet...)។ |

## ៤.៣- សន្លឹកកិច្ចការពិសោធន៍

### ប្រធានបទ៖ សង្កេតរុក្ខជាតិម៉ូណូកូទីលេដូន និងរុក្ខជាតិឌីកូទីលេដូន

### ៤.៣.១- សេចក្តីផ្តើម

នៅជុំវិញខ្លួនយើង រុក្ខជាតិមួយចំនួនដូចជាដូង អំពៅ ពោត ចេក ប្រទាល ស្រូវ...មានលក្ខណៈប្រហាក់ប្រហែលគ្នា ស្របពេលដែលក្រុមរុក្ខជាតិមួយចំនួនទៀតដូចជាស្វាយ ក្រូច ទៀប...ហាក់មានលក្ខណៈផ្សេងទៀតគួរឱ្យកត់សម្គាល់។ ការសម្គាល់ទៅលើលក្ខណៈខុសៗគ្នារបស់រុក្ខជាតិនៅលើផែនដី ជាមធ្យោបាយមួយសម្រាប់ធ្វើចំណែកថ្នាក់រុក្ខជាតិ។ រុក្ខវិទូបានបែងចែករុក្ខជាតិមានផ្កាជាពីរក្រុមគឺម៉ូណូកូទីលេដូន និងឌីកូទីលេដូន។ ស្រូវ អំពៅ និងដូងជាដើមស្ថិតនៅក្នុងក្រុមរុក្ខជាតិម៉ូណូកូទីលេដូន ហើយកកោះ ផ្ទឹក ក្រូច និងស្វាយ....ស្ថិតនៅក្នុងក្រុមរុក្ខជាតិឌីកូទីលេដូន។ តើរុក្ខជាតិម៉ូណូកូទីលេដូន និងរុក្ខជាតិឌីកូទីលេដូនមានលក្ខណៈខុសគ្នាដូចម្តេច?



តើយើងធ្វើចំណាត់ថ្នាក់ក្រុមរុក្ខជាតិម៉ូណូកូទីលេដូន និងឌីកូទីលេដូនដូចម្តេច?

### ៤.៣.២- វត្ថុបំណង

- **វិជ្ជាសម្បទា :** រៀបរាប់ពីលក្ខណៈរុក្ខជាតិម៉ូណូកូទីលេដូន និងរុក្ខជាតិឌីកូទីលេដូនបានត្រឹមត្រូវតាមរយៈការសង្កេត។
- **បំណិនសម្បទា :** ប្រៀបធៀបលក្ខណៈរុក្ខជាតិម៉ូណូកូទីលេដូន និងរុក្ខជាតិឌីកូទីលេដូនបានត្រឹមត្រូវតាមរយៈការសង្កេត។
- **ចរិយាសម្បទា :** មានគំនិតច្នៃប្រឌិតក្នុងការសិក្សាស្រាវជ្រាវអំពីរុក្ខជាតិនៅជុំវិញខ្លួនក្នុងជីវិតរស់នៅប្រចាំថ្ងៃ។

### ៤.៣.៣- វិធីសាស្ត្រ

**ក- សម្ភារៈ**

| | | | | |
|---|---|---|---|---|
|  ១. ឫសរុក្ខជាតិមួយចំនួន |  ២. គ្រាប់រុក្ខជាតិមួយចំនួន |  ៣. ស្លឹករុក្ខជាតិមួយចំនួន |  ៤. ផ្ការុក្ខជាតិមួយចំនួន |  ៥. ដើមរុក្ខជាតិមួយចំនួន |
|  ៦. មីក្រូទស្សន៍ |  ៧. កែវបេសែ |  ៨. កែវអែកឡែន |   ៩. ឡាម |  ១០. ម្សៅល័ក្ត |

| | | | | |
|---|---|---|---|---|
|  |  |  |  |  |
| ១១. ក្រដាសជូតមាត់ | ១២. ប្រអប់ប៉េទ្រី | ១៣. តង្កៀប | ១៤. ទឹកសុទ្ធ | ១៥. ថាស |

**ខ- ដំណើរការ**

១- ដំបូងយើងសង្កេតមើលគ្រាប់រុក្ខជាតិម៉ូណូកូទីលេដូន និងរុក្ខជាតិឌីកូទីលេដូន។

២- សង្កេតស្លឹករុក្ខជាតិម៉ូណូកូទីលេដូន និងឌីកូទីលេដូន។

៣- សង្កេតទៅលើឫសនៃរុក្ខជាតិម៉ូណូកូទីលេដូន និងឌីកូទីលេដូន។

៤- យកផ្ការុក្ខជាតិទាំង២ក្រុមមកសង្កេតស្រទាប់។

៥- ផលិតសូលុយស្យុងល័ក្តពណ៌ក្រហម រួចយកដើមរុក្ខជាតិទាំងពីរក្រុមទៅត្រាំក្នុងសូលុយស្យុងនេះពី ៣០ នាទីទៅមួយម៉ោង ឬច្រើនជាងនេះទៅតាមប្រភេទរុក្ខជាតិ រួចធ្វើខ្នាត់ទទឹងដើមរុក្ខជាតិទាំងពីររុក្ខជាតិម៉ូណូកូទីលេដូន និងឌីកូទីលេដូន។

៦- យកដើមទៅពិនិត្យដោយប្រើមីក្រូទស្សន៍។

**គ- លទ្ធផល និងវិភាគ**

– **លទ្ធផល**

ចូរគូររូបផ្នែកផ្សេងៗរបស់រុក្ខជាតិម៉ូណូកូទីលេដូន និងរុក្ខជាតិឌីកូទីលេដូនក្នុងតារាងខាងក្រោមឱ្យបានត្រឹមត្រូវ។

| **លក្ខណៈ** | **រុក្ខជាតិម៉ូណូកូទីលេដូន** | **រុក្ខជាតិឌីកូទីលេដូន** |
|---|---|---|
| គ្រាប់ | | |
| ផ្កា (ពហុគុណស្រទាប់ផ្កា) | | |
| ស្លឹក | | |

| | | |
|---|---|---|
| ឫស | | |
| បាច់សរសៃ (ដើម) | | |

– **វិភាគ**

១- ចូរប្អូនរៀបរាប់ពីលក្ខណៈរុក្ខជាតិម៉ូណូកូទីលេដូន និងរុក្ខជាតិឌីកូទីលេដូននៅក្នុងតារាងខាងក្រោម៖

| **លក្ខណៈ** | **រុក្ខជាតិម៉ូណូកូទីលេដូន** | **រុក្ខជាតិឌីកូទីលេដូន** |
|---|---|---|
| គ្រាប់ | ..............................<br>..............................<br>..............................<br>..............................<br>..............................<br>..............................<br>.............................. | ..............................<br>..............................<br>..............................<br>..............................<br>..............................<br>..............................<br>.............................. |
| ផ្កា (ពហុគុណស្រទាប់ផ្កា) | ..............................<br>..............................<br>..............................<br>..............................<br>..............................<br>..............................<br>.............................. | ..............................<br>..............................<br>..............................<br>..............................<br>..............................<br>..............................<br>.............................. |
| ស្លឹក | ..............................<br>..............................<br>..............................<br>..............................<br>..............................<br>..............................<br>.............................. | ..............................<br>..............................<br>..............................<br>..............................<br>..............................<br>..............................<br>.............................. |

| | | |
|---|---|---|
| ឫស | ……<br>……<br>……<br>……<br>……<br>…… | ……<br>……<br>……<br>……<br>……<br>…… |
| បាច់សរសៃនាំ (ដើម) | ……<br>……<br>……<br>……<br>……<br>…… | ……<br>……<br>……<br>……<br>……<br>…… |

២- ហេតុអ្វីបានជាខ្នាត់ទទឹងដើម និងស្លឹករុក្ខជាតិប្រេពណ៌ ក្រោយពេលត្រាំក្នុងសូលុយស្យុងល័ក្តក្រហម?

……

……

……

……

៣- ចូរប្រាប់ឈ្មោះរុក្ខជាតិ ដែលប្អូនធ្លាប់ស្គាល់នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។

*រុក្ខជាតិម៉ូណូកូទីលេដូន៖*

……

……

……

……

*រុក្ខជាតិឌីកូទីកូទីលេដូន៖*

……

……

……

……

**ឃ- សន្និដ្ឋាន**

……

……

……

……

**ង- សំណួរពង្រីកចំណេះដឹង**

១- ចូរសង្កេត និងប្រៀបធៀបលក្ខណៈនៃស្តូម៉ាតរុក្ខជាតិម៉ូណូកូទីលេដូន និងស្តូម៉ាតរុក្ខជាតិឌីកូទីលេដូន។

២- ចូរសង្កេត និងប្រៀបធៀបលក្ខណៈបាច់សរសៃនាំឫសរុក្ខជាតិម៉ូណូកូទីលេដូន និងឫសរុក្ខជាតិឌីកូទីលេដូន។

# ប្រធានបទទី៥៖ ប្រៀបធៀបខួរក្បាលសត្វឆ្អឹងកង

## ៥.១- សេចក្ដីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំការធ្វើពិសោធប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូត្រូវអានសេចក្ដីណែនាំខ្លីដូចខាងក្រោម៖

១- អានតារាង (☑ Check List) ខាងក្រោមឱ្យបានយល់ច្បាស់។

២- រៀបចំ ឬប្រមូលសម្ភារៈ និងឧបករណ៍ដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការពិសោធន៍ កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់។

៣- ណែនាំសិស្ស ឱ្យមានការបម្រុងប្រយ័ត្នខ្ពស់ ទាំងមុនពេល ក្នុងអំឡុងពេល និងក្រោយពិសោធន៍រួចជាពិសេសឧបករណ៍មានមុខស្រួច។

៤- សាកល្បងអនុវត្តធ្វើការសង្កេតប្រៀបធៀបទម្រង់ខួរក្បាលសត្វឆ្អឹងកងនៅមុនពេលថ្នាក់រៀនចាប់ផ្ដើមឱ្យបានស្ទាត់ជំនាញ។

៥- ចែកឱ្យសន្លឹកកិច្ចការពិសោធន៍ទៅសិស្សមួយថ្ងៃយ៉ាងតិចមុនម៉ោងអនុវត្តពិសោធ (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)។

៦- បែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទីឱ្យបានច្បាស់លាស់។

៧- ចំពោះខួរក្បាលត្រី កង្កែប កន្ធាយ មាន់ ឬទា ត្រូវលាងទឹកឱ្យស្អាតមុនយកទៅស្ងោរ។ កំណត់រយៈពេលស្ងោរឱ្យបានត្រឹមត្រូវ ជៀសវាងឆ្អិនពេក ឬស្ទើរឆ្អិន ធ្វើឱ្យមាន នាំឱ្យពិបាកបកទាញយកខួរចេញ។

៨- ការបេកយកសំណុំខួរក្បាលថ្នាក់សត្វនីមួយៗត្រូវមានបម្រុងប្រយ័ត្នខ្ពស់កុំឱ្យប៉ះ ចៀសវាងបែក ឬខូចសរីរាង្គណាមួយ។

៩- ចំពោះខួរជ្រូកត្រូវចំហុយ និងប្រុងប្រយ័ត្នរាល់ពេលផ្លាស់ទី។

១០- ជ្រើសខួរក្បាលសត្វឆ្អឹងកងប្រភេទផ្សេងក៏បានឱ្យតែស្ថិតក្នុងថ្នាក់សត្វឆ្អឹងកងដូចគ្នា។

១១- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោម៖

- ☐ ឱ្យសិស្សឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
- ☐ ឱ្យសិស្សឆ្លើយសំណួរផ្ទាល់មាត់
- ☐ ឱ្យសិស្សធ្វើបទបង្ហាញជាក្រុម
- ☐ ឱ្យសិស្សកម្មវិធីវាយតម្លៃឌីជីថល (ឧទាហរណ៍៖ Kahoot, Quizizz, Blooket, Padlet...)។

*សូមចូលទៅកាន់វីដេអូពិសោធន៍តាមតំណភ្ជាប់នេះ*

## ៥.២- បញ្ជីត្រួតពិនិត្យ (☑ Check List)

គ្រូ និងសិស្សត្រូវត្រៀមទៅតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ ក្នុងអំឡុងពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** (☑ Check List) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក៣៖ តម្រូវផ្សេងៗរបស់សារពាង្គកាយ<br>មេរៀនទី១៖ តម្រូវប្រសាទ ទំព័រ៦០-៦១<br>☐ បានបង្រៀនរួចហើយ<br>**ប្រធានបទ៖ ប្រៀបធៀបខួរក្បាលសត្វឆ្អឹងកង**<br>☐ បានត្រៀមសម្ភារៈមួយចំនួនរួមមាន៖ ខួរក្បាលសត្វឆ្អឹងកង (ត្រីជៀប កង្កែប កន្ធាយ មាន់ និងជ្រូក) ជ្រញ់ ថាស ក្រដាសជូតមាត់ ចង្រ្កានហ្គាស កំប៉ុងហ្គាស ឆ្នាំង កូនកាំបិតមុខស្រួច កាំបិតកាប់សាច់ ទឹកស្អាត កញ្ច្រែង កូនតង្កៀប កូនកន្សែងជូតដៃ កន្ត្រៃ ចាន<br>☐ បានត្រៀមសន្លឹកកិច្ចការសង្កេតអំពីការប្រៀបធៀបខួរក្បាលសត្វឆ្អឹងកង និងបានចែកឱ្យសិស្សរួចរាល់<br>☐ បានត្រៀមវិធីឬសន្លឹកកិច្ចការវាយតម្លៃសិស្សរួចរាល់<br>☐ បានត្រៀមវីដេអូអំពីការសង្កេតប្រៀបធៀបខួរក្បាលសត្វឆ្អឹងកង (ត្រី កង្កែប កន្ធាយ មាន់ និងខួរក្បាលជ្រូក) និងចែកឱ្យសិស្សរួចរាល់<br>☐ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទីសមាជិកម្នាក់ៗច្បាស់លាស់ (សមាជិកអាចពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។ | ☐ បានអាន និងរៀនទ្រឹស្តីមេរៀនរួច<br>☐ បានរកសម្ភារៈពិសោធន៍គ្រប់គ្រាន់<br>☐ បានអាន និងយល់ពីដំណើរការពិសោធន៍ច្បាស់លាស់<br>☐ បានមើលវីដេអូអំពីដំណើរការពិសោធន៍ទៅតាមដំហ៊ានទីមួយៗច្បាស់លាស់<br>☐ បានរៀបចំបង្កើតក្រុម និងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់។ |
| **ក្នុងអំឡុងពិសោធន៍** (☑ Check List) | |
| **គ្រូ** | **សិស្ស** |
| ☐ រំឭកពីដំណើរការសង្កេត ការប្រៀបធៀបខួរក្បាលសត្វឆ្អឹងកងដែលមាននៅក្នុងសន្លឹកកិច្ចការឡើងវិញ<br>☐ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួច<br>☐ សម្របសម្រួលតាមក្រុម<br>– បំផុសសិស្ស<br>– បង្កើនការប្រុងប្រយ័ត្នចំពោះឧបករណ៍មុតស្រួច<br>– សង្កេត និងសម្របសម្រួលដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុម<br>☐ ឱ្យសិស្សមើលវីឌីអូអំពីសង្កេតការប្រៀបធៀបខួរក្បាលសត្វឆ្អឹងកង<br>☐ ផ្តល់គំរូរបាយការណ៍ពិសោធន៍ទៅសិស្ស(មានមួយចប់ទាំងលទ្ធផល និងសន្និដ្ឋាន)។ | ☐ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>☐ សង្កេត ពិភាក្សា និងកត់ត្រា<br>☐ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរៀបរយ។<br>☐ បោសសម្អាតបន្ទប់ពិសោធន៍<br>☐ អាន និងស្វែងយល់បន្ថែម<br>☐ មើលវីឌីអូអំពីសង្កេតការប្រៀបធៀបខួរក្បាលសត្វឆ្អឹងកង។ |
| | |

| **ក្រោយពិសោធន៍** ( ☑ Check List ) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ប្រមូលរបាយការណ៍ ឬសន្លឹកកិច្ចការនៃការសង្កេតប្រៀបធៀបខួរក្បាលសត្វឆ្អឹងកង<br>☐ **ការវាយតម្លៃ៖** គ្រូអាចឱ្យសិស្ស<br>☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>☐ ឆ្លើយសំណួរផ្ទាល់មាត់<br>☐ ធ្វើបទបង្ហាញតាមក្រុម<br>☐ កម្មវិធីវាយតម្លៃឌីជីថល ( ឧទាហរណ៍៖ Kahoot, Quizizz, Blooket, Padlet... )។ | ☐ សរសេររបាយការណ៍ និងសន្លឹកកិច្ចការពិសោធន៍<br>☐ **កិច្ចការវាយតម្លៃ៖** សិស្ស<br>☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចវាយតម្លៃ<br>☐ ឆ្លើយសំណួរផ្ទាល់មាត់<br>☐ ធ្វើបទបង្ហាញជាក្រុម។<br>☐ កម្មវិធីវាយតម្លៃឌីជីថល ( ឧទាហរណ៍៖ Kahoot, Quizizz, Blooket, Padlet... )។ |

## ៥.៣- សន្លឹកកិច្ចការពិសោធន៍

# ប្រធានបទ៖ ប្រៀបធៀបខួរក្បាលសត្វឆ្អឹងកង

### ៥.៣.១- សេចក្តីផ្តើម

ខួរក្បាលជាសរីរាង្គសំខាន់ជាងគេក្នុងប្រព័ន្ធប្រសាទ ដែលមាននាទីទទួលព័ត៌មាន ឆ្លើយតប និងតំហែរក្សាថេរលំនឹង។ តម្រូវប្រសាទសត្វឆ្អឹងកងមានការអភិវឌ្ឍខ្ពស់ មានសរីរាង្គច្រើន និងខួរក្បាលលូតលាស់ល្អដូចជាខួរធំ និងខួរតូចមានទំហំធំ លក្ខណៈស្មុគស្មាញពីថ្នាក់ត្រី ដល់ថ្នាក់ថនិកសត្វ។ ក្នុងចំណោមខួរក្បាលសត្វឆ្អឹងកងទាំងប្រាំថ្នាក់ ឃើញមានសរីរាង្គប្រាំគួរកត់សម្គាល់គឺ កំពកឃានវិញ្ញាណ អឌ្ឍគោលខួរ កំពកចក្ខុវិញ្ញាណ ខួរតូច និងខួរឆ្អឹងខ្នង ដែលមានការប្រែប្រួលរូបរាងនិងទំហំទៅតាមថ្នាក់នីមួយៗ។

តើសំណុំខួរក្បាលសត្វឆ្អឹងកងទាំងប្រាំថ្នាក់នេះមានលក្ខណៈខុសគ្នាដូចម្តេចខ្លះ?

### ៥.៣.២- វត្ថុបំណង

- **វិជ្ជាសម្បទា** : រៀបរាប់ពីសំណុំខួរក្បាលរបស់សត្វឆ្អឹងកងទាំងប្រាំថ្នាក់បានត្រឹមត្រូវ តាមរយៈការសង្កេត និងការពិភាក្សាក្រុម។
- **បំណិនសម្បទា** : ប្រៀបធៀបខួរក្បាលរបស់សត្វឆ្អឹងកងទាំងប្រាំថ្នាក់បានត្រឹមត្រូវតាមរយៈការសង្កេត។
- **ចរិយាសម្បទា** : ការពារខួរក្បាលពីការប៉ះទង្គិចផ្សេងៗ និងបរិភោគអាហារដែលមានសារធាតុចិញ្ចឹម និងវីតាមីនគ្រប់គ្រាន់ ដើម្បីជួយឱ្យខួរក្បាលមានសុខភាពល្អ។

### ៥.៣.៣- វិធីសាស្ត្រ

**ក- សម្ភារៈ**

| | | | | |
|---|---|---|---|---|
|  ១. ខួរជ្រូក |  ២. ក្បាលមាន់ |  ៣. ក្បាលកន្ធាយ |  ៤. កង្កែប |  ៥. ក្បាលត្រីដៀប |
|  ៦. ជ្រញ់ |  ៧. ថាស |  ៨. ចង្ក្រានហ្គាស+ឆ្នាំង |  ៩. ចានសម្ល |  ១០. កញ្ច្រែង |
|  ១១. ស្រោមដៃ |  ១២. ម៉ាស |  ១៣. កូនកន្សែងជូតដៃ |  ១៤. កាំបិត |  ១៥. ឈុតវះកាត់ |

**ខ- ដំណើរការ**

១- ស្ងោរក្បាលកង្កែប ក្បាលកន្ធាយ ក្បាលមាន់ និងក្បាលត្រី (១០ទៅ១៥នាទី)។

២- យកក្បាលក្បាលកង្កែប ក្បាលកន្ធាយ ក្បាលមាន់ និងក្បាលត្រី ដែលបានស្ងោររួចបៀរសាច់ និងយកឆ្អឹងចេញឱ្យបានស្អាត (ប្រុងប្រយ័ត្នកុំឱ្យប៉ះខួរក្បាលផ្នែកខាងក្នុង)។

៣- ចំហុយខួរជ្រូកដោយដាក់ក្នុងចានសម្លរួចដាក់ក្នុងឆ្នាំង (ពី៥ទៅ១០នាទី) អាស្រ័យតាមទំហំខួរដាក់ស្តែង។
៤- យកខួរក្បាលរបស់សត្វឆ្អឹងកងទាំង៥ មកតម្រៀបលើថាសដែលបានរៀបចំរួច បន្ទាប់មកធ្វើការសង្កេតពីផ្នែកផ្សេងៗ។

**គ- លទ្ធផល និងវិភាគ**

– **លទ្ធផល**

ចូរគូររូបទម្រង់ខួរក្បាលរបស់សត្វឆ្អឹងកងទាំងប្រាំថ្នាក់ និងដាក់ឈ្មោះផ្នែកផ្សេងៗឱ្យបានត្រឹមត្រូវ។

| | | |
|---|---|---|
| | | |
| ខួរត្រី | ខួរកង្កែប | ខួរកន្ធាយ |
| | | |
| ខួរមាន់ | ខួរជ្រូក | |

– **វិភាគ**

១- ចូរប្រៀបធៀបពីសំណុំខួរក្បាលរបស់សត្វឆ្អឹងកងទាំងប្រាំថ្នាក់។

..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................

២- តើយើងត្រូវធ្វើដូចម្ដេច ដើម្បីឱ្យខួរក្បាលមានសុខភាពល្អ?

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

៣- ហេតុអ្វីបានជាយើងចាំបាច់ត្រូវពាក់មួកសុវត្ថិភាពនៅវេលាពេលជិះម៉ូតូ ឬជិះកង់?

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

**ឃ- សន្និដ្ឋាន**

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

**ង- សំណួរពង្រីកចំណេះដឹង**

១- ចូរសង្កេតខួរក្បាលសត្វឆ្អឹងកងទាំងប្រាំថ្នាក់ ដោយវិធីវះកាត់ទៅ រួចកត់ត្រានូវវិធីសាស្ត្រ និងលទ្ធផលនោះ ហើយធ្វើការប្រៀបធៀបជាមួយលទ្ធផលក្នុងមេរៀននេះ។

២- តើត្រូវធ្វើដូចម្ដេច ដើម្បីរក្សាទុកសំណាកខួរក្បាលសត្វឆ្អឹងកងទាំងប្រាំថ្នាក់ឱ្យបានយូរ?

## ប្រធានបទទី៦៖ ទំនាក់ទំនងរវាងសម្រូបទឹក និងរំភាយចំហាយទឹក

### ៦.១- សេចក្ដីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូគប្បីអានសេចក្ដីណែនាំខ្លីដូចខាងក្រោម៖

១- អានបញ្ជីត្រួតពិនិត្យ (☑ Check List) ខាងក្រោមឱ្យបានយល់ច្បាស់។

២- ត្រៀមឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការពិសោធន៍ កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់។

៣- សាកល្បងអនុវត្តដំណើរការពិសោធឱ្យបានស្ទាត់ នៅមុនពេលថ្នាក់រៀនចាប់ផ្ដើម។

៤- ចែកសន្លឹកកិច្ចការពិសោធន៍ និងវីដេអូណែនាំពិសោធន៍នេះទៅឱ្យសិស្សនៅមុនពេលបង្រៀនមួយថ្ងៃយ៉ាងតិច ដោយអនុវត្តបែបថ្នាក់រៀនត្រឡប់ (Flipped classroom)។

៥- ការបង្រៀនបែបថ្នាក់រៀនសកម្មសម្រាប់មេរៀននេះជាជម្រើសដ៏ល្អបំផុត។

៦- ត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់តួនាទីសមាជិក និងរយៈពេលឱ្យបានច្បាស់លាស់។

៧- ត្រូវណែនាំសិស្សឱ្យយកចិត្តទុកដាក់ទៅលើការវាស់កម្រិតទឹក ជ្រើសរើសទំហំ និងលក្ខណៈឫសរុក្ខជាតិ បិទស្កុតលើមាត់ស៊ីឡាំងក្រិតឱ្យបានជិតល្អ រុំស្កុតមាត់ថង់ប្លាស្ទិកដែលបានគ្របស៊ីឡាំងក្រិតឱ្យជិតល្អ ដើម្បីកុំឱ្យរំភាយចំហាយទឹកចេញ។

៨- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃខាងក្រោម៖

- ☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
- ☐ ឆ្លើយសំណួរផ្ទាល់មាត់
- ☐ ធ្វើបទបង្ហាញជាក្រុម
- ☐ កម្មវិធីវាយតម្លៃឌីជីថល (ឧទាហរណ៍៖ Kahoot, Quizizz, Blooket, Padlet...)។

៩- ផ្ទៀងផ្ទាត់បញ្ជីត្រួតពិនិត្យ (☑) លើចំណុចទាំងឡាយណាដែលជាសកម្មភាពសមស្របតាមប្រធានបទ។

១០- អាចជ្រើសរើសប្រភេទរុក្ខជាតិផ្សេងៗដែលមានឫសរយាងច្រើន សម្រាប់ធ្វើពិសោធនៅក្នុងមូលដ្ឋានជាក់ស្ដែង។

*សូមចូលទៅកាន់វីដេអូពិសោធន៍តាមតំណភ្ជាប់នេះ*

## ៦.២- បញ្ជីត្រួតពិនិត្យ (☑ Check List)

គ្រូ និងសិស្សត្រូវត្រៀមទៅតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ ក្នុងអំឡុងពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** (☑ Check List) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ជំពូក២៖ ការលូតលាស់ និងតំណបរំញោចរុក្ខជាតិ<br>មេរៀនទី១៖ ដំណឹកនាំ និងការលូតលាស់នៅក្នុងរុក្ខជាតិ<br>ទំព័រទី២២<br>☐ បានបង្រៀនរួចហើយ<br>**ប្រធានបទ៖ សង្កេតទំនាក់ទំនងរវាងសម្រូបទឹក និងរំភាយចំហាយទឹករបស់រុក្ខជាតិ**<br>☐ បានត្រៀមសម្ភារៈរួចរាល់រួមមាន៖ ទឹក រុក្ខជាតិ ថង់ប្លាស្ទិកថ្លា ស្កុតថ្លា ស្កុតក្រដាស ដបជ័រថ្លា(ឬស៊ីទ្បាំងក្រិត) កន្ត្រៃ កូនកន្សែង ហ្វឺត ពីប៉ែតជ័រ និងក្រដាស$A_0$<br>☐ បានត្រៀមសន្លឹកកិច្ចការពិសោធន៍ ដំណើរការសង្កេតទំនាក់ទំនងរវាងសម្រូបទឹក និងរំភាយចំហាយទឹករបស់រុក្ខជាតិ<br>☐ បានត្រៀមសន្លឹកកិច្ចការវាយតម្លៃ និងចែកឱ្យសិស្សរួចរាល់<br>☐ បានផ្ញើវីដេអូ ដំណើរការសង្កេតទំនាក់ទំនងរវាងសម្រូបទឹក និងរំភាយចំហាយទឹករបស់រុក្ខជាតិឱ្យសិស្សរួចរាល់<br>☐ បានត្រៀមសន្លឹកវាយតម្លៃ ឬកម្មវិធីវាយតម្លៃឌីជីថលរួចរាល់<br>☐ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទីសមាជិកក្រុមម្នាក់ៗច្បាស់លាស់ (ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។ | ☐ បានរៀនទ្រឹស្តីមេរៀនរួចហើយ<br>☐ បានរក និងប្រមូលសម្ភារៈគ្រប់គ្រាន់<br>☐ បានអាន និងយល់ពីដំណើរការនៅក្នុងសន្លឹកកិច្ចការដែលគ្រូបានចែកឱ្យ<br>☐ បានមើលវីដេអូ ដំណើរការសង្កេតទំនាក់ទំនងរវាងសម្រូបទឹក និងរំភាយចំហាយទឹករបស់រុក្ខជាតិរួចរាល់<br>☐ បានសង្កេតដំណើរការពិសោធន៍ទៅតាមជំហាននីមួយៗ និងមានឯកសារពាក់ព័ន្ធរួចហើយ<br>☐ បានត្រៀមចូលរួមក្នុងការវាយតម្លៃរបស់គ្រូ<br>☐ បានបង្កើតក្រុម និងបែងចែកតួនាទីសមាជិកក្រុមច្បាស់លាស់។ |
| **ក្នុងអំឡុងពិសោធន៍** (☑ Check List) | |
| **គ្រូ** | **សិស្ស** |
| ☐ រំឭក ឬមើលវីដេអូអំពីដំណើរការពិសោធន៍<br>☐ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួច<br>☐ សម្របសម្រួលតាមក្រុម<br>– បំផុស ឬផ្តល់គន្លឹះដល់ក្រុមសិស្ស<br>– បង្កើនការប្រុងប្រយ័ត្នដល់សិស្ស<br>– សង្កេត តាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុមនីមួយៗ<br>☐ ឱ្យសិស្សសរសេររបាយការណ៍មេរៀននៅក្នុងសន្លឹកកិច្ចការពិសោធន៍ជាបុគ្គល ឬក្រុម។ | ☐ រំឭកដំណើរការពិសោធន៍ឡើងវិញ<br>☐ ប្រធានក្រុមដឹកនាំដំណើរការពិសោធន៍តាមក្រុមនីមួយៗ<br>☐ សង្កេត ពិភាក្សា និងកត់ត្រា<br>☐ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ<br>☐ បោសសម្អាតបន្ទប់<br>☐ អាន និងស្វែងយល់បន្ថែម<br>☐ សរសេររបាយការណ៍។ |

| ក្រោយពិសោធន៍ ( ☑ Check List ) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ប្រមូលសន្លឹកកិច្ចការពិសោធន៍<br>– **វាយតម្លៃ៖** គ្រូអាចឱ្យសិស្ស<br>☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>☐ ធ្វើបទបង្ហាញ<br>☐ ឆ្លើយសំណួរនៅក្នុងកម្មវិធីវាយតម្លៃឌីជីថល ( ឧទាហរណ៍៖ Kahoot, Quizizz, Blooket, Padlet... )។ | ☐ ប្រគល់សន្លឹកកិច្ចការពិសោធន៍ឱ្យគ្រូ<br>– **កិច្ចការវាយតម្លៃ៖**<br>☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>☐ ធ្វើបទបង្ហាញជាក្រុម<br>☐ ឆ្លើយសំណួរនៅក្នុងកម្មវិធីវាយតម្លៃឌីជីថល ( ឧទាហរណ៍៖ Kahoot, Quizizz, Blooket, Padlet... )។ |

## ៦.៣- សន្លឹកកិច្ចការពិសោធន៍

### ប្រធានបទ៖ ទំនាក់ទំនងរវាងសម្រូបទឹក និងរំភាយចំហាយ

### ៦.៣.១- សេចក្តីផ្តើម



រុក្ខជាតិមានសរសៃនាំស្រូបយកទឹក និងអំបិលខនិជពីក្នុងដីតាមរយៈរោមជញ្ជក់របស់ឫស។ រោមជញ្ជក់ផ្ទារៗច្រើនរាប់លានបង្កើតជាផ្ទៃប៉ះមួយដ៏ធំរវាងរុក្ខជាតិ និងមជ្ឈដ្ឋានខាងក្រៅ។ ដូច្នេះឫសមាននាទីយ៉ាងសំខាន់ក្នុងការសម្រូបទឹកឱ្យបានគ្រប់គ្រាន់សម្រាប់ទ្រទ្រង់សារពាង្គកាយរុក្ខជាតិ។ ក្រោយពីសម្រូបទឹក រុក្ខជាតិធ្វើរំភាយចំហាយទឹកចេញពីស្លឹកតាមស្តូម៉ាត។ បាតុភូតរំភាយចំហាយទឹកបង្កើតឱ្យមានតុល្យភាពទឹកនៅក្នុងសារពាង្គកាយរុក្ខជាតិ។

តើសម្រូបទឹក និងរំភាយចំហាយទឹករបស់រុក្ខជាតិមានទំនាក់ទំនងគ្នាដូចម្តេច?

### ៦.៣.២- វត្ថុបំណង

- **វិជ្ជាសម្បទា :** បកស្រាយពីទំនាក់ទំនងរវាងសម្រូប និងរំភាយចំហាយទឹករបស់រុក្ខជាតិបានត្រឹមត្រូវតាមរយៈការពិសោធ។
- **បំណិនសម្បទា :** វិភាគពីទំនាក់ទំនងរវាងសម្រូបទឹក និងរំភាយចំហាយទឹករបស់រុក្ខជាតិបានត្រឹមត្រូវតាមរយៈការពិសោធ។
- **ចរិយាសម្បទា :** ចូលរួមដាំ និងថែរក្សារុក្ខជាតិ ដើម្បីរក្សាលំនឹងបរិស្ថាន។

### ៦.៣.៣- វិធីសាស្ត្រ

**ក- សម្ភារៈ**

| | | | | | |
|---|---|---|---|---|---|
|  ១. រុក្ខជាតិ (ដើមកណ្តៀងឈើ) |  ២. ថង់ប្លាស្ទិច |  ៣. ស្រោមដៃ |  ៤. កន្ត្រៃ |  ៥. កូនកន្សែង |  ៦. ថាស |
|  ៧. ទឹក |  ៨. ស្កុតថ្លា |  ៩. ស្កុតក្រដាស |  ១០. ស៊ីឡាំងក្រិត |  ១១. ហ្វឺត |  ១២. ពីប៉ែតជ័រ |

**ខ- ដំណើរការ**

១- រៀបចំស៊ីឡាំងក្រិតចំនួន៤(A,B C និងD)៖

- ស៊ីឡាំងក្រិត A មិនដាក់រុក្ខជាតិ
- ស៊ីឡាំងក្រិត B ដាក់ដើមរុក្ខជាតិដែលមានឫស និងស្លឹក

– ស៊ីឡាំងក្រិត C ដាក់ដើមរុក្ខជាតិដែលមានស្លឹក តែគ្មានឫស(កាត់ឫសចេញ)
– ស៊ីឡាំងក្រិត D ដាក់ដើមរុក្ខជាតិដែលមានតែឫស(កាត់ស្លឹកចេញ)។

**បញ្ជាក់៖** រុក្ខជាតិនីមួយៗត្រូវលាងសម្អាតឫស និងមានចំនួនស្លឹកស្មើ ឬប្រហាក់ប្រហែលគ្នា។

២- ដាក់ដើមរុក្ខជាតិចូលក្នុងស៊ីឡាំងក្រិត B C និងD(ផ្នែកគល់ចុះក្រោម)។

៣- ចាក់ទឹកចូលក្នុងស៊ីឡាំងក្រិតនីមួយៗឱ្យដល់កម្រិត២៥០មីលីលីត្រ រួចយកស្កុតបិទមាត់ស៊ីឡាំងក្រិតឱ្យបានជិតល្អ។

៤- យកស្កុតថ្លាបិទមាត់ស៊ីឡាំងក្រិតនីមួយៗឱ្យបានជិតល្អ។

៥- យកថង់ប្លាស្ទិកថ្លាគ្របពីលើមាត់ស៊ីឡាំងក្រិតនីមួយៗ ហើយរុំស្កុតឱ្យបានណែន និងជិតល្អ។

៦- យកស៊ីឡាំងក្រិតទាំង៤ដាក់នៅកន្លែងដែលមានពន្លឺព្រះអាទិត្យ(មិនក្ដៅពេក) ដោយទុករយៈពេលយ៉ាងតិច៤០នាទី រួចសង្កេត។

## គ- លទ្ធផល និងវិភាគ

### – លទ្ធផល

ចូរសង្កេតពីបម្រែបម្រួលកម្រិតទឹកក្នុងស៊ីឡាំងក្រិតទាំង៤ រួចបំពេញលទ្ធផលក្នុងតារាងខាងក្រោម៖

| ស៊ីឡាំងក្រិត | បម្រែបម្រួលកម្រិតទឹកក្នុងស៊ីឡាំងក្រិតទាំង៤ (ml) | | |
|---|---|---|---|
| | មុនពេលដាក់ក្រោមពន្លឺព្រះអាទិត្យ | បន្ទាប់ពីដាក់ក្រោមពន្លឺព្រះអាទិត្យ | |
| | | ៤០នាទី | ៣ម៉ោង៤០នាទី |
| A | | | |
| B | | | |
| C | | | |
| D | | | |



### – វិភាគ

១- តើពន្លឺព្រះអាទិត្យមានឥទ្ធិពលលើទំនាក់ទំនងសម្រូបទឹក និងរំភាយចំហាយទឹកដូចម្ដេច?

........................................................................................................................................
........................................................................................................................................
........................................................................................................................................
........................................................................................................................................
........................................................................................................................................
........................................................................................................................................
........................................................................................................................................

២- តើឫសរុក្ខជាតិមាននាទីដូចម្ដេច ក្នុងអំឡុងពេលពិសោធន៍នេះ?

........................................................................................................................................
........................................................................................................................................
........................................................................................................................................
........................................................................................................................................
........................................................................................................................................

៣- តើស្លឹករុក្ខជាតិមាននាទីដូចម្ដេច ក្នុងអំឡុងពេលពិសោធន៍នេះ?

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

**ឃ- សន្និដ្ឋាន**

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

**ខ- សំណួរពង្រីកចំណេះដឹង**

១- តើទំនាក់ទំនងរវាងសម្រូបទឹក និងការរំភាយចំហាយទឹករបស់រុក្ខជាតិមានសារៈប្រយោជន៍ដូចម្ដេចចំពោះបរិស្ថាន?

២- តើការរំភាយចំហាយទឹករបស់រុក្ខជាតិ ប្រមូលបានដូចម្ដេច?

៣- តើចំនួនស្លឹករុក្ខជាតិមានឥទ្ធិពលទៅលើសម្រូបទឹកដូចម្ដេច?

៤- តើប្រភេទឫសរុក្ខជាតិមានឥទ្ធិពលទៅលើសម្រូប និងរំភាយចំហាយទឹកដូចម្ដេច?